របាយការណ៍ពិនិត្យតាមដានការអនុវត្តអនុសញ្ញា ស៊ី-ដ សម្រាប់ប្រទេសកម្ពុជា ២០២៥

NGO-CEDAW

សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះត្រូវបានរៀបចំឡើង ដោយគណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (NGO-CEDAW) ដោយសហការជាមួយអង្គការសង្គមស៊ីវិលជាសមាជិក និងដៃគូរបស់ខ្លួន ក៏ដូចជា សម្ព័ន្ធសង្គមស៊ីវិលផ្សេងទៀតនៅកម្ពុជា ដែលមានសណ្ឋានចិត្តជួយផ្តល់ជាធាតុចូល និងការប្រឹក្សាផ្ទៃកបច្ចេកទេសផ្សេងៗ។

NGO-CEDAW សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការរួមចំណែករបស់ អង្គការអាក់សិនអេតកម្ពុជា (AAC) អង្គការសេរីភាពកម្ពុជាអូស្ត្រាលី (AusCam) អង្គការបន្ទាយស្រី (BS) អង្គការអភិវឌ្ឍន៍សម្លេងសហគមន៍ (BCV) មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM) អង្គការកម្ពុជាដើម្បីសុខភាពនិងការអប់រំសហគមន៍ (CHEC) សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (CamboJA) អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ) អង្គការទ្រទ្រង់ស្ត្រីខ្មែរ (COWS) អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ (CWCC) សហភាពការងារកម្ពុជា (CLC) មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL) គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL) អង្គការតំណាក់ទឹក សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA) អង្គការក្លាហាន (Klahaan) មីក្រូឥន្ធធនូកម្ពុជា (MRC) សមាគមអភិវឌ្ឍន៍ជនជាតិដើមភាគតិចមណ្ឌលគីរី (MIPAD) អង្គការភ្នំស្រីដើម្បីអភិវឌ្ឍន៍ (PSOD) អង្គការថែទាំសុខភាពគ្រួសារកម្ពុជា (អង្គការ រ៉ាក់) អង្គការលើកកម្ពស់គុណភាពជីវិត (WELL) អង្គការនារីដើម្បីសន្តិភាព (WPM) និងបណ្តាញការងារស្ត្រីរួបរួមគ្នា (WNU)

របាយការណ៍នេះបានទទួលការគាំទ្រថវិកាសប្បុរសធម៌ពីអង្គការ Bread for the World (BfdW) អង្គការ DanChurchAid កម្ពុជា (DCA) និងអង្គការមូលនិធិ ហេនរេច បូល កម្ពុជា (HBF) រាល់ទស្សនៈដែលបានលើកឡើងនៅក្នុងឯកសារនេះ មិនសុទ្ធតែឆ្លុះបញ្ចាំងអំពីទស្សនៈរបស់អង្គការដែលគាំទ្រថវិកានោះឡើយ។

Brot für die Welt

DCA actalliance

HEINRICH BÖLL STIFTUNG PHNOM PENH Cambodia

មាតិកា

សេចក្តីថ្លែងអំណរគុណ	01
មាតិកា	02
អក្សរកាត់	03
ទិដ្ឋភាពទូទៅក្នុងឆ្នាំ ២០២៥	04
វិធីសាស្ត្រ	06
១. ជម្លោះព្រំដែនរវាងកម្ពុជា-ថៃ	07
១.១ ការជម្លៀសនៅក្នុងប្រទេស	08
១.២ ពលករចំណាកស្រុកដែលបានវិលត្រលប់	10
២. ស្ត្រី សន្តិភាព និងសន្តិសុខ	12
៣. ភាពមិនមានសញ្ញាតិ	14
៤. ស្ត្រីក្នុងភាពជាអ្នកដឹកនាំ	16
៥. សេរីភាពមូលដ្ឋាន និងលំហស៊ីវិល	17
៥.១ សកម្មនិយមនយោបាយ	18
៥.២ សកម្មនិយមបរិស្ថាន	18
៥.៣ សហជីពកម្មករ	19
៥.៤ សេរីភាពសារព័ត៌មាន និងស្ត្រីនៅក្នុងវិស័យសារព័ត៌មាន	19
៦. ការរំលោភយកដីធ្លី និងការបណ្តេញចេញដោយបង្ខំ	22
៧. ការប្រែប្រួលអាកាសធាតុ	24
៨. បំណុលមីក្រូហិរញ្ញវត្ថុ	26
៩. អំពើហិង្សាទាក់ទងនឹងយេនឌ័រ	27
៩.១ ឧប្បត្តិហេតុនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ	27
៩.២ លទ្ធភាពទទួលបានសេវា និងយុត្តិធម៌	29
៩.៣ អំពើហិង្សាទាក់ទងនឹងយេនឌ័រដែលសម្របសម្រួលដោយបច្ចេកវិទ្យា (TFGBV)	30
៩.៤ អាពាហ៍ពិពាហ៍កុមារ	32
៩.៥ អំពើហិង្សាលើអ្នកប្រកបរបរផ្លូវភេទ និងអ្នកធ្វើការនៅគ្រឹះស្ថានសេវាកម្សាន្ត	32
៩.៦ អំពើជួញដូរមនុស្ស និងទីតាំងឆបោកតាមអនឡាញ	33
១០. ការងារ និងសិទ្ធិការងារ	25
១០.១ ការទទួលបានកិច្ចគាំពារសង្គមក្នុងចំណោមកម្មករក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ	35
១០.២ ការរើសអើងនៅកន្លែងធ្វើការ	37
១០.៣ សិទ្ធិការងាររបស់អ្នកប្រកបរបរផ្លូវភេទ និងអ្នកធ្វើការនៅគ្រឹះស្ថានសេវាកម្សាន្ត	37
១១. ការថែទាំសុខភាព	38
១១.១ សុខភាពផ្លូវភេទ និងបន្តពូជ និងសិទ្ធិផ្សេងៗ	38
១១.២ ការថែទាំសុខភាពផ្លូវចិត្ត	40
១២. ស្ត្រី និងក្មេងស្រីក្នុងពន្ធនាគារ	41
អនុសាសន៍	43
ការវិវឌ្ឍនៃការអនុវត្តនូវសេចក្តីសង្កេតសន្និដ្ឋានចុងក្រោយអនុសញ្ញាស៊ី-ដ ឆ្នាំ២០១៩ (CoBs)	44

អក្សរកាត់

CamboJA	សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា
CCIM	មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ
CDRI	វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
CEDAW	អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (ស៊ី-ដ)
CENTRAL	មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស
COWS	អង្គការទ្រទ្រង់ស្ត្រីខ្មែរ
CSE	ការអប់រំសុខភាពផ្លូវភេទគ្រប់ជ្រុងជ្រោយ
CWCC	អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ
IDEA	សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ
LGBTIQ+	សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា
LICADHO	អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស
LRSU	សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនណាហ្គាវើលដ៏
NGO-CEDAW	Cambodiaគណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ
NSAF	មូលនិធិជាតិជំនួយសង្គម
NSSF	បេឡាជាតិសន្តិសុខសង្គម
OHCHR	ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស
RHAC	អង្គការថែទាំសុខភាពគ្រួសារកម្ពុជា
TFGBV	អំពើហិង្សាទាក់ទងនឹងយេនឌ័រដែលសម្របសម្រួលដោយបច្ចេកវិទ្យា
WELL	អង្គការលើកកម្ពស់គុណភាពជីវិត
WNU	បណ្តាញការងារស្ត្រីរួបរួមគ្នា
WPM	អង្គការនារីដើម្បីសន្តិភាព
WPS	ស្ត្រី សន្តិភាព និងសន្តិសុខ

ទិដ្ឋភាពទូទៅក្នុងឆ្នាំ ២០២៥

សិទ្ធិស្ត្រី ក្មេងស្រី និងអ្នកមិនកំណត់អត្តសញ្ញាណភេទស្រី ឬប្រុស (non-binary) នៅប្រទេសកម្ពុជា បានជួបប្រទះនឹងឧបសគ្គជាច្រើននៅក្នុងឆ្នាំ ២០២៥ ស្របពេលមានជម្លោះប្រដាប់អាវុធ ការជម្លៀសចេញពីទីលំនៅ វិបត្តិសេដ្ឋកិច្ច ការរិតត្បិតលំហសង្គមស៊ីវិល និងការរើសអើងយេនឌ័រ និងអំពើហិង្សាទាក់ទងនឹងយេនឌ័ររ៉ាំរ៉ៃ។ ប្រទេសកម្ពុជានៅពុំទាន់បានអនុវត្តឱ្យបានពេញលេញទេ ចំពោះកាតព្វកិច្ចរបស់ខ្លួនក្រោមអនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (ស៊ី-ដ) ហើយរឌ្ឍនភាពនៃការអនុវត្តសេចក្តីសង្កេតសន្និដ្ឋានឆ្នាំ ២០១៩ របស់គណៈកម្មាធិការ ស៊ី-ដ ឱ្យបានជាប់លាប់នៅតែជារឿងចាំបាច់។[1]

ប្រជាជនចំនួន
៦៤៤.000នាក់
ត្រូវបានផ្លាស់ទីលំនៅ
នៅក្នុងប្រទេស

ជម្លោះតាមបណ្តោយព្រំដែនកម្ពុជា-ថៃ បង្កផលប៉ះពាល់ធំធេងទៅលើយេនឌ័រ ប៉ុន្តែអន្តរាគមន៍ឆ្លើយតបបន្ទាន់ភាគច្រើន គឺខ្វះការរិភាគលើយេនឌ័រ។ ការជម្លៀសប្រជាជនពីទីលំនៅទ្រង់ទ្រាយធំចំនួន ៦៤៤.000នាក់ បានផ្តល់ការលំបាកដល់ស្ត្រី និងក្មេងស្រីក្នុងការទទួលបានសេវាថែទាំសុខភាព ការអប់រំ ការប្រកបមុខរបរ និងតម្រូវការចាំបាច់មូលដ្ឋាន ហើយថែមទាំងបង្កើនហានិភ័យនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការបៀតបៀនផ្លូវភេទទៀតផង។ ការវិលត្រឡប់យ៉ាងគំហុករបស់ពលករចំណាកស្រុកកម្ពុជាប្រមាណ ៩១0.000នាក់ ពីប្រទេសថៃ បានដាក់សម្ពាធបន្ថែមទៀតលើជីវភាពរស់នៅ និងធ្វើឱ្យចរន្តនៃការផ្ញើប្រាក់ដើម្បីផ្គត់ផ្គង់គ្រួសារធ្លាក់ចុះ ដោយក្នុងនោះមានការលើកឡើងនៅក្នុងរបាយការណ៍ថា ស្ត្រីមិនអាចស្វែងរកការងារស្របតាមជំនាញរបស់ខ្លួនឡើយ ក្រោយពេលពួកគាត់វិលត្រឡប់មកវិញ។ ការវិវត្តទាំងអស់នេះ បានគូសបញ្ជាក់ឱ្យឃើញពីសារៈសំខាន់នៃរបៀបវារៈស្តីពី “ស្ត្រី សន្តិភាព និងសន្តិសុខ” ប៉ុន្តែប្រទេសកម្ពុជានៅពុំទាន់បានអនុម័តផែនការសកម្មភាពជាតិនៅឡើយទេ គិតត្រឹមចុងឆ្នាំ ២០២៥។

ពលករចំណាកស្រុកកម្ពុជាចំនួន
910,000នាក់
បានត្រឡប់មកពីប្រទេសថៃ

គួរកត់សម្គាល់ថា ស្ត្រីនៅតែមានតំណាងតិចនៅក្នុងជួរដឹកនាំ និងក្នុងការសម្រេចចិត្តនៅគ្រប់កម្រិតទាំងអស់ ហើយលំហសង្គមស៊ីវិលនៅតែបន្តរងការគាបសង្កត់។ ស្ត្រីជាសកម្មជនជួបប្រទះការបៀតបៀន និងការឃ្លាំមើលជាប្រព័ន្ធ ដោយក្នុងនោះស្ត្រីជាសកម្មជនយ៉ាងហោចណាស់ ១៨នាក់ បន្តជាប់ពន្ធនាគារនៅឡើយគិតត្រឹមចុងឆ្នាំកន្លងទៅ។ វិសោធនកម្មទៅលើច្បាប់រដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីសញ្ជាតិ បានបង្កើនហានិភ័យនៃការដកហូតសញ្ជាតិតាមអំពើចិត្ត និងភាពគ្មានសញ្ជាតិ ជាពិសេសចំពោះស្ត្រី និងក្មេងស្រី ដែលសម្តែងមតិប្រឆាំង។

យ៉ាងហោចណាស់សកម្មជនស្ត្រី
១៨នាក់
ដែលនៅបន្តជាប់ពន្ធនាគារ
នៅចុងឆ្នាំ ២០២៥

ការរំលោភយកដីធ្លី ការបណ្តេញចេញដោយបង្ខំ និងការផ្តល់ប្រាក់កម្ចីមីក្រូហិរញ្ញវត្ថុបែបកេងប្រវ័ញ្ចនៅតែបន្តកើតមាននៅទូទាំងប្រទេស ដែលប៉ះពាល់ដោយមិនមានសមមាត្រចំពោះស្ត្រី និងជនជាតិដើមភាគតិច។ ស្រដៀងគ្នានេះដែរ ការប្រែប្រួលអាកាសធាតុ ក៏ធ្វើឱ្យវិសមភាពយេនឌ័រកាន់តែធ្ងន់ធ្ងរឡើង ដោយធ្វើឱ្យប៉ះពាល់ដល់សន្តិសុខស្បៀង សុខភាព និងជីវភាពរស់នៅ និងមានការកើនឡើងនូវការងារថែទាំដោយមិនមានប្រាក់កម្រៃ។ ទោះបីជាយ៉ាងនេះក្តី គោលនយោបាយអាកាសធាតុ ដែលឆ្លើយតបទៅនឹងយេនឌ័រ មិនត្រូវបានអនុវត្តឱ្យបានពេញលេញនោះទេ ហើយសកម្មជនបរិស្ថាន នៅតែបន្តជាប់ពន្ធនាគារដដែល។

1 CEDAW Committee, “Concluding observations on the sixth periodic report of Cambodia”, CEDAW/C/KHM/CO/6, November 12, 2019, para. 15(b), online: <https://docs.un.org/en/CEDAW/C/KHM/CO/6>.

អំពើហិង្សាទាក់ទងនឹងយេនឌ័រនៅតែរីករាលដាល រួមទាំងអំពើហិង្សាក្នុងគ្រួសារ និងផ្លូវភេទ ការរំលោភបំពានតាមរយៈបច្ចេកវិទ្យា អំពើជួញដូរមនុស្ស និងអំពើហិង្សាលើអ្នកប្រកបរបរផ្លូវភេទ និងអ្នកធ្វើការនៅគ្រឹះស្ថានសេវាកម្មរាត្រី។ យុត្តិធម៌ និងសេវាសង្គមកិច្ច ដែលផ្តោតលើជនរងគ្រោះ នៅតែមិនទាន់មានលក្ខណៈគ្រប់គ្រាន់ ហើយកំណែទម្រង់ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះនៅបន្តជាប់គាំងដដែល។ អំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ច នៅតាមទីតាំងបទល្មើសឆបោក នៅតែបន្តកើតមាន ហើយមានទិន្នន័យភាពស្ទើរតែទាំងស្រុង មនុស្សបានទទួលរងការបង្ខិតបង្ខំឱ្យប្រើកម្លាំងពលកម្ម ការធ្វើទារុណកម្ម និងអំពើហិង្សាផ្លូវភេទដោយគ្មានការផ្តន្ទាទោសចំពោះអ្នកជួញដូរ នៅក្នុងប្រទេសកម្ពុជានោះទេ។

អសន្តិសុខសេដ្ឋកិច្ច និងការរំលោភសិទ្ធិការងារនៅតែបន្តកើតមានចំពោះស្ត្រីជាច្រើន ចំណែកឯកម្មករក្នុងវិស័យក្រៅប្រព័ន្ធប្រឈមមុខនឹងការផាត់ចេញតាមអំពើចិត្ត ពីយន្តការគាំពារសង្គម។ អ្នកប្រកបរបរផ្លូវភេទ និងអ្នកធ្វើការនៅគ្រឹះស្ថានសេវាកម្មរាត្រីនៅតែបន្តខ្វះកិច្ចការពារ ផ្នែកសិទ្ធិការងារ ដែលជាការឆ្លុះបញ្ចាំងឱ្យឃើញថា រាជរឿងចាំបាច់ក្នុងការមិនដាក់ទោសទណ្ឌ ចំពោះការងារប្រកបរបរផ្លូវភេទ។ លទ្ធភាពទទួលបានសេវាសុខភាពនៅតែពុំមានភាពស្មើគ្នា។

សេវាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ រួមទាំងការរំលូតកូនដោយសុវត្ថិភាព ត្រូវបានរារាំងដោយការមើលងាយ និងការយល់ដឹងមានកម្រិត ខណៈដែលការអនុវត្តការងារអប់រំផ្លូវភេទឱ្យបានគ្រប់ជ្រុងជ្រោយពុំមានភាពជាប់លាប់នៅឡើយ។

ស្ត្រី និងក្មេងស្រីដែលកំពុងជាប់ឃុំឃាំងមានការកើនឡើង

២៦%

វិបត្តិនៃភាពចង្អៀតណែនក្នុងពន្ធនាគារនៅកម្ពុជា កាន់តែមានសភាពធ្ងន់ធ្ងរឡើង ដោយក្នុងនោះចំនួនស្ត្រី និងក្មេងស្រីដែលកំពុងជាប់ឃុំឃាំងមានការកើនឡើង ២៦%។ ភាគច្រើនត្រូវបានឃុំខ្លួនបណ្តោះអាសន្ន មុនការកាត់ទោសក្រោមលក្ខខណ្ឌដែលមិនគ្រប់គ្រាន់។

0.១៤%

នៃថវិកាជាតិរបស់កម្ពុជា ត្រូវបានបែងចែកសម្រាប់ក្រសួងកិច្ចការនារី

ទោះបីប្រទេសកម្ពុជាមានគោលនយោបាយ និងយុទ្ធសាស្ត្រជាច្រើនទាក់ទងនឹងយេនឌ័រក៏ដោយ ប៉ុន្តែការអនុវត្តនៅមានកម្រិត មិនមានភាពស្មើគ្នា និងខ្វះខាតធនធានក្នុងការអនុវត្ត។ ក្រសួងកិច្ចការនារីនៅតែជាក្រសួងមួយក្នុងចំណោមបណ្តាក្រសួង ដែលទទួលបានថវិកាតិចជាងគេបំផុត ដោយទទួលបានថវិកាចំនួន ៥១,៩៧៩លានរៀល (ប្រហែល ១២.៩៩លានដុល្លារអាមេរិក) ដែលស្មើនឹងប្រមាណ 0.១៤% នៃថវិកាជាតិប៉ុណ្ណោះ ខណៈដែលការបញ្ជាបយេនឌ័រនៅតាមបណ្តាក្រសួងផ្សេងទៀតខ្វះធនធាន និងគណនេយ្យភាពឱ្យបានជាប់លាប់។[2]

ទន្ទឹមនឹងបញ្ហាប្រឈមទាំងនេះ សង្គមស៊ីវិល និងចលនាសិទ្ធិស្ត្រីបានប្រឈមមុខនឹងការកាត់បន្ថយជំនួយថវិកា ដែលមិនធ្លាប់មានពីមុនមក ពីសំណាក់តួអង្គជាដៃគូអភិវឌ្ឍន៍អន្តរជាតិ។ ការដែលសហរដ្ឋអាមេរិកបានបញ្ចប់ភ្លាមៗ នូវជំនួយបរទេស ចាប់ពីខែមករា ឆ្នាំ២០២៥ បានធ្វើឱ្យស្ថាប័នជាច្រើន ជួបប្រទះនូវវិបត្តិក្នុងការដំណើរការ។ ការផ្តល់មូលនិធិប្រកបដោយចីរភា សម្រាប់ចលនាស្ត្រីនិយម និងសិទ្ធិស្ត្រី គឺមានសារៈសំខាន់ខ្លាំងណាស់នៅក្នុងឆ្នាំ ២០២៦។

ស្របពេលដែលបរិបទជាតិ និងពិភពលោកមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស រឌ្ឍនភាពវិជ្ជមានឆ្ពោះទៅរកសមភាពយេនឌ័រនៅកម្ពុជា អាស្រ័យលើរដ្ឋាភិបាលក្នុងការអនុវត្តកំណែទម្រង់ជាបន្ទាន់ ជាប់លាប់ និងមានធនធានគ្រប់គ្រាន់ ដែលផ្តោតលើសំឡេង អាទិភាព និងស្ថានភាពជីវិតជាក់ស្តែងរបស់ស្ត្រី ក្មេងស្រី និងអ្នកកំណត់អត្តសញ្ញាណស្រី ឬប្រុសដើម្បីធានាបានថាពួកគាត់មានសិទ្ធិពេញលេញ។

2 Ministry of Economy and Finance, “Budget in Brief: Fiscal Year 2025”, online: https://mef.gov.kh/documents/budget-in-brief-2025/.

វិធីសាស្ត្រ

គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសប្រឆាំងនឹងនារីភេទ (NGO-CEDAW) បានចងក្រងរបាយការណ៍នេះឡើង ដោយប្រើប្រាស់វិធីសាស្ត្របែបចូលរួម ដោយមានការសហការជាមួយអង្គការសង្គមស៊ីវិលជាសមាជិកអង្គការដៃគូ និងសម្ព័ន្ធដៃគូដទៃទៀត។ អ្នកតំណាង ៣២នាក់ មកអង្គការសង្គមស៊ីវិល និងសមាគមចំនួន ២៧ បានចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់ពេញមួយថ្ងៃ នៅទីក្រុងភ្នំពេញ ដើម្បីកំណត់ចំណុចអាទិភាពប្រធានបទ និងព្រឹត្តិការណ៍នានាដើម្បីដាក់បញ្ចូលក្នុងរបាយការណ៍នេះ។

សង្គមស៊ីវិលដៃគូនានា បានបង្កើតចេញជាក្រុមការងារតាមមូលបទចំនួនប្រាំបី ក្នុងអំឡុងពេលសិក្ខាសាលានោះ។ ក្រុមការងារទាំងនេះ និងដៃគូនីមួយៗត្រូវបានអញ្ជើញឱ្យឡើងចែករំលែកព័ត៌មាន រួមទាំងរបាយការណ៍សង្ខេប ទិន្នន័យបឋមដែលអង្គការរបស់ខ្លួនបានចងក្រងឡើង និងប្រភពទិន្នន័យមានស្រាប់។ បណ្តាដៃគូ ត្រូវបានអញ្ជើញឱ្យឡើងចែករំលែកព័ត៌មានដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរជាភាសាខ្មែរ ឬភាសាអង់គ្លេស។ អង្គការ ស៊ី-ដ ក៏បានពិនិត្យឯកសារឡើងវិញ ទៅតាមប្រភពបន្ថែមទៀតសម្រាប់ដាក់បញ្ចូលក្នុងរបាយការណ៍នេះផងដែរ។ សិក្ខាសាលាពិគ្រោះយោបល់លើកទីពីរមានអ្នកចូលរួមចំនួន ៣៨នាក់ ដែលតំណាងឱ្យសង្គមស៊ីវិលជាដៃគូចំនួន ២៨ស្ថាប័ន ដើម្បីផ្ទៀងផ្ទាត់លទ្ធផលដែលបានរកឃើញ និងរួមគ្នាចងក្រងអនុសាសន៍សំខាន់ៗ។

របាយការណ៍នេះសង្ខេបអំពីការវិវឌ្ឍ និងព្រឹត្តិការណ៍សំខាន់ៗក្នុងឆ្នាំ ២០២៥។ របាយការណ៍នេះមិនមានគោលបំណងរៀបរាប់ឱ្យបានគ្រប់ជ្រុងជ្រោយនៃបញ្ហាទាំងអស់ ដែលប៉ះពាល់លើស្ត្រី ក្មេងស្រី និងអ្នកមិនកំណត់អត្តសញ្ញាណភេទស្រី ឬប្រុសនៅកម្ពុជានោះទេ ប៉ុន្តែផ្តោតលើបញ្ហាថ្មីៗ ឬជាកង្វល់ចម្បងដែលកើតឡើងក្នុងឆ្នាំ ២០២៥។

០១.

ជម្លោះព្រំដែនរវាងកម្ពុជា-ថៃ

ជម្លោះលើការកំណត់ព្រំដែនជាយូរមកហើយតាមបណ្តោយព្រំដែនកម្ពុជា - ថៃបានផ្ទុះឡើងខ្លាំងនៅក្នុងខែឧសភា ឆ្នាំ២០២៥។ កម្ពុជាបានផ្អាកការទាំចូលអគ្គិសនី អ៊ីនធឺណិត ប្រេងឥន្ធនៈ និងឧស្ម័នពីប្រទេសថៃ ហើយការបិទព្រំដែនផ្លូវគោកមិនយូរប៉ុន្មាន បានបញ្ឈប់ទាំងចរាចរណ៍មនុស្ស និងទំនិញ។ ជម្លោះនេះមានសភាពកាន់តែខ្លាំងឡើងនៅថ្ងៃទី២៤ ខែកក្កដា ដោយភាគីទាំងសងខាងបានបាញ់ប្រយុទ្ធគ្នាដោយអាវុធធុនធ្ងន់នៅតាមចំណុចព្រំដែនជាច្រើនកន្លែង ទម្រាំឈានដល់បទឈប់បាញ់នៅថ្ងៃទី២៨ ខែកក្កដា។ នៅប៉ុន្មានខែក្រោយមក ភាពតានតឹងនៅតែមានសភាពខ្លាំងក្លា។ ការប្រយុទ្ធគ្នាបានចាប់ផ្តើមជាថ្មីនៅថ្ងៃទី៧ ខែធ្នូ ហើយបានបន្តរហូតដល់មានបទឈប់បាញ់ម្តងទៀតនៅថ្ងៃទី២៧ ខែធ្នូ។

ជម្លោះនេះមានការប្រើប្រាស់កាំភ្លើងធំធុនធ្ងន់ ការវាយប្រហារតាមផ្លូវអាកាស គ្រាប់មីនប្រឆាំងមនុស្ស ការល្បាតដោយកងទ័ពជើងទឹក និងការវាយប្រហារដោយដ្រូន ទៅលើ និងនៅក្បែរតំបន់ប្រជាជនស៊ីវិល ដោយចូលមកជ្រៅទៅក្នុងទឹកដីកម្ពុជា។ ប្រទេសកម្ពុជាបានរាយការណ៍ថាយោធាចំនួនប្រាំនាក់ និងប្រជាជនស៊ីវិលចំនួនប្រាំបីនាក់បានស្លាប់ និងអ្នករបួសចំនួន ៧១នាក់ក្នុងអំឡុងពេលជម្លោះកាលពីខែកក្កដា។ ចំណែកឯក្នុងជម្លោះកាលពីខែធ្នូ យ៉ាងហោចណាស់មានយោធា និងមន្ត្រីនគរបាលចំនួន ១១០នាក់ និងប្រជាជនស៊ីវិលចំនួន ៣១នាក់ ត្រូវបានកត់ត្រាថាបានស្លាប់នៅក្នុងការប្រយុទ្ធគ្នានោះ។[3]

កាលពីខែវិច្ឆិកា មានរបាយការណ៍ថា ពលករចំណាកស្រុកកម្ពុជាម្នាក់បានរងអំពើហិង្សាផ្លូវភេទពីសំណាក់ក្រុមទាហានថៃចំនួនប្រាំពីរនាក់ នៅពេលដែលស្ត្រីពលករចំណាកស្រុករូបនោះកំពុងព្យាយាមវិលត្រឡប់មកទឹកដីកម្ពុជាវិញ។[4] បើទោះបីជាប្រទេសថៃមានកាតព្វកិច្ចក្រោមច្បាប់មនុស្សធម៌ និងសិទ្ធិមនុស្សអន្តរជាតិក៏ដោយ ក៏មិនទាន់មានការស៊ើបអង្កេតពេញលេញ ឯករាជ្យ និងមានតម្លាភាពណាមួយត្រូវបានធ្វើឡើងចំពោះករណីនោះទេ គិតត្រឹមចុង ឆ្នាំ២០២៥។

3 Danielle Keeton-Olsen and Vantha Phoung, “Cambodian deaths exceed 110 in December border conflict with Thailand”, Nikkei Asia, January 13, 2026, online: https://asia.nikkei.com/politics/international-relations/thailand-cambodia-conflict/cambodian-deaths-exceed-110-in-december-border-conflict-with-thailand.

4 Joint Statement, “Joint Statement by Cambodian Civil Society on Civilian Protection and Women’s Security Amid Border Tensions”, November 19, 2025, online: https://ngocedaw.org/wp-content/uploads/2025/11/ENG_Joint_Statement_by_Cambodian_Civil_Society_on_Thai_Military.pdf.

១.១ ការជម្លៀសនៅក្នុងប្រទេស

ជម្លោះព្រំដែនកម្ពុជា - ថៃ បានបណ្តាលឱ្យមានការជម្លៀសប្រជាជនកម្ពុជាក្នុងប្រទេសរាប់សែននាក់។ ការជម្លៀសដោយបង្ខំ មានការចងក្រងជាឯកសារយ៉ាងទូលំទូលាយថា មានការរឹតត្បិតយ៉ាងខ្លាំងចំពោះសិទ្ធិទទួលបានការអប់រំ មុខរបរ និងសេវាសំខាន់ៗសម្រាប់ស្ត្រី និងក្មេងស្រី ហើយបានធ្វើឱ្យកើនឡើងនូវទំនួលខុសត្រូវ លើការងារថែទាំដែលគ្មានប្រាក់កម្រៃ និងបង្កើនហានិភ័យសុវត្ថិភាព រួមមានហានិភ័យនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងអំពើហិង្សាដោយដៃគូស្និទ្ធស្នាល។[5] ទោះបីជាមានការចងក្រងឯកសារបែបនេះក្តី ប៉ុន្តែផែនការធ្លើយតបផ្នែកមនុស្សធម៌ និងបន្ទាន់ពីសំណាក់រដ្ឋាភិបាលកម្ពុជាភាគច្រើន គឺខ្វះការវិភាគលើយេនឌ័រ និងខ្វះព័ត៌មានលម្អិតបែងចែកទៅតាមភេទ ទាក់ទិននឹងស្ថានភាពរបស់ស្ត្រី ក្មេងស្រី និងអ្នកមិនកំណត់អត្តសញ្ញាណភេទស្រី ឬប្រុស។ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយកម្ពុជាបានរាយការណ៍ថា ជម្លោះកាលពីខែកក្កដា បានធ្វើឱ្យប្រជាជនជាង ១៧២.០០០នាក់ នៅកម្ពុជាត្រូវបានជម្លៀសចេញពីលំនៅដ្ឋាន ដែលភាគច្រើនបានវិលត្រឡប់ទៅលំនៅដ្ឋានវិញនៅក្នុងខែសីហា។[6] នៅក្នុងការប្រយុទ្ធគ្នាជាថ្មីនាខែធ្នូ មានការជម្លៀសប្រជាជន រហូតដល់ទៅចំនួន ៦៤៤.៥៨៩នាក់ ក្នុងនោះមានស្ត្រីចំនួន ៣៣៦.៣០២នាក់ និងកុមារចំនួន ២០៤.៩២២នាក់។[7] ប្រជាជនភាគច្រើនបំផុតត្រូវបានជម្លៀសទៅកាន់ទីតាំងចំនួន ២៣៤កន្លែង ក្នុងខេត្តបន្ទាយមានជ័យ បាត់ដំបង ឧត្តរមានជ័យ ព្រះវិហារ ពោធិ៍សាត់ និងសៀមរាប ចំណែកឯប្រជាជនផ្សេងទៀតស្នាក់នៅជាមួយក្រុមគ្រួសារ ឬមិត្តភក្តិរបស់ខ្លួន។[8]

សហគមន៍ដែលត្រូវបានជម្លៀសពីទីលំនៅ បានជួបប្រទះនឹងការរំខានយ៉ាងធ្ងន់ធ្ងរដល់ជីវភាពរស់នៅ និងលទ្ធភាពទទួលបានទំនិញ និងសេវាសំខាន់ៗរួមមានទីជម្រក ការថែទាំសុខភាព ស្បៀងអាហារ ការអប់រំ កិច្ចគាំពារ អាហារូបត្ថម្ភ អគ្គិសនី ទឹកស្អាតសម្រាប់ទទួលទាន សម្ភារៈប្រើប្រាស់សម្រាប់ពេលមករដូវ និងតម្រូវការទឹកស្អាត និងអនាម័យផ្សេងៗទៀត។[9] ការបិទទ្វារសាលារៀនចំនួន ១.៣០០០ទីតាំង បានបង្កផលប៉ះពាល់ដល់សិស្សប្រមាណ ៣២២.១០៣នាក់ ដោយក្នុងនោះ ប្រមាណ៩០% ពុំមានលទ្ធភាពទទួលបានសេវាអប់រំឡើយ[10] ដែលទំនងបង្កើនហានិភ័យ ដល់ក្មេងស្រីបោះបង់ចោលការសិក្សាកាន់តែច្រើនឡើង។ មូលដ្ឋានផ្តល់សេវាសុខភាពយ៉ាងហោច ៥១កន្លែង ក៏ត្រូវបានបិទទ្វារផងដែរគិតត្រឹមៗ៣ក់កណ្តាលខែធ្នូ[11] ហើយតួលេខនេះទំនងជាអាចនឹងកើនឡើងនៅប៉ុន្មានសប្តាហ៍ក្រោយមកទៀត នៅពេលដែលការប្រយុទ្ធគ្នាចេះតែបន្ត។



5 World Bank (2022) "The Gender Dimensions of Forced Displacement: A Synthesis of New Research", online: https://documents.worldbank.org/en/publication/documents-reports/documentdetail/895601643214591612/the-gender-dimensions-of-forced-displacement-a-synthesis-of-new-research.

6 Humanitarian Response Forum, "Situation Report 2: Cambodia-Thailand Border Situation", August 8, 2025, online: https://reliefweb.int/report/cambodia/humanitarian-response-forum-hrf-situation-report-2-cambodia-thailand-border-situation-8-august-2025.

7 Humanitarian Response Forum, "Situation Report 12: Cambodia-Thailand Border Situation", December 27, 2025, online: https://reliefweb.int/report/cambodia/humanitarian-response-forum-hrf-situation-report-12-cambodia-thailand-border-situation-27-december-2025.

8 Humanitarian Response Forum, "Situation Report 11: Cambodia-Thailand Border Situation", December 12, 2025, online: https://reliefweb.int/report/cambodia/humanitarian-response-forum-hrf-situation-report-11-cambodia-thailand-border-situation-12-december-2025.

9 World Health Organization, "Public Health Situation Analysis (PHSA)", August 19, 2025, online: https://cdn.who.int/media/docs/default-source/2021-dha-docs/phsa-cambodia-190825.pdf?sfvrsn=526877e2_1&download=true.

10 Humanitarian Response Forum, above n 8.

11 Ibid.

ជារឿយៗ ទីកន្លែងតាំងទីលំនៅថ្មី ខ្វះគ្រឿងបរិក្ខារដែលបែងចែកតាមយេនឌ័រងាយស្រួលសម្រាប់កុមារ និងងាយស្រួលចូលទៅប្រើប្រាស់។ ភាពចង្អៀតណែន ដោយសារមានក្រុមគ្រួសារប្រជាពលរដ្ឋច្រើនគេងរួមគ្នា ធ្វើឱ្យឯកជនភាពមានតិចតួចនោះ បានបង្កើនហានិភ័យនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ។[12] សារព័ត៌មាន ខេមបូចា បានចងក្រងឯកសារអំពីហេតុការណ៍នៃការបៀតបៀនផ្លូវភេទទៅលើស្ត្រី និងក្មេងស្រីនៅទីកន្លែងតាំងទីលំនៅមួយកន្លែងក្នុងខេត្តព្រះវិហារ ក្នុងខែកក្កដា។[13] បង្គន់ និងកន្លែងងូតទឹកខ្វះភាពឯកជន និងសន្តិសុខមិនគ្រប់គ្រាន់ ដោយក្នុងនោះជនភៀសខ្លួនមកដល់ឃើញបង្គន់គ្មានទ្វារ។ របងឫស្សីដែលមិនរឹងមាំគ្រប់គ្រាន់ ត្រូវបានដំឡើងនៅពេលក្រោយប៉ុណ្ណោះ។ ក្នុងនោះដែរ មនុស្សប្រុស និងស្ត្រីប្រើប្រាស់បន្ទប់ទឹករួមគ្នា ដោយមានការរាយការណ៍ថាបុរសងូតទឹកនៅជិតស្ត្រី និងក្មេងស្រី។ អ្នកខ្លះបានរាយការណ៍ថា មានការសំឡឹងមើលទាំងមិនពេញចិត្ត និងត្រូវបានប៉ះស្ទាប ឬចតរូបដោយគ្មានការព្រមព្រៀងនោះទេ។ កង្វះលំហសុវត្ថិភាពបានធ្វើឱ្យស្ត្រី និងក្មេងស្រីមួយចំនួនស្ទាក់ស្ទើរក្នុងការងូតទឹក ឬប្រើប្រាស់បង្គន់ ជាពិសេសពេលគ្មានអ្នកទៅជាមួយ។

អង្គការ ទស្សនៈពិភពលោកកម្ពុជា បានធ្វើការវាយតម្លៃសុវត្ថិភាពផ្លូវចិត្តរហ័សមួយនៅចុងខែកក្កដា ឆ្នាំ២០២៥[14] ដោយសារការផ្លាស់ទីលំនៅថ្មីដោយបង្ខំ ការបំបែកគ្នា និងការបាត់បង់សមាជិកគ្រួសារ ការស្តាប់លឺសំឡេងផ្ទុះ និងការបាត់បង់មុខរបរ និងលទ្ធភាពទទួលបានតម្រូវការចាំបាច់ បានបង្កហានិភ័យផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ។ ការវាយតម្លៃនោះ បានសម្ភាសន៍មនុស្សចំនួន ២៧៤នាក់ រួមមានស្ត្រីចំនួន ១១៨នាក់ និងក្មេងស្រីចំនួន ៣៧នាក់ នៅតាមទីកន្លែងតាំងលំនៅថ្មីចំនួន ៤៣កន្លែង។ ក្នុងចំណោមអ្នកឆ្លើយតបទាំងនោះ មានពីរភាគបី (៦៦%) បានរាយការណ៍ថាមានអារម្មណ៍តក់ស្លុតជាខ្លាំងទាក់ទងនឹងការជម្លៀស ការបាត់បង់សមាជិកគ្រួសារ ឬការមើលឃើញការបាញ់ប្រហារ ឬការទម្លាក់គ្រាប់បែកជាដើម។ ជាង៣ក់កណ្តាល (៥២%) បានរាយការណ៍ពីអារម្មណ៍ភ័យខ្លាច និងកំហឹងជាខ្លាំង រួមទាំងបំណងសងសឹកផងដែរ។ មានតែ ៣៥% ប៉ុណ្ណោះដែលយល់ដឹងថាត្រូវស្វែងរកជំនួយនៅទីណា ដោយភាគច្រើនបានលើកឡើងយកសាច់ញាតិជាប្រភពជំនួយចម្បងរបស់ខ្លួន។ កុមារត្រូវបានរាយការណ៍ថា ត្រូវការការអប់រំ និងប្រដាប់លេងជាបន្ទាន់បំផុត ចំណែកឯមនុស្សពេញវ័យបានកំណត់ថា អាហារមូលដ្ឋាន តង់ ពួក សាប៊ូ និងការទទួលបានសេវាថែទាំសុខភាពជាប់លាប់ ជាតម្រូវការបន្ទាន់បំផុតរបស់ខ្លួន។ ភាពតានតឹងផ្លូវចិត្ត និងរបួសផ្លូវចិត្តទំនងជាកើនឡើងកាន់តែខ្លាំងឡើងគួរឱ្យកត់សម្គាល់ ក្នុងអំឡុងពេលមានការប្រយុទ្ធគ្នាខ្លាំងសារជាថ្មី និងការជម្លៀសប្រជាជនទ្រង់ទ្រាយធំនៅក្នុងខែធ្នូ។

ទោះបីជាមនុស្សភាគច្រើនអាចវិលត្រឡប់មកផ្ទះវិញនៅក្នុងខែសីហា ឆ្នាំ២០២៥ និងវិលមកវិញជាថ្មីម្តងទៀតចាប់ពីខែមករា ឆ្នាំ២០២៦ ក៏ដោយ ប៉ុន្តែមនុស្សជាច្រើនដែលបានវិលត្រឡប់មកផ្ទះវិញនៅតែបន្តប្រឈមមុខនឹងហានិភ័យធំៗ រួមមានអសន្តិសុខតាមព្រំដែនដែលកំពុងបន្តកើតមាន យុទ្ធភណ្ឌមិនទាន់ផ្ទុះ ការខូចខាតលំនៅដ្ឋាន និងហេដ្ឋារចនាសម្ព័ន្ធស៊ីវិល និងភាពរអាក់រអួលនៃការផ្តល់សេវានៅតែបន្តកើតមាន។[15] តំបន់ជាច្រើនកន្លែងដែលមានពលរដ្ឋកម្ពុជារស់នៅ បានបន្តស្ថិតនៅក្រោមការគ្រប់គ្រងរបស់ថៃ បន្ទាប់ពីមានបទឈប់បាញ់កាលពីខែធ្នូ ដែលធ្វើឱ្យភូមិទាំងមូលមិនអាចឱ្យគេវិលត្រឡប់ទៅវិញបាន។ រូបភាពផ្កាយរណបបង្ហាញថា ផ្ទះសម្បែង និងសំណង់នានានៅក្នុងតំបន់ ដែលគ្រប់គ្រងដោយថៃត្រូវបានបំផ្លាញចោលបន្ទាប់ពីមានបទឈប់បាញ់។[16]

ការជម្លៀសប្រជាជនទ្រង់ទ្រាយធំនេះ ក៏បានរំខានយ៉ាងធ្ងន់ធ្ងរដល់ជីវភាពរស់នៅ ពាណិជ្ជកម្ម និងទេសចរណ៍ផងដែរ ដែលធ្វើឱ្យសម្ពាធសេដ្ឋកិច្ចកាន់តែធ្ងន់ធ្ងរឡើងថែមទៀតសម្រាប់ប្រជាជនជាច្រើន។ សម្ពាធទាំងនេះមានសភាពធ្ងន់ធ្ងរស្រាប់ទៅហើយ ដោយសារបំណុលពីមីក្រូហិរញ្ញវត្ថុ ដែលកំណត់យកអត្រាការប្រាក់ខ្ពស់ពីប្រជាជនកម្ពុជា និងការធ្លាក់ចុះយ៉ាងគំហុកនៃប្រាក់បញ្ជី បន្ទាប់ពីពលករចំណាកស្រុកកម្ពុជាវិលត្រលប់មកពីប្រទេសថៃវិញ។

12 World Health Organization, about n 9; Humanitarian Response Forum, about n 6.

13 Phon Sothyroth and Pa Tongchen, “Young Girls, Women Sexually Harassed At Preah Vihear War Shelter”, September 23, 2025, CamboJA News, online: https://cambojanews.com/young-girls-women-sexually-harassed-at-preah-vihear-war-shelter/.

14 World Vision Cambodia (2025) “Psychological Safety Assessment Report: Internally Displaced People”, online: https://www.wvi.org/sites/default/files/2025-08/Psychological%20Safety%20Assessment%20Report%208%20August%202025%20FINAL.pdf.

15 Humanitarian Response Forum, above n 6.

16 LICADHO, “Post-Ceasefire Razing of Cambodian Villages Likely Violates International Law”, January 20, 2026, online: https://www.licadho-cambodia.org/articles/20260120/205/index.html.

១.២ ពលករចំណាកស្រុកដែលបានវិលត្រលប់

ពលករចំណាកស្រុកកម្ពុជា
ចំនួន ១.១ លាននាក់រស់នៅប្រទេសថៃ

↓

៩១០,០០០នាក់ បានត្រឡប់មក
កម្ពុជាវិញ

↓

ការបាត់បង់ប្រាក់ចំណូល
និងប្រាក់ផ្ញើពីក្រៅប្រទេស

↓

មានតែការងារចំនួន ១៩០,០០០ កន្លែង
ប៉ុណ្ណោះដែលអាចរកបាន

↓

តម្រូវការសម្រាប់ជីវភាពរស់នៅ
ប្រកបដោយចីរភាព

ពលករចំណាកស្រុកកម្ពុជាមួយចំនួនធំដែលរស់នៅ និងធ្វើការនៅក្នុងប្រទេសថៃ បានវិលត្រឡប់មកប្រទេសកម្ពុជាវិញយ៉ាងប្រញ៉ាប់នៅពេលដែលភាពតានតឹងផ្នែកនយោបាយ និងយោធាបានកើនឡើងចាប់ពីខែឧសភា ឆ្នាំ២០២៥ មក។ ពលករចំណាកស្រុកកម្ពុជាប្រមាណ ៩១០,០០០នាក់ ក្នុងចំណោមប្រជាជនកម្ពុជាប្រមាណ ១,១លាននាក់ ដែលរស់នៅក្នុងប្រទេសថៃ បានសម្រុកវិលត្រឡប់មកកម្ពុជាវិញ ក្នុងរយៈពេលប៉ុន្មានសប្តាហ៍ប៉ុណ្ណោះ ដោយសារមកពីការភ័យខ្លាចពីការរើសអើង ការបៀតបៀន ការចាប់ខ្លួន អំពើហិង្សា សម្ពាធគ្រួសារ និងការបិទព្រំដែន ដែលមិនអាចស្មានទុកមុនបាន។ ការវិលត្រលប់យ៉ាងតក់ក្រហល់បែបនេះ បានធ្វើឱ្យពលករចំណាកស្រុកខាតបង់ប្រាក់ចំណូល និងប្រាក់សន្សំរបស់ខ្លួនកាត់បន្ថយប្រាក់បញ្ជើមកកម្ពុជា និងបង្កើនសម្ពាធលើសេវាសំខាន់ៗ រួមទាំងសេវាសុខភាព ការអប់រំ និងលំនៅដ្ឋាន។[17] ប្រាក់បញ្ជើពីប្រទេសថៃមកកម្ពុជា មានទំហំសរុបប្រមាណជិត ៣៣ន់លានដុល្លារ កាលពីឆ្នាំ ២០២៤ ហើយការធ្លាក់ចុះនៃប្រាក់បញ្ជើនេះបានឆ្លុះបញ្ចាំងឱ្យឃើញពីផលប៉ះពាល់ធំធេង។[18]

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរាយការណ៍ថា មានការងារប្រហែល ១៩០,០០០កន្លែង សម្រាប់ពលករចំណាកស្រុកដែលវិលត្រឡប់មកធ្វើការវិញ ដែលតាគច្រើនស្ថិតនៅក្នុងវិស័យផលិតកម្ម និងសេវាកម្ម។ ទោះជាយ៉ាងណា វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) បានរកឃើញថា ឱកាសការងារទាំងនេះភាគច្រើនមានទីតាំងស្ថិតនៅឆ្ងាយពីខេត្តកំណើតរបស់ពលករចំណាកស្រុក ហើយមិនស្របតាមជំនាញ និងបទពិសោធន៍របស់ពួកគាត់ឡើយ។[19]

មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (មជ្ឈមណ្ឌល សង់ត្រាល់) ក្នុងខែសីហា ឆ្នាំ២០២៥ បានធ្វើការវាយតម្លៃផ្នែកតម្រូវការរបស់ពលករចំណាកស្រុក ដែលបានវិលត្រឡប់មកវិញជាង ៨០០នាក់ ដែលក្នុងនោះជាង៣ក់កណ្តាលជាស្ត្រី។ ការវាយតម្លៃបានរកឃើញថា ពលករចំណាកស្រុកភាគច្រើនបានវិលត្រឡប់ទៅខេត្តឆ្ងាយជាប់ព្រំដែនវិញ ហើយត្រូវការស្បៀងអាហារ និងឱកាសរកប្រាក់ចំណូល។ ស្ត្រីជាច្រើន - ដែលធ្លាប់ធ្វើការជាអ្នកបម្រើតាមផ្ទះ អ្នកចៃទាំ ឬក្នុងវិស័យកែច្នៃអាហារសមុទ្រនៅប្រទេសថៃ - មិនមានជំនាញស្របតាមទីផ្សារការងារបច្ចុប្បន្នរបស់ប្រទេសកម្ពុជាទេ។ ជាក់ស្តែង ស្ត្រីពលករចំណាកស្រុកដែលបានវិលត្រលប់មកវិញមួយរូប បានប្រាប់អង្គការឃ្លាំមើលសិទ្ធិមនុស្ស (HRW) ថាគាត់បានព្យាយាមរកការងារធ្វើនៅរោងចក្រកាត់ដេរមួយកន្លែង ប៉ុន្តែមិនត្រូវបានទទួលយក ដោយសារតែខ្វះបទពិសោធន៍គោល។[21] បើទោះបីជារងសម្ពាធបែបនេះក្តី អ្នកចូលរួមជាច្រើនបានប្រាប់ទៅមជ្ឈមណ្ឌលសង់ត្រាល់ថា ពួកគាត់មិនមានបំណងវិលទៅប្រទេសថៃវិញនោះទេ ដែលក្នុងនោះមានស្ត្រីច្រើនជាងបុរស ដែលទំនងជាមានគម្រោងបន្តរស់នៅក្នុងប្រទេសកម្ពុជាបន្តទៅទៀត ប្រសិនបើពួកគាត់អាចស្វែងរកការងារសមរម្យ និងមានសុវត្ថិភាព។

សេចក្តីថ្លែងការណ៍រួមមួយ ពីសំណាក់អង្គការសង្គមស៊ីវិលចំនួន ១៨ បានគូសបញ្ជាក់ពីភាពចាំបាច់ត្រូវមានវិធានការគ្រប់ជ្រុងជ្រោយ និងចំគោលដៅ ដើម្បីធានាថា ស្ត្រីទទួលបានឱកាសរកប្រាក់ចំណូលប្រកបដោយចីរភាព និងដើម្បីកាត់បន្ថយសម្ពាធដែលបង្ខំឱ្យពួកគាត់ចំណាកស្រុក តាមមធ្យោបាយមិនមានសុវត្ថិភាព ឬមិនទៀងទាត់ ជាពិសេសនៅពេលដែលព្រំដែនគោកនៅតែបន្តបិទពេញមួយឆ្នាំ។[21]

17 Cambodia Development Resource Institute (CDRI), "Navigating the Economic Transition of Cambodia's Returning Workforce: Suggested Policy Approaches", August 2025, online: https://cdri.org.kh/storage/pdf/RPN_Final_1756201887.pdf; World Vision International, "Situation Report #16: Displacement Crisis as a Result of the Cambodia-Thailand Border Conflict", August 26, 2025, online: https://www.wvi.org/sites/default/files/2025-08/World%20Vision_16th%20Sitrep_Cambodia%20Border%20Displacement_26th%20August_0.pdf.

18 Joint Statement, "Strengthen Services, Protections for Returned Migrant Workers", October 7, 2025, online: https://ngocedaw.org/wp-content/uploads/2025/10/Eng-FINAL_Labour_JointStatement_EN_061025.pdf.

19 Cambodia Development Resource Institute (CDRI), "Demographic and Economic Profile of Returned Migrant Labourers", August 2025, online: https://cdri.org.kh/storage/pdf/RPN2_v2_1757326478.pdf.

20 Human Rights Watch, "Cambodia: Returned Migrant Workers Face Hunger, Joblessness", November 25, 2025, online: https://www.hrw.org/news/2025/11/25/cambodia-returned-migrant-workers-face-hunger-joblessness.

21 Joint Statement, above n 18.

០២.

ស្ត្រី សន្តិភាព និងសន្តិសុខ

របៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (WPS) ត្រូវបានបង្កើតឡើងដោយសេចក្តីសម្រេចលេខ ១៣២៥ របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ និងរៀបចំឡើងវិញជុំវិញគោលការណ៍ដែលផ្តោតសំខាន់លើ ការបង្ការ កិច្ចគាំពារ ការសង្គ្រោះ និងការស្តារឡើងវិញ និងការចូលរួម ហើយរបៀបវារៈនេះមានសារៈសំខាន់យ៉ាងយូរមកហើយ សម្រាប់ការកសាង និងការរក្សាសន្តិភាពនៅក្នុងប្រទេសកម្ពុជា។ សារៈសំខាន់នៃរបៀបវារៈនេះ បានលេចឡើងកាន់តែច្បាស់ក្នុងអំឡុងពេលជម្លោះព្រំដែនឆ្នាំ២០២៥។ គណៈកម្មាធិការ ស៊ី-ដ បានផ្តល់អនុសាសន៍ក្នុង ឆ្នាំ២០១៩ ឱ្យកម្ពុជាអនុម័តផែនការសកម្មភាពជាតិ គ្រប់ជ្រុងជ្រោយមួយសម្រាប់ការអនុវត្តរបៀបវារៈនេះ ហើយធានាថា ស្ត្រីបានចូលរួមយ៉ាងពេញលេញនៅគ្រប់ដំណាក់កាលនៃការកសាងសន្តិភាព ការបង្ការជម្លោះ និងការដោះស្រាយជម្លោះ។[22]

កម្ពុជាបានដើរតួនាទីយ៉ាងសកម្មក្នុងការជំរុញរបៀបវារៈ “ស្ត្រី សន្តិភាព និងសន្តិសុខ” នេះ នៅក្នុងតំបន់អាស៊ាន។[23] កម្ពុជាបានរួមចំណែកយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍផែនការសកម្មភាពតំបន់អាស៊ានស្តីពី ស្ត្រី សន្តិភាព និងសន្តិសុខ ដែលបានអនុម័តនៅ ឆ្នាំ២០២២ ក៏ដូចជាយន្តការបំពេញបន្ថែម “កញ្ចប់ឧបករណ៍ និងគោលការណ៍ណែនាំសម្រាប់មូលដ្ឋានីយកម្ម”។ ទោះជាយ៉ាងណា ប្រទេសកម្ពុជាមិនទាន់បានបង្កើត ឬអនុម័តផែនការសកម្មភាពជាតិនៅឡើយទេគិតត្រឹមឆ្នាំ ២០២៥។

របាយការណ៍វិភាគស្ថានភាពស្តីពី ស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា បោះពុម្ពផ្សាយដោយក្រសួងកិច្ចការនារី និងអង្គការសហប្រជាជាតិសម្រាប់ស្ត្រី ក្នុងខែតុលា ឆ្នាំ២០២៥ បានកំណត់បញ្ហាសន្តិសុខធំៗនៅកម្ពុជា គូសផែនទីគោលនយោបាយ និងយន្តការដែលមានស្រាប់ ឆ្លុះបញ្ចាំងពីមេរៀនដែលទទួលបាន និងស្នើឡើងនូវជំហានបន្ទាប់ សម្រាប់ការបង្កើតផែនការសកម្មភាពជាតិ។[24] ជាមួយនឹងអនុសាសន៍ទាំងឡាយនោះ ការវិភាគបានណែនាំថា កម្ពុជាត្រូវបង្កើតបន្ទាត់ពេលវេលាច្បាស់លាស់សម្រាប់បង្កើតផែនការសកម្មភាពជាតិ។

22 CEDAW Committee, above n 1, para. 13(a)-(b).

23 Women Peace Makers (2025) “Foundations of Women, Peace & Security: Lessons and Opportunities for Transformative Peace in Cambodia”, online: https://wpmcambodia.org/project/foundations-of-women-peace-security/.

24 UN Women and Ministry of Women’s Affairs, “Situation Analysis Report on Women, Peace and Security in Cambodia”, October 2025, online: https://asiapacific.unwomen.org/sites/default/files/2025-11/kh-20250438381-situation-analysis-report-on-wps-in-cambodia_en-s.pdf

ការស្រាវជ្រាវមួយ ដែលធ្វើឡើងដោយអង្គការនារីដើម្បីសន្តិភាព (WPM) ក៏បានរកឃើញផងដែរថា ទំហំការងារថែទាំដែលពុំមានប្រាក់ឈ្នួល ត្រូវបានវ៉ាប់រងដោយស្ត្រីកម្ពុជា ដោយមិនមានសមាម្រាត គឺជាកត្តាដ៏ចម្បងមួយដែលជំរុញឱ្យខ្វះតំណាងស្ត្រីនៅក្នុងតួនាទីស្វែងរកសន្តិភាព និងសន្តិសុខ។[25] ជាមធ្យម ស្ត្រីកម្ពុជាវ៉ាប់រងរហូតដល់ទៅជាង ៩០% នៃការងារថែទាំគ្មានប្រាក់ឈ្នួល[26] ហើយទំនួលខុសត្រូវទាំងនេះ ទំនងជាកើនឡើងក្នុងអំឡុងពេលមានជម្លោះ ឬវិបត្តិ។ អង្គការនារីដើម្បីសន្តិភាព (WPM) បានរកឃើញថា បន្ទុកការងារថែទាំទាំងនេះ គួបផ្សំនឹងក្រិតក្រមយេនឌ័រតឹងរ៉ឹងផង ធ្វើឱ្យប៉ះពាល់ដល់ស្ត្រីក្នុងការចូលរួមពេញលេញ និងប្រកបដោយអត្ថន័យក្នុងការងារសន្តិភាព និងសន្តិសុខ រួមទាំងប៉ះពាល់ដល់សមត្ថភាពរបស់ពួកគាត់ ក្នុងការចាប់យកតួនាទីការងារសន្តិសុខ និងតំណែងជាអ្នកដឹកនាំផងដែរ ដែលការងារទាំងនេះ អាចទាមទារឱ្យមានម៉ោងធ្វើការមិនទៀងទាត់ ឬការចាត់តាំងទៅធ្វើការឆ្ងាយពីផ្ទះផងដែរ។

ផែនការសកម្មភាពជាតិនៅតែមានសារៈសំខាន់ដើម្បីធានាបានថា ស្ត្រីមានការចូលរួមពេញលេញ និងប្រកបដោយអត្ថន័យ ក្នុងគ្រប់ដំណាក់កាលនៃរបៀបវារៈស្តីពី ស្ត្រី សន្តិភាព និងសន្តិសុខ (WPS)។

បើទោះបីជាកម្ពុជា បានបង្ហាញឱ្យឃើញពីភាពនាំមុខគេក្នុងការគាំទ្រការចូលរួមរបស់ស្ត្រី ក្នុងបេសកកម្មរក្សាសន្តិភាពក្តី ប៉ុន្តែស្ត្រីនៅតែមានតំណាងតិចតួចណាស់នៅក្នុងមុខតំណែងដឹកនាំ។ កងកម្លាំងរក្សាសន្តិភាពចំនួន ៩.១៩៧នាក់ ដែលកម្ពុជាបានបញ្ជូនឱ្យចូលរួមបេសកកម្មរវាងពី ឆ្នាំ២០០៦ ដល់ខែកុម្ភៈ ឆ្នាំ២០២៤[27] មានស្ត្រីចំនួន ៨% ហើយស្ត្រីមានចំនួន ១៧% នៃកងកម្លាំងរក្សាសន្តិភាពរបស់កម្ពុជាគិតត្រឹម ឆ្នាំ២០២៤។[28] ចំនួននេះ គឺច្រើនជាងគោលដៅជាសកលរបស់អង្គការសហប្រជាជាតិ ដែលកំណត់ឱ្យស្ត្រីមានចំនួន ១៥% នៅក្នុងជួរកងកម្លាំងយោធានៅ ឆ្នាំ២០២៨។[29] ទោះជាបែបនេះក្តី ស្ត្រីកម្ពុជាដែលកាន់តំណែងជាអ្នកដឹកនាំមានត្រឹមតែ ១៣% ប៉ុណ្ណោះគិតត្រឹម ឆ្នាំ២០២៣។[30] ផែនការសកម្មភាពជាតិនៅតែមានសារៈសំខាន់ដើម្បីធានាបានថា ស្ត្រីមានការចូលរួមពេញលេញ និងប្រកបដោយអត្ថន័យ ក្នុងគ្រប់ដំណាក់កាលនៃរបៀបវារៈស្តីពី ស្ត្រី សន្តិភាព និងសន្តិសុខ (WPS)។

25 Women Peace Makers (2025) “Peace, Gender & Care in Cambodia”, online: https://wpmcambodia.org/project/peace-gender-and-care-in-cambodia/.

26 ILO (2018) “Care Work and Care Jobs for the Future of Decent Work”, online: https://www.ilo.org/publications/major-publications/care-work-and-care-jobs-future-decent-work.

27 Royal Cambodian Armed Forces (RCAF) and the National Center for Peacekeeping Force, Mine and ERW Clearance (NPMEC), “2023 Report on Results of the Measuring Opportunities for Women in Peace Operations (MOWIP) Assessment”, online: https://elsiefund.org/wp-content/uploads/2024/08/kh-c1062-mowip-assessement-report_royal_cambodian_armed-en.pdf.

28 Ministry of Women’s Affairs, “Cambodia National Report on the occasion of the Thirtieth Anniversary of the Fourth World Conference on Women and the adoption of the Beijing Declaration and Platform for Action (1995)”, June 2024, online: https://www.unwomen.org/sites/default/files/2024-09/b30_report_cambodia_en.pdf.

29 UN Department of Peace Operations, “Uniformed Gender Parity Strategy 2018 – 2028”, online: https://peacekeeping.un.org/sites/default/files/uniformed-gender-parity-2018-2028.pdf.

30 RCAF and NPMEC, above n 27.

០៣.

ភាពមិនមានសញ្ជាតិ

ភាពគ្មានសញ្ជាតិ គំរាមកំហែងដល់សិទ្ធិជាច្រើនរបស់ស្ត្រី ក្មេងស្រី និងអ្នកមិនកំណត់អត្តសញ្ញាណភេទស្រី ឬប្រុស ដែលសិទ្ធិទាំងនោះត្រូវបានការពារក្រោមអនុសញ្ញា ស៊ី-ដ ក្នុងនោះរួមមាន សិទ្ធិមានសញ្ជាតិ សិទ្ធិចូលរួមក្នុងជីវិតនយោបាយ និងសាធារណៈសិទ្ធិទទួលបានការអប់រំ ការងារ ការថែទាំសុខភាព និងលំនៅដ្ឋាន។ គណៈកម្មាធិការ ស៊ី-ដ បានផ្តល់អនុសាសន៍ឱ្យ ប្រទេសកម្ពុជាធានាថា គ្រប់ស្ត្រី និងក្មេងស្រីជនជាតិភាគតិចដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ជាពិសេសស្ត្រី និងក្មេងស្រីដើមកំណើតរៀតណាម និងកម្ពុជាក្រោមអាចទទួលបានសញ្ជាតិ កម្ពុជា ហើយផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិទាំងពីរដែលទាក់ទងនឹងភាពគ្មានសញ្ជាតិ។[31]

ផ្ទុយទៅវិញ ប្រទេសកម្ពុជាបានអនុម័តលើវិសោធនកម្មយ៉ាងឆាប់រហ័ស ចំពោះរដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីសញ្ជាតិក្នុង ឆ្នាំ២០២៥ ដែលអនុញ្ញាតឱ្យគេអាចដកហូតសញ្ជាតិពលរដ្ឋកម្ពុជាបាន និងធ្វើឱ្យពួកគាត់អាចក្លាយជាជនគ្មានសញ្ជាតិ។ ខណៈភាពតានតឹងតាមព្រំដែនមានការកើនឡើង ប្រធានព្រឹទ្ធសភា លោក ហ៊ុន សែន ក្នុងខែមិថុនា ឆ្នាំ២០២៥ បានអំពាវនាវឱ្យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ពិចារណាធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ដើម្បីអនុញ្ញាតឱ្យមានការដកហូតសញ្ជាតិកម្ពុជាពីពលរដ្ឋបាន។ មាត្រា ៣៣ នៃរដ្ឋធម្មនុញ្ញត្រូវបានធ្វើវិសោធនកម្មយ៉ាងប្រញាប់ប្រញាល់នៅខែបន្ទាប់ ដោយលុបចោលការហាមឃាត់ចំពោះការដកហូតសញ្ជាតិរបស់ពលរដ្ឋ។ ការកែប្រែនេះ បានបើកផ្លូវសម្រាប់វិសោធនកម្មច្បាប់ស្តីពីសញ្ជាតិរបស់កម្ពុជា ដែលត្រូវបានព្រៀង អនុម័ត និងចុះហត្ថលេខាយ៉ាងប្រញ៉ាប់ប្រញ៉ាល់នៅក្នុងខែកញ្ញា ឆ្នាំ២០២៥ ដោយពុំមានការពិគ្រោះយោបល់ ជាសាធារណៈឡើយ។[32] វិសោធនកម្មនេះបានប្រកាសចូលចូលជាធរមាន នៅខែមករា ឆ្នាំ២០២៦ តាមរយៈអនុក្រឹត្យមួយច្បាប់ ចុះកាលបរិច្ឆេទ ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៥។[33]

មាត្រា ២៩ ថ្មីនៃច្បាប់ស្តីពីសញ្ជាតិកំណត់ អំពីមូលដ្ឋានសម្រាប់ការដកហូតសញ្ជាតិ រួមមានការឆ្លើយតបទៅនឹងបុគ្គលដែលប្រព្រឹត្តអំពើក្បត់ជាតិ ឬអំពើដែលប៉ះពាល់ដល់អធិបតេយ្យភាពជាតិ បូរណភាពទឹកដី ឬសន្តិសុខជាតិ ការយុបយិតជាមួយជនបរទេស ឬការត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬបទល្មើសមជ្ឈិមទាក់ទងនឹងការបំពានព្រះមហាក្សត្រ សន្តិសុខរដ្ឋ ឬអំពើភេរវកម្ម។ បទប្បញ្ញត្តិដែលមានលក្ខណៈទូលំទូលាយ និងមិនច្បាស់លាស់ទាំងនេះខ្ទះស្តង់ដារច្បាស់លាស់ទាក់ទិននឹងភាពចាំបាច់សមាមាត្រ និងភាពអាចព្យាករណ៍បាន ហើយមិនបានជួយការពារប្រឆាំងនឹងការរើសអើងឡើយ។

---

31 CEDAW Committee, above n 1, para. 13(a)-(c).

32 Joint Statement, "Repeal the Nationality Law Amendments: How Revoking Cambodian Nationality Fails to Meet International Standards", September 9, 2025, online: https://ngocedaw.org/wp-content/uploads/2025/09/Final_-JointStatementOnNationalityLaw-_EN.pdf.

33 Sub-Decree No. 225 on the Implementation of Law on Nationality, 1 December 2025, online: https://data.opendevelopmentcambodia.net/laws_record/sub-decree-no-225-on-the-implementation-of-law-on-nationality.

វិសោធនកម្មទាំងនេះ ក៏មិនបានផ្តល់ការការពារគ្រប់គ្រាន់ប្រឆាំងនឹងភាពគ្មានសញ្ជាតិនោះដែរ។ សញ្ជាតិអាចត្រូវបានលុបចោលក្នុងករណី ដែល "មានមូលដ្ឋានគួរឱ្យទុកចិត្តបាន ដែលនាំឱ្យជឿថាជនជាតិកម្ពុជារូបនោះអាចទទួលបានសញ្ជាតិ ឬការការពារពីរដ្ឋបរទេសមួយផ្សេងទៀត"។ ពុំមានការកំណត់និយមន័យថាតើអ្វីទៅ ដែលជា "មូលដ្ឋានគួរឱ្យទុកចិត្តដែលនាំឱ្យជឿ" ថាមនុស្សម្នាក់ អាចទទួលបានសញ្ជាតិមួយផ្សេងទៀតនោះទេ ដែលត្រង់នេះបានទុកឱ្យមានចន្លោះចំហសម្រាប់ការបកស្រាយទូលំទូលាយ និងមានលក្ខណៈអត្តនោម័ត។

វិសោធនកម្មទាំងនេះប្រឈមនឹងការប្រើខុស ដើម្បីផ្តោតលើស្ត្រីជាអ្នកការពារសិទ្ធិមនុស្ស និងធ្វើឱ្យប៉ះពាល់ដល់សិទ្ធិមានសេរីភាពក្នុងការបង្កើតសមាគម ការជួបជុំ និងការបញ្ចេញមតិ របស់ស្ត្រី ក្មេងស្រី និងមិនកំណត់អត្តសញ្ញាណភេទស្រី ឬប្រុស។ ក្រុមអង្គការសង្គមស៊ីវិលចំនួន ៥០ បានជំទាស់នឹងការវិសោធនកម្មនេះ ដោយលើកឡើងពីការភ័យខ្លាចថា ច្បាប់ថ្មីនេះអាចត្រូវបានប្រើប្រាស់ខុស ដើម្បីបំបិទសំឡេងអ្នករិះគន់ និងផលប៉ះពាល់ទៅលើសេរីភាពជាមូលដ្ឋាន នៅក្នុងបរិបទ ដែលសកម្មជន គូប្រជែងផ្នែកនយោបាយ និងសំឡេងរិះគន់ផ្សេងទៀតកាន់តែច្រើនត្រូវបានកាត់ទោសពីទោសក្បត់ជាតិ ក្រោមការចោទប្រកាន់ពីបទរួមគំនិតក្បត់ និងប្រមាថព្រះមហាក្សត្រ ជាដើម។[34]

អង្គការឃ្លាំមើលសិទ្ធិមនុស្ស (HRW) បានដាក់ឈ្មោះវិសោធនកម្មទាំងនេះថា "ជាឧបករណ៍ដ៏គ្រោះថ្នាក់ដើម្បីបំបិទសំឡេងប្រឆាំង" ដោយមិនខ្វល់ពីការប្តេជ្ញាចិត្តជាអន្តរជាតិរបស់កម្ពុជា ក្នុងការគោរពសិទ្ធិមនុស្ស។[35] អង្គការលើកលែងទោសអន្តរជាតិ បានសម្តែងការព្រួយបារម្ភថារដ្ឋាភិបាលកម្ពុជានឹង "ប្រើប្រាស់ [វិសោធនកម្ម] ខុស ដើម្បីបង្ក្រាបអ្នករិះគន់របស់ខ្លួន និងធ្វើឱ្យពួកគាត់គ្មានសញ្ជាតិ"។[36]

34 Joint Statement, "Drop Amendments to Nationality Law, Don't Strip Citizenship of Cambodians", August 24, 2025, online: https://ngocedaw.org/wp-content/uploads/2025/08/ENG-Joint-Statement-Drop-Amend-nationality-law.pdf.

35 Human Rights Watch, "Cambodia: Revised Law Endangers Citizenship" September 1, 2025, online: https://www.hrw.org/news/2025/09/01/cambodia-revised-law-endangers-citizenship.

36 Amnesty International, "Cambodia: Revocation of citizenship would be heinous violation of international law", July 11, 2025, online: https://www.amnesty.org/en/latest/news/2025/07/cambodia-revocation-of-citizenship-would-be-heinous-violation-of-international-law/.

០៤.

ស្ត្រីក្នុងភាពជាអ្នកដឹកនាំ

ស្ត្រីនៅតែមានតំណាងតិចជាខ្លាំង ក្នុងមុខតំណែងដឹកនាំទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនៅក្នុងប្រទេសកម្ពុជា។ នៅក្នុងអំឡុងឆមាសទីមួយនៃ ឆ្នាំ២០២៥ ស្ត្រីមានចំនួនតែ ៨% ក្នុងតួនាទីជាអភិបាលខេត្ត (មានស្ត្រីចំនួន ២រូប ក្នុងចំណោម ២៥រូប នៅក្នុងតួនាទី) នៅខេត្តកោះកុង និងប៉ៃលិន); ១៣% ក្នុងតួនាទីជាអភិបាលរងខេត្ត (មានស្ត្រីចំនួន ៣២រូប ក្នុងចំណោម ២៤៨រូប); ៣% ក្នុងតួនាទីជា អភិបាលក្រុង ស្រុក ខណ្ឌ (មានស្ត្រីចំនួន ៦រូប ក្នុងចំណោម ២០៩រូប); និង ២០,៥% ក្នុងតួនាទីជា អភិបាលរងក្រុង ស្រុក ខណ្ឌ (មានស្ត្រីចំនួន ២៤៩រូប ក្នុងចំណោម ១.២១៤រូប)។[37] លោកស្រី មិថុនា ភូថង អភិបាលខេត្តកោះកុងដែលចេញពីតំណែង ត្រូវបានតំឡើងតួនាទីជារដ្ឋលេខាធិការនៅក្រសួងកិច្ចការនារីក្នុង ឆ្នាំ២០២៥ ហើយលោកស្រី ឈី រ៉ា ត្រូវបានតែងតាំងជាអភិបាលខេត្តថ្មី។

វឌ្ឍនភាពដ៏មានអត្ថន័យ ឆ្ពោះទៅរកការចូលរួមស្មើភាពគ្នារបស់ស្ត្រីនៅក្នុងជីវិតនយោបាយ និងសាធារណៈ ទាមទារឱ្យមានវិធានការពិសេសបណ្តោះអាសន្នរឹងមាំជាងមុន រួមមានការកំណត់កូតាសម្រាប់តួនាទីជាអ្នកដឹកនាំ តាមការផ្តល់អនុសាសន៍ពីគណៈកម្មាធិការ ស៊ី-ដ។[38]

ក្នុងតួនាទីជាអភិបាលខេត្តមានស្ត្រីចំនួន
២រូប ក្នុងចំណោម ២៥រូប

ក្នុងតួនាទីជាអភិបាលរងខេត្តមានស្ត្រីចំនួន
៣២រូប ក្នុងចំណោម ២៤៨រូប

ក្នុងតួនាទីជា អភិបាលក្រុង ស្រុក ខណ្ឌមានស្ត្រីចំនួន
៦រូប ក្នុងចំណោម ២០៩រូប

ក្នុងតួនាទីជា អភិបាលរងក្រុង ស្រុក ខណ្ឌ មានស្ត្រីចំនួន
២៤៩រូប ក្នុងចំណោម ១.២១៤រូប

37 Information provided by COMFREL.

38 CEDAW Committee, above n 1, para. 31(a).

០៥.

សេរីភាពមូលដ្ឋាន និងលំហស៊ីវិល

ក្នុងឆ្នាំ២០២៥ ប្រទេសកម្ពុជានៅតែបន្តគាបសង្កត់ ដូចបានធ្វើជាយូរមកហើយ ទៅលើស្ត្រីជាអ្នកការពារសិទ្ធិមនុស្ស គូប្រជែងនយោបាយ សហជីពកម្មករ អ្នកការពារដីធ្លី និងបរិស្ថាន អ្នកសារព័ត៌មាន និងប្រជាពលរដ្ឋដែលបញ្ចេញមតិជំទាស់។ ទោះបីជាគណៈកម្មាធិការស៊ី-ដ បានផ្តល់អនុសាសន៍ឱ្យមានការធានាពេញលេញ ឱ្យពួកគាត់មានសិទ្ធិសេរីភាព ក្នុងការបញ្ចេញមតិ ការជួបជុំគ្នា និងការបង្កើតសមាគម ដោយគ្មានការរឹតត្បិតហួសហេតុក៏ដោយ[39] ប៉ុន្តែប្រជាពលរដ្ឋក្រុមទាំងនេះបានប្រឈមមុខនឹងការឃ្លាំមើល ការគំរាមកំហែង និងការដាក់ពន្ធនាគារថែមទៀតផង។

ការចោទប្រកាន់ពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបង្ករភាពរឹករវៃដល់សន្តិសុខសង្គម និងការរួមគំនិតក្បត់ ក្រោមមាត្រា ៤៩៤, ៤៩៥ និង ៤៥៣ នៃក្រមព្រហ្មទណ្ឌនៅតែបន្តយកមកប្រើប្រាស់ ដើម្បីចោទប្រកាន់តាមអំពើចិត្ត ចំពោះអ្នកដែលនិយាយជំទាស់។ គិតត្រឹមខែធ្នូ ឆ្នាំ២០២៥ យ៉ាងហោចណាស់មានស្ត្រីចំនួន ១៨នាក់ បានជាប់ពន្ធនាគារ ដោយសារតែការបញ្ចេញមតិ សកម្មនិយម ឬការចូលរួមនយោបាយ។[40]



39 Ibid, para. 19.

40 LICADHO, "Cambodia's Prisoners of Interest", online: https://www.licadho-cambodia.org/prisoners_of_interest/ [as of December 2025].

៥.១ សកម្មនិយមនយោបាយ

លំហសម្រាប់សកម្មនិយមនយោបាយ នៅតែមានការរិតត្បិតខ្លាំងដដែលនៅ ឆ្នាំ២០២៥ ដោយក្នុងនោះតួអង្គប្រឆាំងប្រឈមមុខនឹងការសងសឹកជាប្រព័ន្ធចំពោះកិច្ចខិតខំប្រឹងប្រែងដើម្បីរៀបចំសកម្មភាពរបស់ខ្លួន។ សកម្មជនន យោបាយ អ្នកនាង សេង ធារី បានធ្វើកូដកម្មអត់អាហារនៅក្នុងពន្ធនាគារក្នុងខែមិថុនា ឆ្នាំ២០២៥។[41] កូដកម្មអត់អាហារនេះ គឺជាកូដកម្មលើកទីបួនហើយ ចាប់តាំងពីអ្នកនាងត្រូវបានឃុំក្នុងពន្ធនាគារនៅខែមិថុនា ឆ្នាំ២០២២ និងដើម្បីប្រារព្ធខួបលើកទី៣ នៃការឃុំខ្លួនរបស់នាងផង។ តាមរយៈសកម្មភាពនេះ អ្នកនាង បានព្យាយាមទាក់ទាញការចាប់អារម្មណ៍ទៅលើកាដាប់ឃុំរបស់អ្នកនាង ហើយបានអំពាវនាវ ឱ្យមានការដោះលែងសកម្មជនន យោបាយ និងអ្នកការពារសិទ្ធិមនុស្សទាំងអស់ ដែលជាប់ឃុំដោយអយុត្តិធម៌នៅក្នុងប្រទេសកម្ពុជា។

អ្នកនាង សេង ធារី កំពុងអនុវត្តទោសក្នុងពន្ធនាការឃុំ បន្ទាប់ពីត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេលប្រាំមួយឆ្នាំ ក្នុងដំណើរការកាត់ក្តីទ្រង់ទ្រាយធំមួយ ដែលពាក់ព័ន្ធនឹងសកម្មជនប្រឆាំងជាច្រើនរាប់សិបនាក់ផ្សេងទៀត។ លោកស្រីបានបញ្ចប់កូដកម្មអត់អាហារដោយសារបញ្ហាសុខភាព បន្ទាប់ពីធ្វើកូដកម្មអស់រយៈពេលប្រាំបួនថ្ងៃ។[42] ស្ត្រីជាសកម្មជនន យោបាយផ្សេងទៀត រួមមាន អ៊ុក យ៉ីម, អូយ ឌីណា, សឿន គន្ធា, សែម សុផល និង ញ៉ៅ សារ៉ុ ក៏បានជាប់ពន្ធនាគារក្នុង ឆ្នាំ២០២៥ ផងដែរ។[43]

៥.២ សកម្មនិយមបរិស្ថាន

សកម្មជនបរិស្ថានចំនួន ប្រាំនាក់ មកពីអង្គការមាតាធម្មជាតិកម្ពុជា រួមទាំងស្ត្រីជាសកម្មជន ឡុង គន្ធា និង ភួន កែវរស្មី បានបន្តជាប់ពន្ធនាគារពេញមួយឆ្នាំ។ មួយឆ្នាំមុនជាប់ពន្ធនាគារ ពួកគាត់ត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារពីប្រាំមួយ ទៅប្រាំបីឆ្នាំ។ សាលាឧទ្ធរណ៍ក្រុងភ្នំពេញ និងតុលាការកំពូលបានបដិសេធសំណើសុំនៅក្រៅឃុំរបស់ពួកគាត់ ដោយរង់ចាំការប្តឹងឧទ្ធរណ៍នៅក្នុងខែកុម្ភៈ និងខែមេសារៀងៗខ្លួន។[44]

នៅក្នុងខែឧសភា ឆ្នាំ២០២៥ មន្ត្រីជំនាញរបស់អង្គការសហប្រជាជាតិមួយក្រុម តាមរយៈសារទៅកាន់រដ្ឋាភិបាលកម្ពុជា បានសម្តែងការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការចាប់ខ្លួនសកម្មជនទាំងនោះ ដោយសារតែពួកគាត់មានការងារជាអ្នកការពារសិទ្ធិមនុស្សផ្នែកបរិស្ថាន និងការអនុវត្តសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិរបស់ខ្លួន។ មន្ត្រីជំនាញទាំងនោះបានថ្លែងថា ការឃុំខ្លួននេះ គឺធ្វើឡើងតាមអំពើចិត្ត ហើយបុគ្គលទាំងនោះ “ហាក់ដូចជាត្រូវបានកំណត់ជាគោលដៅ ពីព្រោះពួកគាត់ជាសមាជិកនៃចលនាមាតាធម្មជាតិកម្ពុជា ដែលជាក់ស្តែងទង្វើនេះជាការរំលោភសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម”។[45]

---

41 Perseus Strategies, “U.S.-Cambodian Political Prisoner Theary Seng Launches Hunger Strike to Mark Third Anniversary of Wrongful Detention in Cambodia”, June 2, 2025, online: https://perseus-strategies.com/wp-content/uploads/FINAL-Press-Release_Theary-Seng_Hunger-Strike-June-2025-1.pdf; Joint Statement, “Seng Theary’s Hunger Strike Highlights Plight of Unjustly Imprisoned”, June 11, 2025, online: https://www.licadho-cambodia.org/pressrelease.php?perm=541.

42 Khuon Narim, “Imprisoned Activist Seng Theary Halts Hunger Strike, Her Fourth Since 2022”, CamboJA News, June 11, 2025, online: https://cambojanews.com/imprisoned-activist-seng-theary-halts-hunger-strike-her-fourth-since-2022/.

43 LICADHO, above n 40.

44 LICADHO, “Mother Nature Activists Denied Bail; Youth Leaders Face Extended Detention”, February 18, 2025, online: https://www.licadho-cambodia.org/flashnews.php?perm=435; LICADHO, “Supreme Court Denies Bail of Mother Nature Activists”, April 30, 2025, online: https://www.licadho-cambodia.org/flashnews.php?perm=441.

45 Special Rapporteur on the situation of human rights in Cambodia; the Working Group on Arbitrary Detention; the Special Rapporteur on the promotion and protection of the right to freedom of opinion and expression; the Special Rapporteur on the rights to freedom of peaceful assembly and of association; the Special Rapporteur on the situation of human rights defenders; the Special Rapporteur on the independence of judges and lawyers and the Working Group on discrimination against women and girls, AL KHM 3/2025, May 22, 2025, online: https://spcommreports.ohchr.org/TMResultsBase/DownLoadPublicCommunicationFile?gId=29950.

នៅឱកាសខួបនៃការចាប់ខ្លួនពួកគាត់ក្នុងខែកក្កដា ឆ្នាំ២០២៥ អង្គការសង្គមស៊ីវិល និងសហគមន៍ចំនួន ៥១ បានអំពាវនាវសាជាថ្មីឱ្យមានការដោះលែងពួកគាត់ជាបន្ទាន់ និងទម្លាក់រាល់បទចោទប្រកាន់ទាំងអស់មកលើរូបគេ។[46]

៥.៣ សហជីពកម្មករ

លំហសម្រាប់ការរៀបចំសហជីព នៅតែត្រូវបានគាបសង្កត់យ៉ាងខ្លាំងនៅ ឆ្នាំ២០២៥ ដោយក្នុងនោះទម្លាប់បំបែកសហជីពនៅតែបន្ត។ សមាជិកសហជីពជាស្ត្រី បានរាយការណ៍ពីឧបសគ្គទាក់ទងនឹងយេនឌ័រ ចំពោះការបោះជំហានឆ្ពោះទៅរកតួនាទីជាអ្នកដឹកនាំនៅក្នុងសហជីព សូម្បីតែនៅក្នុងឧស្សាហកម្ម ដែលគ្របដណ្ដប់ដោយស្ត្រី ដូចជាវិស័យកាត់ដេរសម្លៀកបំពាក ស្បែកជើង និងផលិតផលធ្វើដំណើរក៏ដោយ។ ស្ត្រីជាសមាជិកសហជីព បានរាយការណ៍តាមរឿងរ៉ាវថា មានការរំពឹងថាឱ្យពួកគាត់ត្រូវបន្តនៅដល់យប់ជ្រៅដើម្បីរៀបចំ ឬទទួលទានគ្រឿងស្រវឹង ដែលបញ្ហានេះត្រូវបានយល់ឃើញថាជាឧបសគ្គចំពោះការចូលរួមរបស់ពួកគាត់ និងបង្កើនភាពតានតឹងក្នុងគ្រួសាររបស់ពួកគាត់ផងដែរ។

សមាជិករបស់ សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនណាហ្គាវើលដ៍ (LRSU) នៅតែបន្តធ្វើបាតុកម្មពេញមួយឆ្នាំ ២០២៥។ ២ឆ្នាំបន្ទាប់ពីបាតុកម្មបានចាប់ផ្តើម សមាជិកសហជីពទាំងនោះ បានបន្តទាមទារឱ្យមានដំណោះស្រាយដោយយុត្តិធម៌ ចំពោះវិវាទការងាររបស់ខ្លួន ទោះបីជាមានការបៀតបៀនឥតឈប់ឈរ និងគ្រប់សព្វសារពើក្តី។[47]

៥.៤ សេរីភាពសារព័ត៌មាន និងស្ត្រីនៅក្នុងវិស័យសារព័ត៌មាន

ស្ត្រីនៅតែមានចំនួនតិចតួចក្នុងចំណោមអ្នកសារព័ត៌មាន និងអ្នកប្រកបវិជ្ជាជីវៈក្នុងប្រព័ន្ធផ្សព្វផ្សាយនៅ ឆ្នាំ២០២៥ ហើយនៅតែបន្តប្រឈមមុខនឹងការរើសអើងយេនឌ័រ និងការបៀតបៀនដែលធ្វើឱ្យប៉ះពាល់ដល់ដំណើរការប្រជាធិបតេយ្យ និងសិទ្ធិទទួលបានព័ត៌មាន។ ក្រសួងព័ត៌មានបានរាយការណ៍ថា ក្នុងចំណោមអ្នកសារព័ត៌មានប្រហែល ១០.០០០នាក់ នៅកម្ពុជា មានតែ ៨៦១នាក់ ប៉ុណ្ណោះជាស្ត្រី បើគិតត្រឹមចុង ឆ្នាំ២០២៤។[48]

ខេមបូចា បានចងក្រងករណីសិក្សាមកលើអ្នកសារព័ត៌មានចំនួន ៦១ករណី នៅក្នុងឆ្នាំ២០២៥ ដែលបានប៉ះពាល់អ្នកសារព័ត៌មានចំនួន ៥៧រូប ក្នុងនោះមានស្ត្រីចំនួន ៥រូប។[49] ក្នុងខណៈដែលផលប៉ះពាល់ពាល់លើអ្នកសារព័ត៌មានស្ត្រី មានចំនួនតិចជាងមុន នេះមិនបង្ហាញថាស្ត្រីមានការប៉ះពាល់តិចជាងមុនចំពោះការរំលោភបំពាននោះទេ។ ផ្ទុយទៅវិញវាឆ្លុះបញ្ចាំងពីកង្វះតំណាងស្ត្រីក្នុងវិស័យសារព័ត៌មាន និងឧបសគ្គក្នុងការរាយការណ៍ពីឧប្បត្តិហេតុនៃការយាយី និងរំលោភបំពានទាក់ទងនឹងយេនឌ័រ។

46 Joint Statement, "An Ongoing Shame: Mother Nature Convictions, One Year On", July 2, 2025, online: https://ngocedaw.org/wp-content/uploads/2025/07/02072025_Final_MN-Statement_EN.pdf.

47 Joint Statement, "Four Years of Strikes at NagaWorld: "We Unite the Nation Beginning with Resolving the Dispute at NagaWorld", January 13, 2026, online: https://ngocedaw.org/wp-content/uploads/2026/01/EN_JS-Four-Years-of-Strikes-at-NagaWorld.pdf.

48 **សើ ដាវី**, "**កម្ពុជាមានអ្នកសារព័ត៌មានប្រមាណ ១ម៉ឺននាក់កំពុងបម្រើការក្នុងស្ថាប័នសារព័ត៌មានជាង ១ពាន់កន្លែង**", RFI, 2025, online: https://tinyurl.com/32bw9x3t.

49 CamboJA, "Cambodian Journalism Situation Report 2025", online: https://www.camboja.net/wp-content/uploads/2026/04/Cambodian-Journalism-Situation-Report-2025-Final.pdf

អ្នករាយការណ៍ព័ត៌មានចាត់បង់ការងារបន្ទាប់ពីរាយការណ៍ពីការបំពានផ្លូវភេទ

ខេមបូចា បានចងក្រងករណីបំពានផ្លូវភេទមួយ ដែលកើតឡើងនៅកន្លែងធ្វើការ មកលើអ្នកសារព័ត៌មានជាស្ត្រីម្នាក់ ដែលធ្វើការឱ្យកាសែតក្នុងស្រុកមួយ។ អ្នករាយការណ៍ព័ត៌មាននេះ បានរាយការណ៍ពីការបំពានផ្លូវភេទមកលើរូបនាងទាំង៣ក្យសម្តី និងរាងកាយដោយអ្នកគ្រប់គ្រងរបស់នាង ដោយរួមទាំងការអត្តាធិបាយផ្លូវភេទមិនសមរម្យ និងការប៉ះ៣ល់រាងកាយដោយមិនមានការអនុញ្ញាតិ។ បន្ទាប់ពីនាងរាយការណ៍ហេតុការណ៍នេះទៅកាន់អ្នកគ្រប់គ្រង និងការិយាល័យធនធានមនុស្ស នាងត្រូវបានស្តីបន្ទោសពីអ្វីដែលកើតមានឡើង ហើយប្រាប់ឱ្យដឹងថាមិនមានសក្តភាពអ្វីធ្វើឡើងនោះទេ ដោយសារមកពីនាងមិនបានដាក់បណ្តឹងជាលាយលក្ខណ៍ជាផ្លូវការភ្លាមៗ។ អ្នករាយការណ៍ព័ត៌មាននេះបានឱ្យដឹងថា នៅក្នុងក្រុមហ៊ុននេះមិនមានគផលនយោបាយការពារ ឬយន្តការបណ្តឹងដែលពាក់ព័ន្ធនឹងការបំពានផ្លូវភេទនោះទេ។

ដោយសារមានពាក្យបណ្តឹងរបស់នាង ជនដែលត្រូវចោទដំបូងឡើយបានដាក់ពាក្យលាឈប់ បើទោះជាក្រោយមកបានដកពាក្យនេះវិញក៏ដោយ។ អ្នករាយការណ៍ព័ត៌មានបានឱ្យដឹងថា នាងទទួលរងនូវជំងឺថប់បារម្ភ និងមិនអាចគេងលក់ ដោយស្ថានភាពដែលកើតមានចំពោះរូបនាង។ ដោយមិនមានការពន្យល់ហេតុផល ក្រុមហ៊ុនបានផ្អាកការងារនាងរយៈពេល១ខែ ដោយមិនទទួលប្រាក់កម្រៃ សម្រាប់ការចោទប្រកាន់ថានាង បានប្រព្រឹត្តកំហុសធ្ងន់ធ្ងរ។ នៅខែបន្ទាប់មក កុងត្រាការងាររបស់នាងត្រូវបានបញ្ចប់ ដោយមិនមានការជូនដំណឹងជាមុន ឬពន្យល់ឱ្យបានច្បាស់ឡើយ។ មិនមានសកម្មភាពណា ដែលត្រូវបានដឹងបានធ្វើឡើងប្រឆាំងនឹងជនត្រូវចោទនោះទេ។

របាយការណ៍មួយរបស់មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM) ឯកសារអំពីការរើសអើងយេនឌ័រនៅក្នុងវិស័យប្រព័ន្ធផ្សព្វផ្សាយ រួមទាំងកង្វះស្ត្រីក្នុងតួនាទីជាអ្នកដឹកនាំ ទម្លាប់តំឡើងតួនាទីបែបរើសអើង និងការចាត់ចែងស្ត្រីឱ្យធ្វើប្រធានបទ “ស្រាលៗ” និងចាត់តាំងបុរសឱ្យធ្វើសេចក្តីរាយការណ៍បែបស៊ើបអង្កេត។[50] អ្នកសារព័ត៌មានស្ត្រីបានរៀបរាប់ពីការឱ្យតម្លៃទាបលើវិជ្ជាជីវៈនេះ និងពីសង្គម ការព្រួយបារម្ភអំពីសុវត្ថិភាពទាក់ទងនឹងការចោទសួរពីសំណាក់អាជ្ញាធរ ការធ្វើការនៅតំបន់ដាច់ស្រយាល និងឧបសគ្គក្នុងការទទួលបានបណ្ណសារព័ត៌មាន និងការបៀតបៀនយេនឌ័រ និងការរំលោភបំពានដោយ៣ក្យសម្តីទាំងតាមអ៊ីនធឺណិត និងនៅខាងក្រៅ។ ការព្រួយបារម្ភរបស់គ្រួសារអំពីសុវត្ថិភាពរបស់ស្ត្រី ជាការរារាំងមួយកម្រិតបន្ថែមទៀត ចំពោះចំនួនស្ត្រីដែលចូល និងបន្តប្រកបវិជ្ជាជីវៈនេះ។

50 Cambodian Center for Independent Media (CCIM), “Challenges for Independent Media Report 2024”, online: https://ccimcambodia.org/?page_id=6232.

អ្នកសារព័ត៌មានត្រូវបានណែនាំឱ្យដោះក្រម៉ាហ៊ីចាប នៅឯក្រសួងមួយរបស់រដ្ឋាភិបាល

ខេមបូចា បានចងក្រងករណីមួយដែល ស្ត្រីអ្នកសារព័ត៌មានមួយរូប ដែលបម្រើការងារឱ្យស្ថានីយ៍ទូរទស្សន៍ក្នុងស្រុកមួយបានប្រាប់ថា គាត់ត្រូវបានបដិសេធ មិនឱ្យចូលទៅក្នុងក្រសួងមួយរបស់រដ្ឋាភិបាលក្នុងទីក្រុងភ្នំពេញ ដោយសារតែសម្លៀកបំពាក់បែបសាសនារបស់គាត់។ នៅពេលដែលគាត់មកដល់ ដើម្បីយកព័ត៌មានក្នុងកម្មវិធីមួយ សន្តិសុខម្នាក់បានទាមទារឱ្យគាត់ដោះក្រម៉ាហ៊ីចាបចេញ។ គាត់បានពន្យល់ថាការពាក់ក្រម៉ាហ៊ីចាប គឺជាលក្ខខណ្ឌតម្រូវក្នុងជំនឿសាសនារបស់គាត់ ប៉ុន្តែសន្តិសុខនៅតែមិនអនុញ្ញាតឱ្យគាត់ចូលទេ លុះត្រាតែគាត់ព្រមដោះចេញ។ គាត់បានថ្លែងតាមរយៈសេចក្តីថ្លែងការណ៍មួយថា៖ “ហេតុការណ៍នេះឆ្លុះបញ្ចាំងពីកង្វះការយល់ដឹង និងការយោគយល់ចំពោះទម្លាប់អនុវត្តក្នុងសាសនាអ៊ីស្លាម”។ ស្ត្រីអ្នកកាសែតរូបនោះបានរៀបរាប់នាអំពីបទពិសោធន៍នេះ ថាជាការរើសអើង ហើយបានអំពាវនាវឱ្យមានការយល់ដឹងខ្លាំងជាងមុន និងការគោរពចំពោះភាពចម្រុះខាងសាសនាជាពិសេសនៅក្នុងបណ្តាស្ថាប័នសាធារណៈ។[51]

អ្នកសារព័ត៌មានពលរដ្ឋរងការបៀតបៀនផ្លូវភេទពេលចុះយកព័ត៌មាន

មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM) បានចងក្រងជាឯកសារថា ស្ត្រីជាអ្នកសារព័ត៌មានពលរដ្ឋមួយរូបរងការបៀតបៀនផ្លូវភេទ អំឡុងពេលចុះយកព័ត៌មានកាលពីខែកញ្ញា ឆ្នាំ២០២៥។ ស្ត្រីរូបនោះបានធ្វើដំណើរប្រមាណ ៣០គីឡូម៉ែត្រ ពីផ្ទះដើម្បីចុះទៅសម្ភាស។ នៅពេលទៅដល់លំនៅដ្ឋានរបស់ប្រភព មានបុរសម្នាក់បានមកជិតគាត់ ហើយប្រព្រឹត្តអំពើមិនសមរម្យ។ គាត់បានដាក់ពាក្យបណ្តឹងនៅអាជ្ញាធរឃុំ ប៉ុន្តែអាជ្ញាធរ មិនអាចកំណត់អត្តសញ្ញាណជនល្មើស ឬនាំជនល្មើសឱ្យមកទទួលខុសត្រូវនោះទេ។[52]

បរិយាកាសនៃវិស័យប្រព័ន្ធផ្សព្វផ្សាយជារួម នៅតែត្រូវបានរឹតត្បិតយ៉ាងខ្លាំងបន្ទាប់ពីមានការបង្ក្រាបដោយរដ្ឋាភិបាលអស់រយៈពេលជាច្រើនឆ្នាំមក។ ប្រទេសកម្ពុជាស្ថិតនៅលេខរៀងទី ១៦១ ក្នុងចំណោមប្រទេសចំនួន ១៨០ នៅក្នុងសន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោក ឆ្នាំ២០២៥ របស់អង្គការអ្នកកាសែតគ្មានព្រំដែន ដែលជាការធ្លាក់ចុះ ១០លេខរៀង បើធៀបនឹងចំណាត់ថ្នាក់កាលពីឆ្នាំមុន។[53] អ្នកសារព័ត៌មានដែលរាយការណ៍អំពីប្រធានបទនានា ដូចជាបញ្ហាដីធ្លី និងបរិស្ថាន អភិបាលកិច្ចមូលដ្ឋាន និងជម្លោះព្រំដែនកម្ពុជា-ថៃ បានប្រឈមមុខនឹងការបៀតបានតាមផ្លូវច្បាប់ ដោយក្នុងនោះការអនុវត្តបទចោទប្រកាន់ពីបទញុះញង់ និងបរិហារកេរ្តិ៍ជាការបង្អាក់ដល់ការរាយការណ៍បែបរិះគន់។

51 Information provided by CamboJA.

52 Information provided by CCIM.

53 Reporters Without Borders, “2025 World Press Freedom Index”, online: https://rsf.org/en/country/cambodia.

កម្ពុជាស្ថិតនៅចំណាត់ថ្នាក់ទី ១៦១ ក្នុងចំណោម ១៨០ប្រទេស លើសេរីភាពសារព័ត៌មានក្នុងឆ្នាំ ២០២៥ ដោយធ្លាក់ចុះ ១០ ចំណាត់ថ្នាក់ក្នុងរយៈពេលត្រឹមតែមួយឆ្នាំ។

របាយការណ៍ របស់មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM) បានរកឃើញថា សារព័ត៌មានជាទម្រង់បោះពុម្ព និងអនឡាញបានប្រឈមមុខនឹងសម្ពាធធ្ងរច្បាប់ និងហិរញ្ញវត្ថុកាន់តែខ្លាំងឡើង ខណៈដែលប្រព័ន្ធផ្សព្វផ្សាយសោតទស្សន៍នៅតែស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាល។ សារព័ត៌មានពលរដ្ឋ និងអនឡាញបានពង្រីកខ្លួន ខណៈដែលលំហប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណីកាន់តែរួមតូច ដែលនាំមកនូវទាំងអត្ថប្រយោជន៍ផង និងហានិភ័យផង។ ក្នុងចំណោមអ្នកសារព័ត៌មានចំនួន ១០០រូប ដែលត្រូវបានស្ទង់មតិដោយមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM) ក្នុងនោះ ៩១% បានរាយការណ៍ពីការព្រួយបារម្ភជុំវិញសុវត្ថិភាពរបស់ខ្លួន ជាពិសេសទាក់ទងនឹងវិធានការច្បាប់ ការបៀតបៀនដោយពាក្យសម្តី ការឃ្លាំមើល និងអំពើហិង្សាលើរាងកាយ។ ៤៤% បានរាយការណ៍ថា បានជួបប្រទះបញ្ហាសុវត្ថិភាពកាលពីឆ្នាំ ២០២៤ ដែលភាគច្រើនជាប់ទាក់ទងនឹងការរាយការណ៍ពីប្រធានបទ ដែលត្រូវបានចាត់ទុកថារសើប។ អ្នកសារព័ត៌មានភាគច្រើន ដែលត្រូវបានស្ទង់មតិបានរាយការណ៍ថា ទទួលរងផលប៉ះពាល់អវិជ្ជមានលើសុខភាពផ្លូវចិត្តម្តងម្កាល (៥៩%) ឬញឹកញាប់ (៣២%) ដូចជាការថប់បារម្ភ ស្រ្តេស នឿយហត់ និងការធ្លាក់ទឹកចិត្ត។

ហានិភ័យទាំងនេះ កាន់តែមានសភាពខ្លាំងឡើងបន្ទាប់ពីក្រសួងព័ត៌មានបានចេញប្រកាសថ្មីមួយ ស្តីពី “លក្ខណៈគុណវុឌ្ឍិ និងវិជ្ជាជីវៈសារព័ត៌មាន” នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៥ រួមជាមួយនឹងការកែប្រែបន្ថែមចំពោះលក្ខខណ្ឌតម្រូវក្នុងការស្នើសុំបណ្ណសារព័ត៌មាន។ ប្រកាសនេះ បានបានដាក់ចេញនូវលក្ខខណ្ឌតម្រូវយ៉ាងច្រើន និងមានលក្ខណៈជាការរិតត្បិតសម្រាប់ស្ថាប័នព័ត៌មាន អ្នកសារព័ត៌មានឯករាជ្យ អ្នកផលិតមាតិកា និងអ្នកដទៃទៀតខណៈលក្ខខណ្ឌតម្រូវ សម្រាប់ស្នើសុំបណ្ណសារព័ត៌មានបានធ្វើឱ្យប៉ះពាល់រឹតតែខ្លាំងថែមទៀត លើការទទួលបានឯកសារប្រភេទនេះ។ សេចក្ដីថ្លែងការណ៍រួមមួយ របស់អង្គការសង្គមស៊ីវិលចំនួន ២១ បានព្រមានថា “វិធានការទាំងនេះនឹងធ្វើឱ្យការរាយការណ៍ព័ត៌មានកាន់តែពិបាក កាន់តែមានគ្រោះថ្នាក់ និងរឹតត្បិតរឹតតែខ្លាំងថែមទៀត លើវិស័យសារព័ត៌មាន ដែលកំពុងមានភាពផុយស្រួយស្រាប់ទៅហើយ”។[54]

ក្នុងចំណោមអ្នកសារព័ត៌មានចំនួន ១០០រូប ដែលត្រូវបានស្ទង់មតិដោយ CCIM

៩១%
បានរាយការណ៍ពីការព្រួយបារម្ភជុំវិញសុវត្ថិភាពរបស់ខ្លួន

៤៤%
បានរាយការណ៍ថាបានជួបប្រទះបញ្ហាសុវត្ថិភាពកាលពីឆ្នាំ ២០២៤

៩១%
បានជួបប្រទះផលប៉ះពាល់អវិជ្ជមានដល់សុខភាពផ្លូវចិត្ត
៥៩% ជាប្រចាំម្តងម្កាល | ៣២% ជាញឹកញាប់

54 Joint Statement, “New Prakas Lacks Consultation, Further Restricts Media Freedom”, December 15, 2025, online: https://ngocedaw.org/wp-content/uploads/2025/12/Final-EN_Statement-on-Cambodia-New-Media-Regulations.pdf

០៦. ការរំលោភយកដីធ្លី និងការបណ្តេញចេញដោយបង្ខំ

ការរំលោភយកដីធ្លី និងការបណ្តេញចេញដោយបង្ខំ បានបន្តប៉ះពាល់ខ្លាំងចំពោះស្ត្រីនៅទូទាំងប្រទេសកម្ពុជាក្នុង ឆ្នាំ២០២៥។ សម្បទានដីសេដ្ឋកិច្ចយូរអង្វែង រួមជាមួយនឹងការចែកដីធ្លីថ្មីៗ បាននាំឱ្យមានការកើនឡើងទាំងជម្លោះថ្មី និងជម្លោះដែលរ៉ាំរ៉ៃ។ យ៉ាងហោចណាស់ ជម្លោះដីធ្លីបានប៉ះពាល់ដល់សហគមន៍នានា នៅក្នុងខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ឆ្នាំង កំពង់ស្ពឺ កណ្តាល កែប កោះកុង ក្រចេះ ឧត្តរមានជ័យ ភ្នំពេញ ព្រះសីហនុ ព្រះវិហារ ពោធិ៍សាត់ សៀមរាប និងស្ទឹងត្រែង។ អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ) បានចងក្រងឯកសារ ដោយបង្ហាញថា យ៉ាងហោចណាស់មានប្រជាពលរដ្ឋចំនួន ៥.០៧០គ្រួសារ បានរងផលប៉ះពាល់ថ្មី ក្នុងចំណោម ៨៧ករណី ក្នុងអំឡុងឆ្នាំនោះ។

នៅខេត្តព្រះសីហនុ ប្រជាពលរដ្ឋចំនួន ៣៣៩គ្រួសារ មកពីសហគមន៍ព្រៃឈើអ្នកតាថ្មព្រង់កំពុងមានជម្លោះ ជាមួយក្រុមហ៊ុនមី នើ រ៉ា អ៊ិនវេសមិន ឯ.ក. (Mi Ner Va Investment Co. Ltd.) ជុំវិញដីធ្លីទំហំ ៩១ហិកតា ដែលស្ថិតនៅក្នុងព្រៃសហគមន៍ដែលទទួលស្គាល់ជាផ្លូវការ។[55] ជម្លោះនេះបានកើនកម្តៅឡើងនៅក្នុងខែកុម្ភៈ ឆ្នាំ២០២៥ នៅពេលដែលក្រុមហ៊ុនចាប់ផ្តើមឈូសឆាយដីដើម្បីអភិវឌ្ឍន៍កន្លែងចាក់សំរាម។ ទោះបីព្រៃនោះជាព្រៃការពារក្តី ប៉ុន្តែតាមរបាយការណ៍ ប័ណ្ណកម្មសិទ្ធិដីធ្លីដែលត្រួតស៊ីគ្នាជាមួយតំបន់ព្រៃនោះ ត្រូវបានចេញដោយអាជ្ញាធរហើយលក់ទៅឱ្យក្រុមហ៊ុន។

នៅខេត្តព្រះវិហារ សមាជិកសហគមន៍ជនជាតិដើមភាគតិចគួយ បានស្នុះស្ទែងការពារដីដូនតានិងដីសហគមន៍របស់ខ្លួន ដែលប្រើប្រាស់សម្រាប់ធ្វើកសិកម្មបង្ងិល ដែលពួកគាត់អះអាងថាត្រូវបានឈូសឆាយដោយក្រុមហ៊ុន សាន់តាណា អាហ្ក្រូ ប្រូដាក់ ឯ.ក (Santana Agro Product Co. Ltd.)។[56] ភាពតានតឹងបានកើនឡើងក្នុងខែមករា ឆ្នាំ២០២៥ នៅពេលមានការប៉ះទង្គិចគ្នារវាងសមាជិកសហគមន៍ និងកម្មករកសិកម្មរបស់ក្រុមហ៊ុន។[57]

គម្រោងអភិវឌ្ឍន៍នានា បានបន្តបង្កហានិភ័យដល់សហគមន៍ដែលមានវត្តមានយូរលង់ណាស់មកហើយ។ នៅក្នុងខេត្តកណ្តាល ប្រជាពលរដ្ឋប្រមាណ ៤០០គ្រួសារ ដែលរស់នៅលើដីរបស់ខ្លួនអស់ជាច្រើនទសវត្សរ៍មកហើយនោះ បានប្រឈមមុខនឹងការបាត់បង់មុខរបរ ទីកជ័ន្ធ និងហានិភ័យនៃការបណ្តេញចេញដោយបង្ខំ នៅពេលដែលបឹងមួយកន្លែងត្រូវបានហ៊ុមព័ទ្ធ និងគ្រោងយកទៅអភិវឌ្ឍនៅជិតអាកាសយានដ្ឋានអន្តរជាតិតេជោថ្មី ដែលអភិវឌ្ឍដោយក្រុមហ៊ុនអូស៊ីអាយស៊ី (OCIC)។[58]

55 LICADHO, "Forest Community Petitions Senate President over Land Conflict", May 30, 2025, online: https://www.licadho-cambodia.org/flashnews.php?perm=447.

56 Khuon Narim, "Kuy Indigenous Demand Resolution Over Land Dispute in Preah Vihear", CamboJA News, March 4, 2025, online: https://cambojanews.com/kuy-indigenous-demand-resolution-over-land-dispute-in-preah-vihear/.

57 Sovann Sreypich, "Hundreds of Indigenous People Clash with Developers Over Disputed Farmland", January 31, 2025, online: https://cambojanews.com/hundreds-of-indigenous-people-clash-with-developers-over-disputed-farmland/.

58 Phon Sothyroth, "Seized lakes: How Cambodia's airport boom is breaking a fishing community", HaRDstories , September 10, 2025, online: https://hardstories.org/stories/land-rights/cambodias-new-airport-slowly-destroys-a-rural-community.

នៅទីក្រុងភ្នំពេញ ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោងអភិវឌ្ឍផ្លូវរថភ្លើង ក៏បានដាក់ញត្តិស្នើសុំប័ណ្ណកម្មសិទ្ធិដីធ្លីផងដែរ ដោយសារតែការភ័យខ្លាចពីការបណ្តេញចេញ។[59] អ្នកភូមិមកពីសហគមន៍កោះមាស នៅឆ្នាំ២០២៥ ក៏បានបន្តអំពាវនាវសុំប័ណ្ណកម្មសិទ្ធិដីធ្លីដែលរង់ចាំជាយូរមកហើយ បន្ទាប់ពីដីរបស់ពួកគាត់ត្រូវបានចាត់ថ្នាក់ឡើងវិញថាជាដីឯកជនរបស់រដ្ឋ និងត្រូវបានផ្ទេរទៅឱ្យក្រុមហ៊ុនឯកជនមួយនៅ ឆ្នាំ២០២០។[60]

ទន្ទឹមនឹងជម្លោះដីធ្លីទាំងនេះ ស្ត្រីសកម្មជនដីធ្លីនៅតែបន្តប្រឈមមុខនឹងប្រតិកម្មខ្លាំង និងការបៀតបៀនតាមផ្លូវតុលាការ ដោយសារតែពួកគាត់ព្យាយាមការពារផ្ទះសម្បែង និងមុខរបររបស់ខ្លួន។ នៅឆ្នាំ២០២៤ ស្ត្រីមកពីសហគមន៍សំរោងត្បូង នៅបឹងតាមោក ក្នុងទីក្រុងភ្នំពេញបន្តរងការបៀតបៀនតាមផ្លូវច្បាប់ជាបន្តបន្ទាប់។[61]

គំរូលំនាំគ្នានេះ ក៏ឃើញកើតមាននៅក្នុងខេត្តកោះកុងផងដែរ។ នៅខែមិថុនា ឆ្នាំ២០២៥ តុលាការកំពូលបានបញ្ជាឱ្យបញ្ជូន ដីកាសម្រេចផ្តន្ទាទោសពីបទបរិហារកេរ្តិ៍ ចំពោះសកម្មជនដីធ្លីខេត្តកោះកុង គឺអ្នកស្រី ផារ ញើង និងអ្នកស្រី សេង លីន ត្រឡប់ទៅឱ្យសាលាឧទ្ធរណ៍ខេត្តព្រះសីហនុ ដើម្បីការកាត់ក្តីឡើងវិញ។[62] បទចោទប្រកាន់ គឺតាំងពីខែវិច្ឆិកា ឆ្នាំ២០១៩ នៅពេលដែលស្ត្រីទាំងពីររូបបានចោទប្រកាន់អតីតតំណាងសហគមន៍ម្នាក់ពីបទរឹបអូសដីធ្លី។ នៅខែវិច្ឆិកា ឆ្នាំ២០២៥ សាលាឧទ្ធរណ៍ខេត្តព្រះសីហនុបានជំនុំជម្រះឡើងវិញនូវសំណុំរឿងនេះ និងបានតម្កល់ការផ្តន្ទាទោស ដោយបញ្ជាឱ្យស្ត្រីម្នាក់ៗបង់ប្រាក់ពិន័យចំនួន ១លានរៀល (ប្រហែល ២៥០ដុល្លារអាមេរិក) និងសំណងជំងឺចិត្តចំនួន ២លានរៀល (ប្រហែល ៥០០ដុល្លារអាមេរិក)។[63]

នៅក្នុងសំណុំរឿងដាច់ដោយឡែកមួយទៀត សាលាឧទ្ធរណ៍ខេត្តព្រះសីហនុបានទម្លាក់ការចោទប្រកាន់ពីបទញុះញង់ ចំពោះសកម្មជនដីធ្លីខេត្តកោះកុងចំនួន ១១នាក់ រួមមានស្ត្រីជាសកម្មជនឈ្មោះ ដេត ហួរ, អ៊ិន ធូ, ផារ ញើង, សេង លីន, ស្ងួង ថេង, ទិត តាំង, យី គន្ធា និង យៀត ខ្មៅ។[64] ក្រុមសកម្មជនទាំងនេះត្រូវបានផ្តន្ទាទោសពីបទញុះញង់ កាលពីខែមិថុនា ឆ្នាំ២០២៤ បន្ទាប់ពីបានព្យាយាមធ្វើដំណើរមកទីក្រុងភ្នំពេញ ដើម្បីដាក់ញត្តិទាក់ទងនឹងជម្លោះដីធ្លីដែលកំពុងបន្តកើតមាន ជាមួយក្រុមហ៊ុនមួយដែលមានទំនាក់ទំនងជាមួយឧកញ៉ាម្នាក់។ សកម្មជនចំនួនប្រាំបួននាក់ បានជាប់ឃុំបណ្តោះអាសន្នរយៈពេលពីរខែ ក្នុងឆ្នាំ ២០២៣ ទាក់ទងនឹងបទចោទប្រកាន់ផ្សេងៗដែលចុងក្រោយត្រូវបានទម្លាក់ចោល ។

នៅខែឧសភា ឆ្នាំ២០២៥ សហគមន៍រងផលប៉ះពាល់មួយនៅខេត្តកោះកុងក៏បានដាក់ញត្តិទាក់ទងជម្លោះដីធ្លី ដែលកំពុងកើតមានទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ផងដែរ។[65] នៅខែកញ្ញា សមាជិកសហគមន៍ប្រមាណ ៤០នាក់ ត្រូវបានគណៈបាលមូលដ្ឋានឃាត់ខ្លួន និងសាកសួរនៅពេលកំពុងធ្វើដំណើរទៅទីក្រុងភ្នំពេញ ដើម្បីតាមដានអំពីញត្តិរបស់ពួកគេ ហើយក្រោយមកក៏ត្រូវបានអនុញ្ញាតឱ្យធ្វើដំណើរបន្ត។

59 Sovann Sreypich, "Phnom Penh Residents Push City Hall Again for Land Titles, Road Construction", CamboJA News, June 20, 2025, online: https://cambojanews.com/phnom-penh-residents-push-city-hall-again-for-land-titles-road-construction/.

60 Sovann Sreypich, "Koh Meas Residents Demand Land Titles Amid 50-Year Development Lease", CamboJA News, March 14, 2025, online: https://cambojanews.com/koh-meas-residents-demand-land-titles-amid-50-year-development-lease/.

61 LICADHO, "Charges Dropped Against Koh Kong Land Activists; Boeung Tamok Residents Convicted", July 17, 2025, online: https://www.licadho-cambodia.org/flashnews.php?perm=454; Sovann Sreypich, "Boeung Tamok Residents Accept Compensation, Plead Judge to Quash Criminal Charge During 18-Minute Hearing", CamboJA News, June 27, 2025, online: https://cambojanews.com/boeung-tamok-residents-accept-compensation-plead-judge-to-quash-criminal-charge-during-18-minute-hearing/.

62 LICADHO, "Supreme Court Orders Retrial in Defamation Conviction of Land Activists", June 17, 2025, online: https://www.licadho-cambodia.org/flashnews.php?perm=449.

63 LICADHO, "Appeal Court Upholds Defamation Verdict of Koh Kong Land Activists ", November 19, 2025, online: https://www.licadho-cambodia.org/flashnews.php?perm=476.

64 LICADHO, above n 61.

65 LICADHO, "Koh Kong Community Members, Reps Gather at Land Ministry", September 1, 2025, online: https://www.licadho-cambodia.org/flashnews.php?perm=459.

០៧.

ការប្រែប្រួលអាកាសធាតុ

កម្ពុជាងាយរងគ្រោះខ្លាំង ចំពោះផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ រួមមានការឡើងកម្តៅខ្លាំង គ្រោះរាំងស្ងួត និងទឹកជំនន់។ គណៈកម្មាធិការ ស៊ី-ដ បានផ្តល់អនុសាសន៍ដល់កម្ពុជាត្រូវធានាថា ស្ត្រីបានចូលរួមប្រកបដោយប្រសិទ្ធភាពក្នុងការបង្កើត និងអនុវត្តគោលនយោបាយឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ ហើយគោលនយោបាយទាំងនេះត្រូវបញ្ចូលឱ្យបានច្បាស់ៗនូវទស្សនទានយេនឌ័រ។[66]

ការអង្កេតយេនឌ័រ និងបរិស្ថានរបស់ប្រទេសកម្ពុជាឆ្នាំ ២០២៤ បានរកឃើញថា ៨៧% នៃប្រជាជនរស់នៅក្នុងតំបន់ដែលប្រឈមនឹងហានិភ័យបរិស្ថានខ្ពស់ ទាំងនៅតំបន់ទីក្រុង និងជនបទ ហើយប្រជាជនកម្ពុជាស្ទើរតែទាំងអស់ បានជួបប្រទះនឹងគ្រោះមហន្តរាយយ៉ាងហោចណាស់មួយលើកកាលពីមួយឆ្នាំមុននោះ។[67] ការអង្កេតនោះបានកំណត់ឃើញថា ស្ត្រីកម្ពុជាប្រឈមមុខនឹងផលប៉ះពាល់ខ្លាំងដោយសារគ្រោះមហន្តរាយ រួមមានការថយចុះនៃការទទួលបានសេវាថែទាំសុខភាព និងផលិតផលអនាម័យ ការខូចខាតមុខរបរ ការកើនឡើងនៃបន្ទុកការងារថែទាំគ្មានប្រាក់កម្រៃ ការធ្លាក់ចុះនូវការទទួលបានអាហារ និងអាហារូបត្ថម្ភ និងការកើនឡើងហានិភ័យសុវត្ថិភាពផ្ទាល់ខ្លួន។ ការអង្កេតនោះ ក៏បានរកឃើញផងដែរថា មានប្រជាជនកម្ពុជាតិចតួចណាស់ ដែលចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តជាផ្លូវការទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ឬការគ្រប់គ្រងបរិស្ថាន។ របាយការណ៍មួយរបស់អង្គការយូនីសេហ្ វ បានរាយតម្លៃបន្ថែមទៀតអំពីការជួបប្រទះ និងភាពងាយរងគ្រោះរបស់កុមារចំពោះគ្រោះថ្នាក់អាកាសធាតុ ដោយបានប៉ាន់ប្រមាណថា កុមារចំនួន ១,៩លានទាក់ - ឬប្រហែល ៣៦% នៃចំនួនកុមារទូទាំងប្រទេស - រស់នៅតាមបណ្តាសហគមន៍ដែលមានហានិភ័យអាកាសធាតុខ្ពស់ និងខ្ពស់ខ្លាំង។[68]

កុមារចំនួន
១,៩លានទាក់
រស់នៅតាមបណ្តាសហគមន៍ ដែលមានហានិភ័យ អាកាសធាតុខ្ពស់ និងខ្ពស់ខ្លាំង

៣០% ទៅ ៤០%
នៃប្រាក់ចំណូលរបស់ចម្ការ ម្រេចតូចៗក្នុងខេត្តកំពត និងកែប ត្រូវបានធ្លាក់ចុះ

៨៧%
នៃប្រជាជនរស់នៅក្នុងតំបន់ ដែលប្រឈមនឹងហានិភ័យបរិស្ថានខ្ពស់

66 CEDAW Committee, above n 1, para. 43(a)-(b).

67 National Institute of Statistics (2025) "Cambodia Gender and Environment Survey 2024", online: https://data.unwomen.org/sites/default/files/documents/Publications/2025/cambodia_gender_and_environment_survey_en.pdf.

68 Ministry of Environment and UNICEF Cambodia (2025) "Children's Climate Risk Index for Cambodia", online: https://www.unicef.org/cambodia/reports/childrens-climate-risk-index-cambodia.

មានមនុស្សជាច្រើន ដែលទទួលអារម្មណ៍ថារងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។ អង្គការបន្ទាយស្រី តាមរយៈការសហការជាមួយអង្គការដទៃទៀត បានសម្ភាសម្ចាស់ និងកម្មករចម្ការម្រេចតូចៗក្នុងខេត្តកំពត និងកែប ចំនួន ១៥០នាក់ (ស្ត្រី ៨៩នាក់ និងបុរស ៦១នាក់)។[69] អ្នកឆ្លើយសំណួរបានរាយការណ៍ថា មានអារម្មណ៍ថាពីមួយឆ្នាំទៅមួយឆ្នាំ កាន់តែក្តៅទៅៗ ហើយប្រាក់ចំណូលបានធ្លាក់ចុះពី ៣០% ទៅ ៤០% ក្នុងឆ្នាំ២០២៤ ដោយសារតែផលប៉ះពាល់ពីកម្តៅ។ កម្តៅបានបណ្តាលឱ្យរុក្ខជាតិងាប់ ទិន្នផលថយចុះ គ្រាប់ម្រេចមានគុណភាពទាប និងការកើនឡើងថ្លៃទឹក និងឧបករណ៍បូមទឹក។ ជាលទ្ធផល អ្នកខ្លះខ្វះដើមទុនចាំបាច់ សម្រាប់ផលិតកម្មម្រេចក្នុង ឆ្នាំ២០២៥។ ការវាយតម្លៃបានរកឃើញថា ស្ត្រីរងផលប៉ះពាល់ខ្លាំងដោយមានអត្រាជំងឺប្រចាំកាយខ្ពស់ ការចូលរួមក្នុងកម្លាំងពលកម្មមានប្រាក់ឈ្នួលបានធ្លាក់ចុះ និងអំណាចធ្វើការសម្រេចចិត្ត តិចជាងបុរស។ ឯកសារបោះពុម្ពផ្សាយផ្សេងទៀតក្នុង ឆ្នាំ២០២៥ បានបង្ហាញស្រដៀងគ្នានេះដែរថា ស្ត្រីដែលរស់នៅក្នុងសហគមន៍ឆ្នេរសមុទ្រ ឬធ្វើការនៅតាមរោងចក្រកាត់ដេរ វិស័យសំណង់ កសិកម្ម និងការងារក្រៅប្រព័ន្ធប្រឈមមុខនឹងហានិភ័យទាក់ទងនឹងអាកាសធាតុខ្លាំងជាងគេ។[70]

ប្រទេសកម្ពុជា គឺជាភាគីមួយនៃអនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ និងកិច្ចព្រមព្រៀងទីក្រុងប៉ារីស។ ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយជាតិ រួមមានក្រមបរិស្ថាន និងធនធានធម្មជាតិឆ្នាំ ២០២៣ ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជាឆ្នាំ ២០២៤-២០៣៣ ផែនការជាតិរួមចំណែកឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ (NDC) ដែលបានធ្វើបច្ចុប្បន្នភាព យុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងប្រកបដោយអព្យាក្រឹតកាបូន (LTS4CN) (ឆ្នាំ២០២១) និងផែនការមេស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុឆ្នាំ ២០១៨-២០៣០។

ទាំងអស់នេះ បង្ហាញពីការប្តេជ្ញាចិត្តចំពោះការបញ្ជ្រាបយេនឌ័រ ក្នុងការងារសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ ការសម្រាលការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យពីគ្រោះមហន្តរាយ។ ទោះជាយ៉ាងណា មិនមែនគោលនយោបាយទាំងអស់សុទ្ធតែឆ្លើយតបទៅនឹងយេនឌ័របានពេញលេញនោះទេ។ គោលនយោបាយមួយចំនួន ខ្វះសកម្មភាពច្បាស់លាស់ ហិរញ្ញប្បទាន និងធនធាន ក៏ដូចជាយន្តការដើម្បីធានាបាននូវការចូលរួមរបស់ស្ត្រី និងក្មេងស្រីក្នុងការសម្រេចចិត្ត ហើយទន្ទឹមនឹងនេះចំណុចខ្វះចន្លោះក្នុងការអនុវត្តនៅតែមានដដែល។ ការអង្កេតយេនឌ័រ និងបរិស្ថាន ឆ្នាំ២០២៤ ផ្តល់នូវមូលដ្ឋានភស្តុតាងរឹងមាំមួយដើម្បីជាព័ត៌មានសម្រាប់ធ្វើគោលនយោបាយឆ្លើយតបនឹងយេនឌ័រ និងការអនុវត្តទៅថ្ងៃខាងមុខ ។

69 Banteay Srei Organization, People in Need, Fair Farms, Solar Green Energy Cambodia, "As Assessment Report on the Impacts of Heat on Women and the Role of Gender Within the Peppercorn Value Chain, Opportunities for Gender Mainstreaming, and Small Pepper Farm Owner and Companies' Adaptation to Climate Change in Kampong Trach and Chhouk District of Kampot, and Other Areas of Kep Provinces," March 2025, online: https://banteaysrei.info/app/uploads/2025/12/An_Assessment_Report_on_the_Impacts_of_Heat_on_Women_and_the_Role.pdf.

70 See National Institute of Social Affairs (NISA), Advocacy and Policy Institute (API), and Fishery Coalition Action Team (FACT) (2025) "Climate Change Adaptation Through a Cash-transfer Program (CTP) in Cambodia: Empirical Evidence from Coastal Communities", online: https://policypulse.org/wp-content/uploads/2025/07/NISA-Final-Report.pdf; Vabotra Chea, et al. "Perceived impact of heat stress on health and productivity of tropical female garment workers – a comparison between cool and hot months", BMC Public Health, April 25, 2025, online: https://link.springer.com/article/10.1186/s12889-025-22787-0; Sao Phal Niseiy, "Climate Crisis Hurts Street Vendors, Mostly Women", Cambodianess, July 20, 2025, online: https://cambodianess.com/article/climate-crisis-hurts-street-vendors-mostly-women; Laurie Parsons, et al. "Climate-linked heat inequality in the global southern workforce: Cambodian workers' economic and health vulnerability to high core temperatures in five occupational sectors", Taylor & Francis, March 11, 2025, online: https://www.tandfonline.com/doi/full/10.1080/17565529.2025.2474026?utm_source=chatgpt.com.

០៨.

បំណុលមីក្រូហិរញ្ញវត្ថុ

គណៈកម្មាធិការ ស៊ី-ដ បានផ្តល់អនុសាសន៍ថា កម្ពុជាគួរតែគ្រប់គ្រងស្ថាប័នមីក្រូហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាព និងបង្កើតយន្តការត្រួតពិនិត្យមួយ ដើម្បីទប់ស្កាត់ការផ្តល់ប្រាក់កម្ចីបែបកេងប្រវ័ញ្ច។[71] ទោះជាយ៉ាងណា ដូចដែលបានចងក្រងជាឯកសារកាលពីឆ្នាំមុនៗដែរ ឧស្សាហកម្មមីក្រូហិរញ្ញវត្ថុរបស់កម្ពុជា ដែលគាំទ្រដោយការវិនិយោគពីធនាគារអភិវឌ្ឍន៍អន្តរជាតិមកពីទូទាំងទ្វីបអឺរ៉ុប និងតំបន់ផ្សេងៗទៀត បានបន្តបង្កើនប្រាក់ចំណេញក្នុងកម្រិតអតិបរមា ដោយគិតគូរពីសុខុមាលភាពរបស់អ្នកខ្ចីប្រាក់ដោយពុំមានលទ្ធភាពទទួលបានដំណោះស្រាយជាប្រព័ន្ធនោះឡើយ។ ជាច្រើនលើសលុប បំណុលទាំងនេះ យកប័ណ្ណកម្មសិទ្ធិដីធ្លីជាទ្រព្យធានា ហើយបន្ទុកភាគច្រើន គឺស្ត្រីជាអ្នកវ៉ាប់រង ខណៈអ្នកខ្ចីប្រាក់ពីមីក្រូហិរញ្ញវត្ថុភាគច្រើន គឺជាស្ត្រី។

អង្គការឃ្លាំមើលសិទ្ធិមនុស្ស (HRW) បានចេញផ្សាយរបាយការណ៍ ឆ្នាំ២០២៥ ដែលពិនិត្យមើលផលប៉ះពាល់នៃការផ្តល់ប្រាក់កម្ចីមីក្រូហិរញ្ញវត្ថុ ដែលមានចរិតកេងប្រវ័ញ្ចលើជនជាតិដើមភាគតិចនៅខេត្តរតនគិរី។[72] របាយការណ៍នេះបានរកឃើញថា "ការជំពាក់បំណុលវ័ណ្ឌក បានធ្វើឱ្យជនជាតិដើមភាគតិចរងការផាត់ចេញកាន់តែខ្លាំងថែមទៀត" ហើយបានចងក្រងជាឯកសារនូវគ្រោះថ្នាក់ដែលពាក់ព័ន្ធ រួមទាំងការបាត់បង់ដីធ្លីមានសារៈសំខាន់ខាងរបួធម៌ ការរំខានដល់ដំណើរការផ្តល់កម្មសិទ្ធិដីធ្លីសមូហភាព ការបាត់បង់មធ្យោបាយចិញ្ចឹមជីវិត និងយន្តការដោះទាល់ បែបគ្រោះថ្នាក់ផ្សេងទៀត ដូចជាការកាត់បន្ថយការទទួលទានអាហារ ការបោះបង់ចោលការសិក្សារបស់កូនៗ និងការធ្វើអត្តឃាតទាក់ទងនឹងបំណុល។ **អង្គការឃ្លាំមើលសិទ្ធិមនុស្ស (HRW) ក៏បានចងក្រងជាឯកសារនូវករណីមួយ ដែលក្នុងនោះ មន្ត្រីតណទានម្នាក់ បានដាក់សម្ពាធឱ្យប្រជាពលរដ្ឋក្នុងគ្រួសារមួលក់កូនស្រីវ័យជំទង់របស់ខ្លួន ឱ្យរកស៊ីផ្លូវភេទដើម្បីសងប្រាក់កម្ចី។ ក្រុមគ្រួសារនោះបានបដិសេធ ហើយក្មេងស្រីនោះមិនបានចាកចេញពីបន្ទប់ឡើយ ហើយខកខានមិនបានទៅសាលារៀនអស់រយៈពេល ជាច្រើនថ្ងៃ ដោយសារតែការភ័យខ្លាចថានឹងត្រូវចាប់ពង្រត់។**

បន្ទុកបំណុល កាន់តែធ្ងន់ធ្ងរឡើង នៅពេលដែលពលករចំណាកស្រុកកម្ពុជាប្រមាណ ៩១០.០០០នាក់ បានវិលត្រឡប់មកពីប្រទេសថៃវិញ ហើយមនុស្សរាប់សែននាក់ត្រូវបានជម្លៀសចេញពីទីលំនៅ ក្នុងស្រុកក្នុងអំឡុងពេលមានជម្លោះព្រំដែន។ ខណៈដែលវិធានការឱ្យចំតាមគោលដៅត្រូវបានដាក់ចេញ ក្នុងបំណងកាត់បន្ថយសម្ពាធហិរញ្ញវត្ថុលើក្រុមគ្រួសារជម្លៀសមួយចំនួន និងគ្រួសាររបស់ទាហានជួរមុខ[73] ប៉ុន្តែរបាយការណ៍បឋមបានបង្ហាញថា វិធានការទាំងនេះមានភាពរប៉ះរប៉ោះ ហើយចន្លោះប្រហោងនៅតែកើតមាន។ ស្ត្រីជាពលករចំណាកស្រុក ដែលបានវិលត្រឡប់មកប្រទេសកម្ពុជាវិញ បានរាយការណ៍ប្រាប់ទៅអង្គការឃ្លាំមើលសិទ្ធិមនុស្ស (HRW) ថាពួកគាត់បានហូបអាហារ និងលែងខ្ចល់ពីការថែទាំសុខភាព ដើម្បីបានសងប្រាក់កម្ចីមីក្រូហិរញ្ញវត្ថុ។[74] គិតត្រឹមត្រីមាសទីបីនៃ ឆ្នាំ២០២៥ ប្រាក់កម្ចីប្រមាណ ២,៣លាន ប្រមាណ៥,៦៩%[75] មានការសងយឺតយ៉ារលើសពី ៩០ថ្ងៃ នៃកាលកំណត់សងប្រាក់វិញ ដែលបង្ហាញឱ្យឃើញពីភាពចាំបាច់ជាបន្តបន្ទាប់ក្នុងការបន្ធូរបន្ថយបំណុល និងដំណោះស្រាយប្រកបដោយអត្ថន័យ។

---

71 CEDAW Committee, above n 1, para. 41.

72 Human Rights Watch (2025) "Cambodia: Microfinance Lending Harming Indigenous Groups", online: https://www.hrw.org/news/2025/09/24/cambodia-microfinance-lending-harming-indigenous-groups.

73 Cambodia Microfinance Association, "CMA Highlights Microfinance Sector Support for Front Soldiers and Displaced Households Affected by Border Conflict", January 16, 2026, online: https://opendevelopmentcambodia.net/wp-content/blogs.dir/2/files_mf/1768536375a.jpg; Pa Tongchen, "Loan Relief Ends for Displaced, Border Farmers Amid Mounting Debt", November 28, 2025, online: https://cambojanews.com/loan-relief-ends-for-displaced-border-farmers-amid-mounting-debt/.

74 Human Rights Watch, anove n 20.

75 Credit Bureau Cambodia previously reported on the percentage of loans that were over 30 days late on repayment. In 2025, the Credit Bureau began only reporting on loans that are over 90 days late. Therefore, this figure is not comparable to previous years. Credit Bureau Cambodia, "Retail Credit Index: Q3 2025 Quarterly Report", online: https://www.creditbureau.com.kh/directus/assets/e8d52587-cce1-4481-ae1c-0c3abe2321e7.

០៩.

អំពើហិង្សាទាក់ទឹងនឹងយេនឌ័រ

អំពើហិង្សាទាក់ទងនឹងយេនឌ័រ រួមទាំងអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សាផ្លូវភេទ អំពើហិង្សាទាក់ទងនឹងយេនឌ័រដែលសម្របសម្រួលដោយបច្ចេកវិទ្យា (TFGBV) អាពាហ៍ពិពាហ៍វ័យកុមារ អំពើហិង្សាផ្តោតលើអ្នកប្រកបរបរផ្លូវភេទ និងសេវាកម្មាន្ត និងអំពើជួញដូរមនុស្ស នៅតែបន្តកើតមានទូទាំងប្រទេសកម្ពុជាក្នុងឆ្នាំ ២០២៥។ បើទោះបីជា មានអនុសាសន៍ជាច្រើនពីគណៈកម្មាធិការ ស៊ី-ដ ក្នុងឆ្នាំ២០១៩ ក្តីក៏លទ្ធភាពទទួលបានសេវាសំខាន់ៗ និងការទទួលបានយុត្តិធម៌ នៅតែបន្តមានកម្រិតតិចតួចដដែល គួបផ្សំនឹងច្បាប់ទម្លាប់សង្គមចាក់ឫសយ៉ាងជ្រៅដែលចាត់ទុកអំពើហិង្សាទាក់ទងនឹងយេនឌ័រ ជារឿងធម្មតា និងផ្តល់អាទិភាពលើការគោរពវប្បធម៌ជាជាងសិទ្ធិស្ត្រី និងក្មេងស្រី។ ហានិភ័យនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងភាពមានកម្រិតនៃការទទួលបានយុត្តិធម៌ មានការកើនឡើងផងដែរ ស្របពេលមានជម្លោះព្រំដែនកម្ពុជា-ថៃ និងការជម្លៀសចេញពីទីលំនៅក្នុងប្រទេសជាលក្ខណៈទ្រង់ទ្រាយធំ។

ប្រទេសកម្ពុជាបន្តពន្យារពេលធ្វើកំណែទម្រង់គ្រប់ជ្រុងជ្រោយ លើច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥ ទោះបីជាចំណុចចន្លោះប្រហោង និងចំណុចខ្សោយនៃច្បាប់នេះត្រូវបានកត់ត្រាចងក្រងជាឯកសារបានយ៉ាងត្រឹមត្រូវក្តី។ នៅក្នុងខែមិថុនា ឆ្នាំ២០២៥ អង្គការសង្គមស៊ីវិលចំនួន ១៣ បានអំពាវនាវជាថ្មីម្តងទៀតឱ្យរដ្ឋាភិបាលចេញផ្សាយជាសាធារណៈ នូវផែនទីបង្ហាញផ្លូវសម្រាប់ការធ្វើវិសោធនកម្មច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ ឱ្យរដ្ឋាភិបាលរៀបចំសេចក្តីព្រាងច្បាប់ដែលបានកែសម្រួលរួច ហើយដែលអនុលោមតាមកាតព្វកិច្ចរបស់កម្ពុជាទាំងនៅថ្នាក់ជាតិ និងអន្តរជាតិ តាមរយៈការធ្វើការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ ហើយអនុម័តច្បាប់ដែលបានកែសម្រួលយ៉ាងពេញលេញ ដោយប្រើប្រាស់ធនធានចាំបាច់ទានា សម្រាប់ការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធភាព។[76] គិតត្រឹមដំណាច់ឆ្នាំ ពុំមានការរាយការណ៍ណាមួយអំពីវឌ្ឍនភាពជាសាធារណៈឡើយ ។

76 Joint Statement, "Cambodia's Delay in Overhauling the Domestic Violence Law is Putting Lives at Risk", June 17, 2025, online: https://ngocedaw.org/wp-content/uploads/2025/06/Joint-Statement-DV-Law-Amendment-Final_20250617_ENG.pdf.

៩.១ ឧប្បត្តិហេតុនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ

រដ្ឋាភិបាលកម្ពុជា មិនបានបោះពុម្ពផ្សាយទិន្នន័យថ្នាក់ជាតិបែងចែកតាមប្រភេទ ស្តីពីប្រេវ៉ាឡង់នៃករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រដែលបានរាយការណ៍នោះទេ។ ក្នុងបរិបទនេះ អង្គការសង្គមស៊ីវិលជាច្រើន ដែលផ្តល់សេវាដល់ប្រជាជន ដែលបានជួបប្រទះអំពើហិង្សាទាក់ទងនឹងយេនឌ័រ បានចងក្រងជាឯកសារ នូវបណ្តាករណីនានាពេញមួយឆ្នាំ។ ទិន្នន័យរបស់អង្គការទាំងនោះ មិនតំណាងឱ្យប្រេវ៉ាឡង់ថ្នាក់ជាតិនោះទេ ប៉ុន្តែបង្ហាញឱ្យឃើញលំនាំគំរូនៃអំពើហិង្សាដែលនៅតែបន្តកើតមាន និងឧបសគ្គជាបន្តបន្ទាប់ដែលប៉ះពាល់ដល់សុវត្ថិភាព និងយុត្តិធម៌។[77]

អង្គការកម្ពុជាដើម្បីស្ត្រីមានវិបត្តិ (CWCC) បានជួយគាំទ្រករណីចំនួន ៣១៧ នៅរាជធានីភ្នំពេញ បន្ទាយមានជ័យ កំពង់ធំ និងសៀមរាប ចាប់ពីខែមករា ដល់ខែមិថុនា ឆ្នាំ២០២៥ រួមមានករណីហិង្សាក្នុងគ្រួសារចំនួន ១៤៣ករណី ហិង្សាផ្លូវភេទចំនួន ៨២ករណី និងអំពើជួញដូរមនុស្សចំនួន ៩២ករណី។

អង្គការថែទាំសុខភាពគ្រួសារកម្ពុជា (អង្គការ រ៉ាក់-RHAC) បានរកឃើញអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រថ្មីចំនួន ៣៣៧ករណី នៅក្នុងខេត្តបន្ទាយមានជ័យ កំពង់ចាម កំពង់ឆ្នាំង កំពង់ធំ កំពតកណ្តាល ភ្នំពេញ ពោធិ៍សាត់ សៀមរាប និងស្ទឹងត្រែង ចាប់ពីខែមករា ដល់ខែសីហា ឆ្នាំ២០២៥។

អង្គការបន្ទាយស្រី បានបញ្ជូនជនរងគ្រោះ/អ្នករស់រានពីអំពើហិង្សាទាក់ទងនឹងយេនឌ័រចំនួន ១២៣នាក់ នៅក្នុងខេត្តសៀមរាប និងខេត្តបាត់ដំបង ទៅកាន់ផ្ទះសុវត្ថិភាព ក្នុងនោះមានជនរងគ្រោះ ៣៩នាក់ ដែលរងផលប៉ះពាល់ដោយអំពើហិង្សាផ្លូវភេទ និង៨៤នាក់ រងផលប៉ះពាល់ដោយអំពើហិង្សាក្នុងគ្រួសារ។

អង្គការលីកាដូ បានស៊ើបអង្កេតករណីរំលោភសិទ្ធិស្ត្រីចំនួន ១៤៦ករណី និងករណីរំលោភសិទ្ធិក្មេងស្រីចំនួន ១៥៩ករណី ក្នុងឆ្នាំ២០២៥ ដែលភាគច្រើនបំផុតទាក់ទងនឹងអំពើហិង្សាក្នុងគ្រួសារ និងផ្លូវភេទ។ ក្នុងចំណោមករណីទាំងនេះ ស្ត្រីចំនួន ៣០នាក់ និងក្មេងស្រី ១២នាក់ ត្រូវបានសម្លាប់។

77 The same case may have been documented and supported by more than one organization in order to provide holistic and comprehensive services. As a result, there may be overlap between the cases documented by CWCC, Banteay Srei, RHAC, and LICADHO.

អង្គការលីកាដូ ក៏បានបោះពុម្ពផ្សាយទិន្នន័យ ស្តីពីការស្លាប់ក្នុងករណីអំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាផ្លូវភេទ ដែលអង្គការនេះបានចងក្រងជាឯកសារ ចាប់ពីខែមករា ឆ្នាំ២០២០ ដល់ខែសីហា ឆ្នាំ២០២៥។[78] ទោះបីមិនមែនជាទិន្នន័យតំណាងទូទាំងប្រទេសក៏ដោយ អង្គការនេះបានកត់ត្រាករណីស្លាប់ចំនួន ១៤៦នាក់ រួមមានស្ត្រី ៩៦នាក់ បុរស ៤នាក់ ក្មេងស្រី ២៧នាក់ និងក្មេងប្រុស ១៩នាក់។ ទិន្នន័យបង្ហាញពីការកើនឡើងនៃករណីដែលបានកត់ត្រាក្នុង ឆ្នាំ២០២៤ ហើយអត្រានៃករណីដែលបានកត់ត្រាបានកើនឡើងបន្ថែមទៀតនៅ ឆ្នាំ២០២៥។ ការស្លាប់ភាគច្រើនកើតឡើងនៅក្នុងបរិបទទំនាក់ទំនងដែគូស្និទ្ធស្នាល ឬក្នុងគ្រួសារ ដោយក្នុងនោះដែគូបច្ចុប្បន្ន ឬអតីត ត្រូវបានកំណត់ថាជាអ្នកទទួលខុសត្រូវចំពោះការស្លាប់របស់ស្ត្រី និងក្មេងស្រីចំនួន ៧៩នាក់ ហើយសមាជិកគ្រួសារ ឬសាច់ញាតិផ្សេងទៀត ជាអ្នកទទួលខុសត្រូវចំពោះការស្លាប់របស់មនុស្សចំនួន ៤៧នាក់។ មានករណីខ្លះ អំពើហិង្សាផ្លូវភេទបានកើតឡើងមុនពេលយាតកម្ម ដែលភាគច្រើនបំផុត ពាក់ព័ន្ធនឹងបុគ្គលដែលអ្នកស្លាប់នោះស្គាល់ ដូចជាអ្នកជិតខាងជាដើម។

ករណី បុរសម្នាក់ និងក្មេងប្រុសពីរនាក់បានរំលោភសេពសន្ថវ: និងសម្លាប់ក្មេងស្រីអាយុ ១៥ឆ្នាំ ម្នាក់ នៅក្នុងសាលារៀនមួយកន្លែងក្នុងខែឧសភា ឆ្នាំ២០២៥។[79] ករណីនេះបានបណ្តាលឱ្យមានការពិភាក្សាជាច្រើន ក្នុងចំណោមមហាជននៅលើបណ្តាញសង្គម ដែលភាគច្រើនមានការប្រើប្រាស់ពាក្យពេចន៍ដែលស្តីបន្ទោសក្មេងស្រី និងឱពុកម្តាយរបស់នាងជាជាងជនល្មើស។ បើទោះបីជា មហាជនខ្លះបានបញ្ចេញមតិវិជ្ជមាន ជំទាស់ទៅនឹងពាក្យពេជន៍ទាំងនោះក្តី ហើយជនសង្ស័យត្រូវបានឃុំខ្លួន និងផ្តន្ទាទោសក្តី ប៉ុន្តែបទល្មើស និងការពិភាក្សាជុំវិញករណីនោះបានបង្ហាញឱ្យឃើញនូវឧបសគ្គសង្គមរ៉ាំរ៉ៃ ដែលរាវាំងដល់ការដោះស្រាយ សូម្បីអំពើហិង្សាទាក់ទងនឹងយេនឌ័រដែលមានទម្រង់ធ្ងន់ធ្ងរបំផុតដូចនេះក្តី។

អង្គការទ្រទ្រង់ស្ត្រីខ្មែរ (COWS) បានស្ទង់មតិមនុស្សចំនួន ៣៦០នាក់ នៅក្នុងខេត្តកំពង់ធំ ស្ទឹងត្រែង និងព្រះវិហារ។[80] ក្នុងនោះអ្នកឆ្លើយតបចំនួន ២៨ភាគរយ បានរាយការណ៍ថាធ្លាប់បានជួបប្រទះនឹងការបៀតបៀនផ្លូវភេទនៅក្នុងសហគមន៍របស់ខ្លួន ដោយក្នុងចំនួននោះ អ្នកដែលរាយការណ៍ពីអំពើហិង្សាពីដែគូស្និទ្ធស្នាល និងអំពើហិង្សាក្នុងគ្រួសារមានភាគរយខ្ពស់ជាងគេ។ ការស្ទង់មតិនេះ ក៏បានពិនិត្យមើលលើការយល់ឃើញអំពីកត្តារួមផ្សំនានាចំពោះអំពើហិង្សាផ្លូវភេទផងដែរ ដោយក្នុងនោះការប្រើប្រាស់គ្រឿងស្រវឹង និងគ្រឿងញៀនគឺជាកត្តារួមផ្សំដែលត្រូវបានរាយការណ៍ញឹកញាប់បំផុត ពោលគឺ ២៨% នៃអ្នកឆ្លើយតប គឺបានរាយការណ៍បែបនេះ។

78 LICADHO, "Enough is Enough: At Least 146 Cambodians Killed by Domestic and Sexual Violence Since 2020", October 16, 2025, online: https://www.licadho-cambodia.org/articles/20251016/202/index.html.

79 Sangeetha Amarthalingam and Thang Sinorn, "Teenagers Rape and Kill 15-year-old Girl in School Toilet", Kiripost, May 22, 2025, online: https://kiripost.com/stories/teenagers-rape-and-kill-15-year-old-girl-in-school-toilet.

80 Information provided by COWS.

៩.២ លទ្ធភាពទទួលបានសេវា និងយុត្តិធម៌

លទ្ធភាពទទួលបានសេវា និងយុត្តិធម៌ សម្រាប់អ្នកដែលជួបប្រទះអំពើហិង្សាទាក់ទងនឹងយេនឌ័រ នៅតែមិនទាន់គ្រប់គ្រាន់ទាល់តែសោះនៅ ឆ្នាំ២០២៥។ អង្គការនារីដើម្បីសន្តិភាព (WPM) បានបោះពុម្ពផ្សាយការស្រាវជ្រាវថ្មីមួយស្តីពី លទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានយុត្តិធម៌ និងការប្រើប្រាស់ដំណោះស្រាយវិវាទនៅថ្នាក់មូលដ្ឋាន ដើម្បីឆ្លើយតបទៅនឹងទំនាស់ដៃគូស្និទ្ធស្នាល។[81] ការស្រាវជ្រាវនេះ បានពិនិត្យមើលការអនុវត្តរបស់មន្ត្រីចំនួន ៥២រូប ដែលផ្តល់ជំណោះស្រាយវិវាទនៅមូលដ្ឋាន ដោយប្រៀបធៀបអ្នកដែលបានទទួលការបណ្តុះបណ្តាលជំនាញ ស្តីពីការសម្រុះសម្រួល ឬសន្ធានកម្មឆ្លើយតបនឹងយេនឌ័រ ជាមួយអ្នកដែលមិនបានទទួលការបណ្តុះបណ្តាល។

របាយការណ៍នេះបានកំណត់រកឃើញគម្លាតចំណេះដឹង សមត្ថភាព និងការអនុវត្តផ្តោតលើជនរងគ្រោះក្នុងចំណោមមន្ត្រីទាំងពីរក្រុម។ មន្ត្រីមួយចំនួនបានបន្តបង្វែរករណីផ្សេងៗ ដែលតាមពិតត្រូវមានចំណាត់ការផ្លូវច្បាប់ ទៅជាការប្រើប្រាស់ដំណោះស្រាយវិវាទនៅមូលដ្ឋានទៅវិញ ដែលជា "ការប្រថុយធ្វើឱ្យសកម្មភាពរបស់ជនល្មើស ទៅជាស្របច្បាប់ ឬបង្ករគ្រោះថ្នាក់បន្ថែមទៀតដល់ជនរងគ្រោះ"។ ទន្ទឹមនឹងនេះ អ្នកផ្តល់សេវាក៏បានរាយការណ៍ដូចគ្នាដែរថា យន្តការបញ្ជូនទៅរកជំនួយផ្នែកច្បាប់ ការថែទាំសុខភាព ការប្រឹក្សាយោបល់ និងមណ្ឌលសុវត្ថិភាព គឺមិនមានភាពច្បាស់លាស់ ឬគ្មានប្រសិទ្ធភាពតែម្តង។ ស្រដៀងគ្នានេះដែរ ការប្រើប្រាស់សេចក្តីសម្រេចរដ្ឋបាល ដើម្បីជាវិធានការការពារ ក៏មិនប្រសិទ្ធភាពដែរ។

ក្នុងចំណោមស្ត្រី ៤៩នាក់ ដែលបានចូលរួមក្នុងការសិក្សាស្រាវជ្រាវរបស់អង្គការ នារីដើម្បីសន្តិភាព (WPM) ភាគច្រើនបានសម្តែងការគាំទ្រចំពោះការដោះស្រាយវិវាទនៅមូលដ្ឋាន ដែលជារឿយៗត្រូវបានគេយល់ឃើញ ថាងាយស្រួលស្វែងរក ចំណាយសមរម្យ ទាន់ពេលវេលា និងត្រឹមត្រូវជាជាងប្រព័ន្ធច្បាប់ផ្លូវការ។ បើទោះបីជាមានអ្នកខ្លះរាយការណ៍ថា បានលទ្ធផលវិជ្ជមានរួមទាំងភាពប្រសើរឡើងនៃទំនាក់ទំនងរបស់ខ្លួន ឬការលៃងលះដោយជោគជ័យក្តី ប៉ុន្តែមនុស្សផ្សេងទៀតនៅតែបន្តបង្ហាញពីការព្រួយបារម្ភយ៉ាងខ្លាំងអំពីសុវត្ថិភាពរបស់ខ្លួន និងលទ្ធភាពទទួលបានយុត្តិធម៌។ របាយការណ៍បានសន្និដ្ឋានថា ការកែទម្រង់ជាបន្ទាន់គឺជារឿងចាំបាច់ ទាំងយន្តការដោះស្រាយវិវាទនៅមូលដ្ឋាន និងប្រព័ន្ធច្បាប់ផ្លូវការ ដើម្បីធានាបាននូវការទទួលបានយុត្តិធម៌ប្រកបដោយប្រសិទ្ធភាព និងផ្តោតលើជនរងគ្រោះ។

ការស្ងង់មតិដោយអង្គការទ្រទ្រង់ស្ត្រីខ្មែរ (COWS) ក្នុងចំណោមមនុស្សចំនួន

៣៦០នាក់

ប្រហែល ៣០% នៃអ្នកឆ្លើយតប បានរាយការណ៍ថា នៅក្នុងឃុំរបស់ខ្លួនមិនមានកន្លែងសុវត្ថិភាពឡើយ សម្រាប់អ្នកដែលកំពុងជួបប្រទះអំពើហិង្សា។

ការស្ងង់មតិដោយអង្គការទ្រទ្រង់ស្ត្រីខ្មែរ (COWS) ក្នុងចំណោមមនុស្សចំនួន ៣៦០នាក់ ក៏បានរកឃើញស្រដៀងគ្នាដែរថា ប្រហែល ៣០% នៃអ្នកឆ្លើយតបបានរាយការណ៍ថា នៅក្នុងឃុំរបស់ខ្លួនមិនមានកន្លែងសុវត្ថិភាពឡើយ សម្រាប់អ្នកដែលកំពុងជួបប្រទះអំពើហិង្សា។ ជាង៣ក់កណ្តាល (៥២%) បានបង្ហាញថាអាជ្ញាធរមូលដ្ឋាន និងអ្នក៣ក់ព័ន្ធផ្សេងទៀតគួរតែប្រឹងប្រែងបន្ថែមទៀត ដើម្បីផ្សព្វផ្សាយព័ត៌មានឱ្យបានទូលំទូលាយ ដើម្បីឱ្យអ្នកដែលប្រឈមមុខនឹងអំពើហិង្សាអាចដឹងពីវិធីស្វែងរកទីតាំងសុវត្ថិភាព។[82]

81 Women Peace Makers (2025) "Prospects and Challenges for Women's Access to Justice: Revisiting Local Dispute Resolution Practice in relation to Intimate Partner Disputes", online: https://wpmcambodia.org/project/prospects-and-challenges-for-womens-access-to-justice/.

82 Information provided by COWS.

អង្គការកម្ពុជាដើម្បីស្ត្រីមានវិបត្តិ (CWCC) បានរាយការណ៍ថាការទទួលបានជំនួយផ្នែកច្បាប់ ដែលកំណត់ដោយរដ្ឋាភិបាលនៅតែមានកម្រិតនៅឡើយ។ ជារឿយៗ អ្នកដែលស្នើសុំជំនួយផ្នែកច្បាប់ ត្រូវបានទាមទារឱ្យផ្តល់ភស្តុតាងបញ្ជាក់ពីតម្រូវការហិរញ្ញវត្ថុ ដែលជាទូទៅ គឺតាមរយៈបណ្ណសមធម៌ដែលចេញក្រោមកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (IDPoor) របស់កម្ពុជា។ លក្ខខណ្ឌតម្រូវទាំងនេះអាចជាការផាត់ចោលស្ត្រី និងកុមារមួយចំនួន ដែលត្រូវការជំនួយផ្នែកច្បាប់ ប៉ុន្តែខ្វះឯកសារចាំបាច់។ ស្រដៀងគ្នានេះដែរ លទ្ធភាពទទួលបានសំណងផ្នែកហិរញ្ញវត្ថុក៏នៅតែមានកម្រិតផងដែរ។ សូម្បីនៅពេលតុលាការបញ្ជាឱ្យផ្តល់សំណងរដ្ឋប្បវេណី ដំណើរការនៃការអនុវត្តច្បាប់គឺស្មុគស្មាញ និងអូសបន្លាយពេលវេលាយូរ។ ក្នុងការអនុវត្តជាក់ស្តែង នីតិវិធីវែងឆ្ងាយ ការចំណាយលើដំណើរការផ្នែកច្បាប់ និងរដ្ឋបាល ការចំណាយលើការធ្វើដំណើរ និងការខកខានពេលវេលាមិនបានធ្វើការ គឺជាឧបសគ្គក្នុងការទទួលបានសំណងហិរញ្ញវត្ថុ។

អង្គការកម្ពុជាដើម្បីស្ត្រីមានវិបត្តិ (CWCC) ក៏បានរាយការណ៍ផងដែរថា គេនៅតែខ្វះវិធីសាស្ត្រកុមារមេត្រី។[83] ជាពិសេស ការប្រើប្រាស់អ្នកសម្ភាសកុមារ ដែលមានការបណ្តុះបណ្តាលត្រឹមត្រូវ កន្លែងសម្ភាសមានសុវត្ថិភាព និងភាសាសមស្របតាមអាយុ គឺមិនទាន់គ្រប់គ្រាន់នោះទេ។ ពេលខ្លះកុមារត្រូវបានសាកសួរដោយប្រើវិធីសាស្ត្របែបផ្ទ្រិតបង្ខំ ត្រួតត្រាតាមអំពើចិត្ត ហើយមានករណីខ្លះ គឺសាកសួរនៅចំពោះមុខជនជាប់ចោទនៅក្នុងបន្ទប់សវនាការ។ ទោះបីជាតុលាការមួយចំនួនបានប្រើរបាំងមិនឱ្យឃើញរាងកាយក្តី ប៉ុន្តែកុមារមួយចំនួននៅតែអាចស្តាប់ឮសម្លេង ជនជាប់ចោទនិយាយចោទប្រកាន់ ហើយពួកគាត់មានអារម្មណ៍ថាមានវត្តមានរបស់ជនជាប់ចោទ។ បញ្ហាប្រឈមផ្សេងទៀតរួមមានដូចជា កុមារមានជម្រើសតិចតួចទាក់ទងនឹងយេនឌ័ររបស់អាជ្ញាធរ និងចៅក្រម ដែលពួកគាត់ប្រាស្រ័យទាក់ទង ហើយនិងដំណើរការនីតិវិធីច្បាប់អូសបន្លាយពេលយូរ ដែលរំខានដល់ការអប់រំ និងជីវិតប្រចាំថ្ងៃ។ កត្តាទាំងនេះត្រូវបានរាយការណ៍ថា បានរួមចំណែកដល់ការភ័យខ្លាច ស្រេកការភាន់ច្រឡំ ការគំរាមកំហែង ការចប់បារម្ភ និងរបួសផ្លូវចិត្ត។ កត្តាទាំងនេះអាចរំខានដល់សមត្ថភាពរបស់កុមារក្នុងការផ្តល់សក្ខីកម្មពេញលេញ និងសុក្រឹត ហើយអាចធ្វើឱ្យប៉ះពាល់ដល់ជំនឿចិត្តរបស់កុមារក្នុងការបញ្ចេញព័ត៌មានអំពីការរំលោភបំពាន និងក្នុងការស្វែងរកយុត្តិធម៌។

៩.៣ អំពើហិង្សាទាក់ទងនឹងយេនឌ័រដែលសម្របសម្រួលដោយបច្ចេកវិទ្យា (TFGBV)

កំណើនលទ្ធភាពចូលទៅប្រើប្រាស់បច្ចេកវិទ្យា និងអ៊ីនធឺណេត ក៏ដូចជាកំណើនសេដ្ឋកិច្ចឌីជីថលរបស់ប្រទេសកម្ពុជា បានផ្តល់ឱកាសឱ្យទម្រង់ថ្មីនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ កើតមានឡើងនៅតាមអនឡាញ ឬតាមរយៈការប្រើប្រាស់បច្ចេកវិទ្យា។

ការស្រាវជ្រាវមួយដោយមជ្ឈមណ្ឌលអាស៊ី បានពិនិត្យមើលលើបញ្ហាអំពើហិង្សាទាក់ទងនឹងយេនឌ័រសម្របសម្រួលដោយបច្ចេកវិទ្យា (TFGBV) ដែលជួបប្រទះដោយស្ត្រីកម្ពុជា ហើយពួកគេត្រូវបានគេស្គាល់ថាជាបុគ្គលសាធារណៈ រួមមានស្ត្រីអ្នកការពារសិទ្ធិមនុស្ស ស្ត្រីជនជាតិដើមភាគតិចដែលតស៊ូមតិដើម្បីសិទ្ធិរបស់ពួកគាត់ អ្នកសារព័ត៌មាន និងមេដឹកនាំសង្គមស៊ីវិល។[84] ការសិក្សាស្រាវជ្រាវ បានរកឃើញនូវទម្រង់រួមនៃគ្រោះថ្នាក់ រួមមានការធ្វើបាប និងការបៀតបៀនតាមអនឡាញ ដែលមានបំណងបង្ខូចដល់ការជឿជាក់ ការបៀតបៀនផ្លូវភេទតាមអនឡាញ ដូចជាសារប្រមាថមាក់ងាយ ឬការស្នើសុំ ឬផ្ញើរូបភាពអាសអាភាស ដែលគេមិនមានការព្រមព្រៀង និងការភ្ជួតកុហក ឬការក្លែងខ្លឹមសារ នៃមាតិកាតាមអនឡាញ។ គ្រោះថ្នាក់ទាំងនេះត្រូវបានប្រព្រឹត្តដោយទាំងតួអង្គរដ្ឋផង និងមិនមែនរដ្ឋផង។

83 Information provided by COWS.

84 Asia Centre (2025) "Technology-Facilitated Gender-Based Violence in Cambodia: Impact on the Civic Freedoms of Women Journalists and Human Rights Defenders", online: https://asiacentre.org/technology-facilitated-gender-based-violence-in-cambodia-impact-on-the-civic-freedoms-of-women-journalists-and-human-rights-defenders/.

អង្គការក្លាហាន ក៏បានស្រាវជ្រាវអំពីការយល់ដឹង និងបទពិសោធន៍របស់សាធារណជនជុំវិញ អំពើហិង្សាទាក់ទងនឹងយេនឌ័រសម្របសម្រួលដោយបច្ចេកវិទ្យា (TFGBV) នៅកម្ពុជា ដោយមានការសម្ភាសន៍ជាមួយមនុស្សចំនួន ៦១នាក់ និងការស្ទង់មតិតាមអនឡាញជាមួយនឹងអ្នកចូលរួមចំនួន ១២៩នាក់។[85] ស្ទើរតែមួយភាគបីនៃអ្នកចូលរួមក្នុងការស្ទង់មតិ (ចំនួន៣២%) បានរាយការណ៍ថា ធ្លាប់បានឆ្លងកាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រសម្របសម្រួលដោយបច្ចេកវិទ្យា (TFGBV) ខណៈអ្នកចូលរួមជាងពាក់កណ្តាល (៥៥%) បានរាយការណ៍ថា ធ្លាប់ស្គាល់អ្នកដែលធ្លាប់បានឆ្លងកាត់។ ស្ត្រី និងសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា (LGBTIQ+) ភាគច្រើនត្រូវបានគេយល់ឃើញថាជាអ្នកដែលរងហានិភ័យខ្ពស់ បន្ទាប់មកគឺជនមានពិការភាព ជនជាតិដើមភាគតិច ប្រជាជនដែលរស់នៅទីជនបទ និងជនជាតិភាគតិច។

ទម្រង់នៃអំពើហិង្សាទាក់ទងនឹងយេនឌ័រសម្របសម្រួលដោយបច្ចេកវិទ្យា (TFGBV) ដែលគេជួបប្រទះ ឬបានឃើញញឹកញាប់ជាងគេបំផុត រួមមានពាក្យពេជន៍បែបស្អប់ខ្ពើម ការបៀតបៀន និងការកេងប្រវ័ញ្ចផ្លូវភេទ ជាពិសេសការរំលោភបំពានដោយប្រើរូបភាព និងការបោកប្រាស់តាមអនឡាញ។ ទម្រង់នៃអំពើហិង្សាទាំងនេះភាគច្រើន ត្រូវបានប្រព្រឹត្តឡើងតាមរយៈមតិយោបល់នៅលើប្រព័ន្ធបណ្តាញសង្គម សារបង្ហោះដែលបានចែករំលែក ឬការផ្ញើសារ និងទូរស័ព្ទហៅដោយផ្ទាល់។ បើទោះបីជាហេតុការណ៍ជាច្រើនពាក់ព័ន្ធនឹងមនុស្សប្លែកមុខក្តី ប៉ុន្តែជនជាអតីតដៃគូស្និទ្ធស្នាល ក៏បានប្រព្រឹត្តអំពើបៀតបៀនផ្លូវភេទតាមអនឡាញ និងការរំលោភបំពានដោយប្រើរូបភាពផងដែរ។

ការសិក្សាទាំងពីរបានគូសបញ្ជាក់ពីកត្តារចនាសម្ព័ន្ធ និងកត្តាសង្គម ដែលរួមចំណែកឱ្យមានអំពើហិង្សាទាក់ទងនឹងយេនឌ័រសម្របសម្រួលដោយបច្ចេកវិទ្យា (TFGBV) នេះ។ មជ្ឈមណ្ឌលអាស៊ី បានកំណត់ឃើញទំនាក់ទំនងរវាងអំពើហិង្សាទាក់ទងនឹងយេនឌ័រសម្របសម្រួលដោយបច្ចេកវិទ្យា (TFGBV) និងគំរូលំនាំក្នុងរូបភាពធំនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដែលកើតឡើងដោយសារទំនាក់ទំនងអំណាចមិនស្មើគ្នា និងភាពខ្ទះចន្លោះនៅក្នុងយន្តការច្បាប់ និងកិច្ចគាំពារជនរងគ្រោះ។ បទសម្ភាសន៍របស់អង្គការក្លាហាន បានឆ្លុះបញ្ចាំងឱ្យឃើញពីកត្តាបន្ថែមទៀត រួមមានអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយនៅមានកម្រិត ភាពអនាមិកដែលកម្មវិធីអនឡាញអនុញ្ញាតឱ្យមាន និងច្បាប់ទម្លាប់ដែលគេប្រកាន់ខ្ជាប់ជាទូទៅ និងការរំពឹងចង់បានពីយេនឌ័រនីមួយៗ។

អំពើហិង្សាទាក់ទងនឹងយេនឌ័រសម្របសម្រួលដោយបច្ចេកវិទ្យា (TFGBV) ត្រូវបានគេរកឃើញថា ធ្វើឱ្យប៉ះពាល់ដល់ការចូលរួមក្នុងជីវិតរស់នៅសាធារណៈទាំងនៅក្នុងអនឡាញ និងក្រៅអនឡាញ។ មជ្ឈមណ្ឌលអាស៊ី បានរាយការណ៍ថា គ្រោះថ្នាក់បែបនេះជាការរឹតត្បិតសេរីភាពក្នុងការបញ្ចេញមតិ ការបង្កើតសមាគម និងការប្រតិបត្តិសាសនា ហើយរួមចំណែកធ្វើឱ្យស្ត្រីដកខ្លួនចេញពីតួនាទីសាធារណៈ ដោយសារការបាក់ស្បាត ឬលាលែងពីតំណែងជាអ្នកដឹកនាំ និងជាអ្នកតស៊ូមតិ។ ស្រដៀងគ្នានេះដែរ ៧១% នៃអ្នកឆ្លើយតបសំណួរស្ទង់មតិ របស់អង្គការក្លាហាន បានបង្ហាញថាពួកគាត់បាក់ស្បាតនៅលើអនឡាញ។ ជាងមួយភាគបី (៣៦%) រាយការណ៍ថា អំពើហិង្សាទាក់ទងនឹងយេនឌ័រសម្របសម្រួលដោយបច្ចេកវិទ្យា (TFGBV) បានរិតត្បិតពួកគាត់ពីការចូលរួមនៅក្នុងការពិភាក្សាជាសាធារណៈនៅខាងក្រៅ និងឱកាសនានា។ ផលប៉ះពាល់កើតឡើងជាក់ស្តែងនៅខាងក្រៅ ដែលគេបានរាយការណ៍ រួមមានភាពតានតឹងផ្លូវចិត្ត ភាពអាម៉ាស ការថប់បារម្ភ ការធ្លាក់ទឹកចិត្ត និងការព្រួយបារម្ភអំពីសុវត្ថិភាពផ្ទាល់ខ្លួន។

ការយល់ដឹងរបស់មហាជនអំពី TFGBV នៅតែមានកម្រិតមិនស្មើគ្នា និងតិចតួច។ ទោះជាយ៉ាងណា មជ្ឈមណ្ឌលអាស៊ីបានសង្កេតឃើញថា ស្ត្រីបានចែករំលែកបទពិសោធន៍របស់ខ្លួននៅលើបណ្តាញសង្គមកាន់តែច្រើនឡើង ដែលរួមចំណែកដល់ការបង្កើនចំណេះដឹង និងការពិភាក្សាជាសាធារណៈកាន់តែទូលំទូលាយ។

យន្តការកិច្ចគាំពារ និងជំនួយគាំទ្រនៅតែមានកម្រិតដដែល។ មជ្ឈមណ្ឌលអាស៊ីបានរកឃើញថា បទប្បញ្ញត្តិច្បាប់បច្ចុប្បន្នមិនបានឆ្លើយតបឱ្យបានគ្រប់គ្រាន់ចំពោះ TFGBV ឡើយ ហើយដំណើរការតុលាការមិនមានការផ្តោតលើជនរងគ្រោះឱ្យបានគ្រប់គ្រាន់ទេ ហើយទន្ទឹមនឹងនេះអង្គការសង្គមស៊ីវិលច្រើនតែខ្ទះនីតិវិធី និងជំនាញដើម្បីឆ្លើយតបចំពោះអំពើហិង្សាបែនេះ។ ស្រដៀងគ្នានេះដែរ អង្គការក្លាហាន បានកំណត់រកឃើញឧបសគ្គធំៗ ដែលរាវាំងដល់ការស្វែងរកជំនួយគាំទ្រ រួមមានការប្រមាថមាក់ងាយ និងអាកប្បកិរិយាស្តីបន្ទោសជនរងគ្រោះ ព័ត៌មាន សេវាកម្ម និងតម្លៃ ដែលអាចជឿទុកចិត្ត បាននៅមានកម្រិត។

85 Klahaan (2025) "Behind the Screen: Understanding Online Gender-Based Violence in Cambodia", online: https://56dd158a-1ed4-4131-9020-9d0718381f08.filesusr.com/ugd/091c7d_eef56ca6c07e4d86867a42c520ff884c.pdf.

១៤%
ចំណោមស្ត្រីនៅក្នុងខេត្តចំនួនប្រាំបួន ដែលបានចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះ បានរៀបការមុនអាយុ **១៨**



អាយុអប្បបរមាស្របច្បាប់សម្រាប់ការរៀបអាពាហ៍ពិពាហ៍នៅក្នុងប្រទេសកម្ពុជាគឺ ១៨ឆ្នាំ ហើយក្នុងករណីលើកលែង កុមារអាយុ ១៦ឆ្នាំ ត្រូវបានអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍បាន ប្រសិនមានការព្រមព្រៀងពីឪពុកម្តាយ

៩.៤ អាពាហ៍ពិពាហ៍កុមារ

ទោះបីកម្ពុជាសម្រេចបានវឌ្ឍនភាព ក្នុងការកាត់បន្ថយអាពាហ៍ពិពាហ៍កុមារ តាមរយៈអន្តរាគមន៍ចំគោលដៅក៏ពិតមែន ប៉ុន្តែចាំបាច់ត្រូវកែសម្រេចឱ្យបាននូវវឌ្ឍនភាពបន្ថែមទៀត។ អាយុអប្បបរមាស្របច្បាប់ សម្រាប់ការរៀបអាពាហ៍ពិពាហ៍នៅក្នុងប្រទេសកម្ពុជាគឺ ១៨ឆ្នាំ ហើយក្នុងករណីលើកលែង កុមារអាយុ ១៦ឆ្នាំ ត្រូវបានអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍បាន ប្រសិនមានការព្រមព្រៀងពីឪពុកម្តាយ។[86] ជាក់ស្តែង ដោយសារតែការអនុវត្តនៅមានកម្រិត និងអត្រានៃការរៀបអាពាហ៍ក្រៅផ្លូវការ ឬបែបប្រពៃណី នាំឱ្យមានអាពារពិពារហ៍កុមារមិនទាន់គ្រប់អាយុកាន់តែច្រើនបានរៀបចំឡើង។

ការសិក្សាស្រាវជ្រាវមួយរបស់ក្រសួងកិច្ចការនារី ជាមួយអង្គការផ្លែនអន្តរជាតិ (Plan International) បានរកឃើញថា ក្នុងចំណោមស្ត្រីនៅក្នុងខេត្តចំនួនប្រាំបួន ដែលបានចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះមាន ១៤% បានរៀបការមុនអាយុ ១៨ឆ្នាំ។ ការសិក្សានេះបានរកឃើញថា ខេត្តរតនគិរី មានប្រេវ៉ាឡង់ខ្ពស់ជាងគេបំផុត ដោយក្នុងនោះស្ត្រីដែលចូលរួមការសិក្សាមានចំនួន ៣៧% ដែលបានរៀបការមុនអាយុ ១៨ឆ្នាំ។[87]

ប្រទេសកម្ពុជា បានបង្ហាញពីការអភិវឌ្ឍផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អាពាហ៍ពិពាហ៍វ័យក្មេង និងការមានផ្ទៃពោះវ័យជំទង់នៅកម្ពុជា (២០២៥-២០៣០)។[88] ទោះជាយ៉ាងណា ការបន្តសម្រេចឱ្យបានវឌ្ឍនភាពនឹងត្រូវពឹងផ្អែកលើការវិនិយោគជាបន្តបន្ទាប់លើការអប់រំ ការកែលម្អឱកាសសេដ្ឋកិច្ចឱ្យប្រសើរឡើង និងកិច្ចខិតខំប្រឹងប្រែងដើម្បីដោះស្រាយច្បាប់ទម្លាប់សង្គម ដែលជាកត្តារួមចំណែកដល់ការរៀបអាពាហ៍ពិពាហ៍វ័យក្មេង។

86 Civil Code of Cambodia, Article 948.

87 Ministry of Women's Affairs and Plan International, June 2024, online: https://asset.cambodia.gov.kh/mowa/2024/06/report-on-early-married-kh.pdf.

88 See, National Action Plan on Prevention and Response to Violence Against Children 2025-2030, July 18, 2025, online: https://www.unicef.org/cambodia/media/10486/file/NVAC%202025-2030%20English%20version.pdf.pdf

៩.៥ អំពើហិង្សាលើអ្នកប្រកបរបរផ្ទះភេទ និងអ្នកធ្វើការនៅគ្រឹះស្ថានសេវាកម្មាន្ត

នៅឆ្នាំ២០២៥ សិទ្ធិរបស់អ្នកប្រកបរបរផ្ទះភេទ និងអ្នកធ្វើការនៅគ្រឹះស្ថានសេវាកម្មាន្ត ក្នុងការទទួលបានសុវត្ថិភាពស្វ័យភាពរាងកាយ ការថែទាំសុខភាព និងការទទួលបានយុត្តិធម៌នៅតែបន្តរងការគំរាមកំហែង ដោយសារការដាក់ទោសព្រហ្មទណ្ឌ កង្វះការគាំពារផ្នែកច្បាប់ និងច្បាប់ទម្លាប់សង្គមដែលកំណត់លើយេនឌ័រ។ បើទោះបីជាគណៈកម្មាធិការ ស៊ី-ដ បានផ្តល់អនុសាសន៍ឱ្យដកទោសព្រហ្មទណ្ឌចំពោះការងារប្រកបរបរផ្ទះភេទក្តី[89] ប៉ុន្តែច្បាប់ឆ្នាំ ២០០៨ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្ទះភេទ និងគោលការណ៍ណែនាំ ស្តីពីគោលនយោបាយភូមិឃុំ/សង្កាត់សុវត្ថិភាពឆ្នាំ ២០១០[90] នៅតែបន្តហាមឃាត់សកម្មភាពភាគច្រើនដែលទាក់ទងនឹងការងារប្រកបរបរផ្ទះភេទ។ ក្របខ័ណ្ឌទាំងនេះ បានរួមចំណែកដល់បរិយាកាសការងារអសុវត្ថិភាព និងរឹតត្បិតដល់លទ្ធភាពទទួលបានសេវាសង្គមកិច្ច ច្បាប់ និងសុខភាព។ គំនិតផ្តួចផ្តើមប្រឆាំងនឹងការជួញដូរមនុស្ស បានបង្ហាញពីការបរាជ័យក្នុងការបែងចែកភាពខុសគ្នារវាង ការងារប្រកបរបរផ្ទះភេទ និងអំពើជួញដូរមនុស្ស ដែលទាំងនេះបាននាំឱ្យជះឥទ្ធិពលអវិជ្ជមានទៅលើសិទ្ធិ និងជីវភាពរស់នៅរបស់អ្នកប្រកបរបរផ្ទះភេទផងដែរ។

អង្គការ បណ្តាញការងារស្ត្រីរួបរួមគ្នា (WNU) បានចងក្រងឯកសារអំពីការចាប់ខ្លួនស្ត្រីប្រកបរបរផ្ទះភេទយ៉ាងហោច ១៨៩នាក់ ក្នុង ឆ្នាំ២០២៥ រួមទាំងស្ត្រីប្រកបរបរផ្ទះភេទឯករាជ្យចំនួន ២៦នាក់ និងអ្នកធ្វើការនៅគ្រឹះស្ថានសេវាកម្មាន្តចំនួន ១៦៣នាក់នៅតាមខាវ៉ាអូខេ និងភោជនីយដ្ឋាន។ ដូចឆ្នាំមុនៗដែរ មនុស្សជាច្រើនត្រូវបានចាប់ឃុំដោយបំពានពីអាជ្ញាធរខណ្ឌដូនពេញ ហើយបញ្ជូនទៅមន្ទីរសង្គមកិច្ចនៅរាជធានីភ្នំពេញ បន្ទាប់មកក៏បញ្ជូនទៅមណ្ឌលសំចតរាជធានីភ្នំពេញ (មណ្ឌលព្រៃស្ពឺ) ឬមជ្ឈមណ្ឌលជាតិស្តានីតិសម្បទាព្យាបាលអ្នកញៀនគ្រឿងញៀន ឬមណ្ឌលឱកាសខ្ញុំ មុនពេលទទួលបានការដោះលែង។

ក្នុងអំឡុងពេលដូចគ្នានេះដែរ អង្គការបណ្តាញការងារស្ត្រីរួបរួមគ្នា (WNU) បានចងក្រងឯកសារចំនួន ១២០ករណី នៃអំពើហិង្សាលើរាងកាយ និងការរំលោភបំពានផ្ទះភេទ (រួមទាំងការរំលោភបូក) ទៅលើអ្នកប្រកបរបរផ្ទះភេទ និងអ្នកធ្វើការនៅគ្រឹះស្ថានសេវាកម្មាន្ត ដែលប្រព្រឹត្តដោយសន្តិសុខស្រុក ម្ចាស់ផ្ទះ និងម្ចាស់ហាង អតិថិជន ដៃគូស្និទ្ធស្នាល និងបុគ្គលិកមន្ទីរឃុំ ឃាំង។ អ្នកប្រកបការងារទាំងនោះ បានប្រឈមមុខនឹងឧបសគ្គខ្លាំងក្នុងការទទួលបានយុត្តិធម៌ចំពោះការរំលោភសិទ្ធិទាំងនេះ។ ក្នុងករណីចំនួនពីរ ដែលគាំទ្រដោយអង្គការ បណ្តាញការងារស្ត្រីរួបរួមគ្នា (WNU) ស្ត្រីដែលបានដាក់ពាក្យបណ្តឹងទៅមន្ត្រីនគរបាលនៅភ្នំពេញ និងក្រុងព្រះសីហនុ អំពីអំពើហិង្សាដែលប្រព្រឹត្តដោយអតិថិជន ឬដៃគូ បានរាយការណ៍ថា សំណុំរឿងរបស់ខ្លួនត្រូវបានកត់ត្រាទុកជាកំណត់ហេតុ ប៉ុន្តែមិនមានការចាត់វិធានការនោះទេ។ មន្ត្រីនគរបាលបានត្រឹមតែណែនាំស្ត្រីទាំងនោះឱ្យទាក់ទងមកមន្ត្រីនគរបាល ប្រសិនបើពួកគាត់បានឃើញជនល្មើសម្តងទៀត ដែលធ្វើឱ្យពួកគាត់ត្រូវប្រឈមនឹងហានិភ័យនៃគ្រោះថ្នាក់ជាបន្តបន្ទាប់។

អ្នកប្រកបរបរផ្ទះភេទដែលជាអ្នកផ្លាស់ប្តូរយេនឌ័រ ក៏បានរាយការណ៍ពីការរើសអើង ការផាត់ចេញ ការកេងប្រវ័ញ្ច និងការព្រួយបារម្ភអំពីសុវត្ថិភាពកាន់តែខ្លាំងឡើង។ អ្នកប្រកបរបរផ្ទះភេទនៅខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យបានរាយការណ៍ពីការកើនឡើងនៃការរំលោភបំពានជាសាធារណៈ ការប្រមាថ និងការបៀតបៀន ក៏ដូចជាកង្វះការគាំពារពីអាជ្ញាធរមូលដ្ឋានថែមទៀតផង។

89 CEDAW Committee, above n 1, para. 29(a).

90 Ministry of Interior, "Safety village commune/Sangkat Policy Guideline", August 16, 2010, online: https://www.sithi.org/medias/files/projects/sithi/law/Village%20Commune%20Safety%20Policy%20(Eng)%20-%202010.pdf.

៩.៦ អំពើជួញដូរមនុស្ស និងទីតាំងឆបោកតាមអនឡាញ

អំពើជួញដូរមនុស្សក្នុងគោលបំណងធ្វើអាជីវកម្មកម្លាំងពលកម្ម នៅក្នុងឧស្សាហកម្មឆបោកនៅកម្ពុជា បានបន្តកើតមានពេញមួយឆ្នាំ ២០២៥។ ការប៉ាន់ប្រមាណបានបង្ហាញថា មនុស្សជាង ១៥០.០០០នាក់ ត្រូវបានឃុំខ្លួននៅតាមទីតាំងឆបោកបែបនេះ ដែលរកចំណូលបានចន្លោះពី ១២,៥ ទៅ ១៩ពាន់លានដុល្លារអាមេរិក ក្នុងមួយឆ្នាំ ស្មើនឹង៦០% នៃផលិតផលក្នុងស្រុកសរុប (GDP) របស់ប្រទេសកម្ពុជា។[91] ក្រុមអ្នកតាមដានបានរាយការណ៍ថា ចូលដល់ ឆ្នាំ២០២៥ មានការសាយភាយជាបន្តបន្ទាប់នៃទីតាំងទាំងនេះ ហើយបានរកឃើញទីតាំងជាង ២៥០កន្លែង ដែលមានភស្តុតាងបង្ហាញពីសកម្មភាពអនឡាញខុសច្បាប់។[92] ខណៈដែលជនរងគ្រោះភាគច្រើន ជាមនុស្សប្រុស ដែលត្រូវបានជួញដូរចូលឱ្យទៅបម្រើការងារក្នុងឧស្សាហកម្មនេះក្តី ប៉ុន្តែ ស្ត្រី ក្មេងស្រី និងក្មេងប្រុសក៏រងផលប៉ះពាល់ផងដែរ។

ការស្រាវជ្រាវដោយអង្គការលើកលែងទោសអន្តរជាតិ – ដែលបានសម្ភាសន៍ជាមួយអ្នកធ្លាប់រងគ្រោះចំនួន ៥៨នាក់ រួមមានបុរស និងក្មេងប្រុសចំនួន ៤៣នាក់ និងស្ត្រី និងក្មេងស្រីចំនួន ១៥នាក់ – បានរកឃើញថា អំពើជួញដូរមនុស្ស និងពលកម្មដោយបង្ខំ ពលកម្មកុមារ ការធ្វើទារុណកម្ម ការដកហូតសេរីភាព និងទាសភាព ប្រព្រឹត្តដោយក្រុមឧក្រិដ្ឋជនចាត់តាំង កំពុងកើតមានក្នុងទំហំ “ទ្រង់ទ្រាយធំ” ដោយចំណាត់ការពីរដ្ឋាភិបាល “មិនគ្រប់គ្រាន់សោះ”។[93]

បុរសម្នាក់បានរាយការណ៍ថា ពួកអ្នកបង្ខាំងគាត់បានគំរាមរំលោភបូកប្រពន្ធរបស់គាត់ ដែលត្រូវបានឃុំខ្លួន នៅក្នុងទីតាំងជាមួយគ្នាដែរ ប្រសិនបើគាត់មិនគោរពតាមបញ្ជារបស់គេទេនោះ។ របាយការណ៍បន្ទាប់ដោយអង្គការលើកលែងទោសអន្តរជាតិ បានចងក្រងឯកសារពីការរំលោភបំពានផ្លូវភេទពីសំណាក់អ្នកគ្រប់គ្រងទីតាំង រួមទាំងការរំលោភដែលធ្វើឱ្យស្ត្រីពីរនាក់មានផ្ទៃពោះផងដែរ។[94]

អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) ក៏បានកំណត់រកឃើញទំនាក់ទំនងរវាងប្រតិបត្តិការឆបោក និងការជំរិតកុមារដោយប្រើរូបភាពអាសអាភាស រួមទាំងការប្រើប្រាស់រូបភាពផ្លូវភេទរបស់កុមារ ដើម្បីបង្ខំពួកគាត់ឱ្យចូលរួមក្នុងទំនាក់ទំនងផ្លូវភេទផ្តល់រូបភាពបន្ថែម ឬផ្ទេរលុយកាក់ឱ្យទៅពួកគាត់ផងដែរ។ របាយការណ៍នេះក៏បានកត់សម្គាល់ផងដែរថា ស្ត្រីដែលត្រូវបានគេជួញដូរចូលទៅក្នុងទីតាំងឆបោក ត្រូវបានបង្ខំឱ្យផលិតមាតិកាផ្លូវភេទ ដើម្បីរួចផុតពីការធ្វើបាប។[95]

---

91 Jacob Sims (2025) “Policies and Patterns: State-Abetted Transnational Crime in Cambodia as a Global Security Threat”, Humanity Research Consultancy, online: https://www.humanity-consultancy.com/publications/policies-and-patterns-state-abetted-transnational-crime-in-cambodia-as-a-global-security-threat.

92 Cyber Scam Monitor, “Going Out East: Expansion of Scam Compounds on the Cambodia–Vietnam Border”, November 4, 2025, online: https://cyberscammonitor.substack.com/p/going-out-east-expansion-of-scam.

93 Amnesty International (2025) “‘I was someone else’s property’: Slavery, human trafficking and torture in Cambodia’s scamming compounds”, online: https://www.amnesty.org/en/documents/asa23/9447/2025/en/

94 Amnesty International, “Cambodia: Growing humanitarian crisis as escaped scamming compound survivors tell of murder, rape and torture”, January 27, 2026, online: https://www.amnesty.org/en/latest/news/2026/01/cambodia-growing-humanitarian-crisis-as-escaped-scamming-compound-survivors-tell-of-murder-rape-and-torture/.

95 IJM (2025) “A Potential Nexus Between Forced Scamming and the Financially-Motivated Sextortion of Children”, online: https://www.ijm.org/nexus-report.

របាយការណ៍វិភាគមួយនៅក្នុងឆ្នាំ ២០២៥ បានចាត់ទុកការបន្តវត្តមានរបស់ឧស្សាហកម្មឆបោកនៅកម្ពុជាថាអាចកើតឡើងដោយសារ "ការរាលដាលនៃអំពើពុករលួយ ការមានខ្នងបង្អែកពីរដ្ឋាភិបាល និងការសហការប្រព្រឹត្តរួមគ្នាដោយឥស្សរជនក្នុងជួរបក្ស"។[96] បើទោះបីជារដ្ឋាភិបាលបានចាត់ចែងឱ្យមាន "ការបង្ក្រាប" កាលពីខែកក្កដា ក្តីប៉ុន្តែក៏មិនបានតម្រង់ទៅរកគោលដៅទីតាំងធំៗ ដែលគេស្គាល់ ឬឥស្សរជនដែលមានខ្សែក្នុងជួរនយោបាយនោះទេ ហើយជនល្មើសមួយចំនួនត្រូវបានដោះលែង ឬអាចត្រូវបានជូនដំណឹងជាមុន។[97]

របាយការណ៍ស្តីពីអំពើជួញដូរមនុស្ស ឆ្នាំ២០២៥ របស់ក្រសួងការបរទេសសហរដ្ឋអាមេរិក បានបន្តចាត់ថ្នាក់ប្រទេសកម្ពុជានៅក្នុងលំដាប់ទី ៣ ដោយបញ្ជាក់ថា "ក្នុងប្រតិបត្តិការឆបោកតាមអនឡាញ មានគំរូលំនាំអំពើជួញដូរមនុស្សដោយរដ្ឋាភិបាល" ដែលក្នុងនោះមានមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ទទួលបានផលប្រយោជន៍ហិរញ្ញវត្ថុពីប្រតិបត្តិការនេះ ដូចជាតាមរយៈភាពជាម្ចាស់ឯកជននៃអចលនទ្រព្យ ដែលពួកគេប្រើប្រាស់សម្រាប់ធ្វើប្រតិបត្តិការ។[98] របាយការណ៍នេះបានកត់សម្គាល់ថាកម្ពុជាមិនដែលបានកាត់ទោសប្រតិបត្តិករ ឬម្ចាស់ទីតាំងឆបោកអនឡាញណាម្នាក់នោះទេ ទោះបីជាមានភស្តុតាងជាច្រើនក្តី។

នៅខែតុលា ឆ្នាំ២០២៥ សហរដ្ឋអាមេរិក និងចក្រភពអង់គ្លេស បានដាក់ទណ្ឌកម្មលើអង្គភាព និងបុគ្គលចំនួន ១៨៦ ដែលមានទំនាក់ទំនងជាមួយក្រុមហ៊ុនព្រីនស៍គ្រុប (Prince Group) មានមូលដ្ឋាននៅកម្ពុជា និងប្រធានក្រុមហ៊ុន គឺលោក ចេន ហ្ស៊ី (Chen Zhi) ដែលពេលនោះមានសញ្ជាតិកម្ពុជា ដែលការដាក់ទណ្ឌកម្មនេះ គឺដោយសារតែការធ្វើប្រតិបត្តិការ "អាណាចក្រឧក្រិដ្ឋកម្មឆ្លងដែនតាមរយៈការឆបោកការវិនិយោគតាមអនឡាញ"។ ចក្រភពអង់គ្លេសបានបង្កកទ្រព្យសម្បត្តិ រួមមានអចលនទ្រព្យចំនួន ១៩កន្លែង ហើយសហរដ្ឋអាមេរិកបានចោទប្រកាន់លោកចេន ហ្ស៊ី និងរឹបអូសយក Bitcoin គិតជាទឹកប្រាក់ប្រមាណ ១៥ពាន់លានដុល្លារអាមេរិក។[99] សហរដ្ឋអាមេរិកក៏បានកាត់ផ្តាច់ក្រុមហ៊ុន ហួយវ៉ែន គ្រុប (HuionGroup) ចេញពីប្រព័ន្ធហិរញ្ញវត្ថុរបស់សហរដ្ឋអាមេរិក ដោយសារក្រុមហ៊ុននេះ ដើរតួនាទីក្នុងការលាងសម្អាតលុយកខ្វក់។[100] លោកចេន ហ្ស៊ី ត្រូវបានធ្វើបណ្ឋាប័នទៅប្រទេសចិនវិញនៅខែមករា ឆ្នាំ២០២៦។[101]

96 Jacob Sims, above n 91.

97 Coby Hobbs and Khuon Narim, "Nationwide Raids Miss Key Scam Sites, Powerful Elites, Analysts Say", CamboJA News, July 17, 2025, online: https://cambojanews.com/nationwide-raids-miss-key-scam-sites-powerful-elites-analysts-say/.

98 U.S. Department of State, "2025 Trafficking in Persons Report: Cambodia", online: https://www.state.gov/reports/2025-trafficking-in-persons-report/cambodia/.

99 Lauren Turner and Osmond Chia, "Bitcoin worth $14bn seized in US-UK crackdown on alleged scammers", October 15, 2025, online: https://www.bbc.com/news/articles/c70jw436n0yo.

100 U.S. Department of the Treasury, "U.S. and U.K. Take Largest Action Ever Targeting Cybercriminal Networks in Southeast Asia", October 14, 2025, online: https://home.treasury.gov/news/press-releases/sb0278.

101 Simon Fraser, "Cambodia extradites alleged scam mastermind to China after arrest", BBC, January 8, 2026, online: https://www.bbc.com/news/articles/cy4q8e88n2vo

១០. ការងារ និងសិទ្ធការងារ

ការប្រែប្រួលនៃទិដ្ឋភាពសេដ្ឋកិច្ចពិភពលោក ព្រមជាមួយនឹងការបិទអាជីវកម្ម ក្នុងវិស័យទេសចរណ៍ និងវិស័យសំខាន់ៗផ្សេងទៀត បានធ្វើឱ្យប៉ះពាល់ដល់ជីវភាពរស់នៅរបស់ស្ត្រីកម្ពុជា។ ប្រាក់ឈ្នួលអប្បបរមាប្រចាំខែក្នុងវិស័យកាត់ដេរ ស្បែកជើង និងផលិតផលធ្វើដំណើរ ដែលក្នុងនោះកម្មករជាង ៧៥% ជាស្ត្រី ត្រូវបានកំណត់ត្រឹម ២០៨ដុល្លារអាមេរិក សម្រាប់ឆ្នាំ២០២៥។[102] កម្មករ និងសហជីពឯករាជ្យបានរាយការណ៍ថា ការដំឡើងប្រាក់ឈ្នួល ៤ដុល្លារអាមេរិក បើធៀបនឹងឆ្នាំមុននោះ គឺមិនគ្រប់គ្រាន់ ដើម្បីបំពេញតម្រូវការចំណាយលើការរស់នៅដែលកំពុងកើនឡើងនោះទេ ជាពិសេស នៅក្នុងបរិបទដែលអតិផរណាមានកម្រិតខ្ពស់។[103]

នៅខែសីហា ឆ្នាំ២០២៥ សហរដ្ឋអាមេរិកបានកំណត់យកពន្ធចំនួន ១៩% លើការនាំចូលពីប្រទេសកម្ពុជា។ ទោះបីជា ៣៣% នៃការនាំចេញរបស់កម្ពុជា គឺទៅកាន់សហរដ្ឋអាមេរិកក្តី ប៉ុន្តែធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានវាយតម្លៃថា ពន្ធគយនេះនឹងមាន “ផលប៉ះពាល់តិចតួចប៉ុណ្ណោះ” ទៅលើវិស័យសេដ្ឋកិច្ចសំខាន់ៗ។ ទោះជាយ៉ាងណា ធនាគារនេះបានព្រមានថា បរិយាកាសគោលនយោបាយពាណិជ្ជកម្មសកល “មិននឹងនរ” បានធ្វើឱ្យប្រទេសកម្ពុជាងាយរងហានិភ័យសេដ្ឋកិច្ចសង្គមធ្ងន់ធ្ងរ។[104]

១០.១ ការទទួលបានកិច្ចគាំពារសង្គមក្នុងចំណោមកម្មករក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ

ស្ត្រីដែលធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ បានបន្តជួបនឹងបញ្ហាប្រឈម និងការរើសអើងខ្លាំងនៅ ឆ្នាំ២០២៥ ទោះបីជា គណៈកម្មាធិការ ស៊ី-ដ បានផ្តល់អនុសាសន៍ថា ឱ្យធានាឱ្យបានទូលំទូលាយនូវកិច្ចការពារប្រកបដោយប្រសិទ្ធភាពចំពោះសិទ្ធិរបស់ស្ត្រី ដែលបម្រើការងារក្នុងវិស័យក្រៅប្រព័ន្ធនោះ។[105]

សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA) បានសង្កេតឃើញថា អ្នកធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ជាពិសេសអ្នកលក់ដូរតាមចិញ្ចើមផ្លូវ ជារឿយៗតែងជួបប្រទះនឹងការរើសអើងពីសំណាក់អាជ្ញាធរមូលដ្ឋាន និងនៅក្នុងសហគមន៍របស់ខ្លួន ក៏ដូចជាការលំបាកក្នុងការទទួលបានកម្មវិធីគាំពារសង្គម។

102 UNDP, “Retaining Women in Cambodia’s Workforce After LDC Graduation”, March 14, 2025, online: https://www.undp.org/cambodia/blog/retaining-women-cambodias-workforce-after-ldc-graduation#:~:text=In%202024%2C%20the%20garment%2C%20textiles,benefiting%20around%203%20million%20persons.

103 Sovann Sreypich, “Garment Workers’ Minimum Wage Raised To $208 for 2025, Employees Say It’s Too Little, September 19, 2024, online: https://cambojanews.com/garment-workers-minimum-wage-raised-to-208-for-2025-employees-say-its-too-little/.

104 Asian Development Bank, “Economic Impacts of the United States Tariff on Cambodia”, November 2025, online: www.adb.org/sites/default/files/publication/1095941/adb-brief-360-us-tariff-cambodia.pdf.

105 CEDAW Committee, above n 1, para. 37(b).

មូលនិធិជាតិជំនួយសង្គម (NSAF) ដែលត្រូវបានបង្កើតឡើងក្នុង ឆ្នាំ២០២២ មានបំណងជួយគាំទ្រដល់ប្រជាពលរដ្ឋ មានហានិភ័យ តាមរយៈកម្មវិធីផ្សេងៗដូចជា ការផ្តល់ប្រាក់ឧបត្ថម្ភ សេវាថែទាំសុខភាព និងការឧបត្ថម្ភធន ក្នុងបំណងកាត់បន្ថយភាពក្រីក្រ និងកែលម្អស្ថានភាពរស់នៅ។ ក្នុងការអនុវត្តជាក់ស្តែង ការទទួលបានអត្ថប្រយោជន៍ពីមូលនិធិជាតិជំនួយសង្គម (NSAF) ត្រូវបានរឹតត្បិត ដោយសារលក្ខខណ្ឌចុះឈ្មោះតឹងរ៉ឹង។ អ្នកដាក់ពាក្យសុំ ត្រូវតែមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងបណ្ណសមធម៌ដែលមានសុពលភាព ដែលត្រូវបានចាត់ថ្នាក់ថា “ក្រីក្រកម្រិតទី ១” ឬ “ក្រីក្រកម្រិតទី ២” ដើម្បីអាចចុះឈ្មោះសម្រាប់ជំនួយគាំទ្រ។ លក្ខខណ្ឌតម្រូវទាំងនេះបង្កជាឧបសគ្គធំ ចំពោះស្ត្រីនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលជារឿយៗខ្វះឯកសារតម្រូវ ឬមិនមានការទទួលស្គាល់ដោយអាជ្ញាធរ។ នៅខែកក្កដា ឆ្នាំ២០២៥ លោកនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត ក៏បានបដិសេធសំណើមួយ ដើម្បីពង្រីកកម្មវិធីបេឡាជាតិរបបសន្តិសុខសង្គម (NSSF) ដើម្បីគ្របដណ្តប់ប្រជាពលរដ្ឋដែលមានអាយុ ៦០ឆ្នាំ ឡើងទៅផងដែរ ដោយលើកឡើងពីកង្វះថវិកា។[106]

អ្នករើសអេតចាយត្រូវបានបដិសេធមិនឱ្យទទួលបានកិច្ចគាំពារសង្គម ហើយបានស្លាប់នៅពេលកំពុងស្នើសុំជំនួយ

ស្ត្រីជាអ្នករើសអេតចាយអាយុ ៦១ឆ្នាំម្នាក់ នៅទីក្រុងភ្នំពេញ បានរងការរើសអើងជាបន្តបន្ទាប់ពីសំណាក់សហគមន៍ និងមន្ត្រីមូលដ្ឋានរបស់ខ្លួន។ បើទោះបីជាមានមនុស្សក្នុងបន្ទុកច្រើននាក់ និងបញ្ហាសុខភាពក្តីម្តងហើយម្តងទៀត អាជ្ញាធរបានបដិសេធសំណើររបស់គាត់ ដែលបានស្នើសុំសៀវភៅស្គាល់នៅ អត្តសញ្ញាណបណ្ណ និងការចុះឈ្មោះក្នុងកម្មវិធី បេឡាជាតិរបបសន្តិសុខសង្គម (បសស)។ នៅខែមករា ឆ្នាំ២០២៥ អំឡុងពេលមានការអបអរពិធីបុណ្យចូលឆ្នាំចិន គាត់បានរង់ចាំនៅខាងក្រៅផ្ទះឧកញ៉ាម្នាក់ ដើម្បីទទួលបានអាហារ និងលុយកាក់ ដែលជាការផ្តល់អំណោយជាប្រពៃណី។ ស្ត្រីរូបនោះ ជាមនុស្សម្នាក់ក្នុងចំណោមមនុស្សបួននាក់ ដែលបានស្លាប់បាត់បង់ជីវិតដោយសារការជាន់គ្នាក្នុងចំណោមហ្វូងមនុស្ស។[107]

ស្ត្រីអាជីវករតាមចិញ្ចើមផ្លូវវ័យចំណាស់ម្នាក់រងរបួស និងទុកចោលគ្មានអ្នកជួយ

អាជីវករតាមចិញ្ចើមផ្លូវអាយុ ៧២ឆ្នាំម្នាក់ ដែលជាអ្នកលក់ផ្លែឈើអស់រយៈពេល ១៥ឆ្នាំមកហើយនោះ លៃងអាចរកស៊ីបានទៀតហើយក្រោយពេលរងរបួសជើង និងស្មាធ្ងន់ធ្ងរ ក្នុងហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍មួយក្នុងឆ្នាំ២០២៥។ ដោយសារតែវ័យរបស់គាត់ គាត់មិនត្រូវលក្ខខណ្ឌក្នុងការចុះឈ្មោះក្នុងកម្មវិធី បសស បានឡើយ ដែលធ្វើឱ្យគាត់មិនអាចទទួលបានជំនួយ និងសេវាថែទាំសុខភាពពីរដ្ឋាភិបាល។ អវត្តមាននៃកិច្ចគាំពារសង្គម គួបផ្សំនឹងការរើសអើងពីសំណាក់អ្នកផ្តល់សេវាសុខភាព ការបាត់បង់មុខរបរ និងតម្រូវការការថែទាំសុខភាពចំពោះជំងឺ ភ្ជាប់ផ្ទាល់ នោះ បានប៉ះពាល់ធ្ងន់ធ្ងរដល់គុណភាពជីវិតរបស់គាត់។

ស្ត្រីក្នុងវិស័យក្រៅប្រព័ន្ធ បានអំពាវនាវឱ្យមានការពង្រីកកិច្ចគាំពារសង្គម រួមមានការធានារ៉ាប់រងសុខភាព របបសន្តិសុខសង្គម កម្មវិធីកាត់បន្ថយភាពក្រីក្រ និងអាហារូបករណ៍សម្រាប់កូនៗរបស់ពួកគាត់។ ពួកគាត់ក៏បានជំរុញឱ្យរដ្ឋាភិបាល និងអាជ្ញាធរពាក់ព័ន្ធកែលម្អលទ្ធភាពទទួលបានឯកសារ ដូចជាអត្តសញ្ញាណប័ណ្ណ សំបុត្រកំណើត និងសៀវភៅស្គាល់នៅ ជាពិសេសសម្រាប់អ្នកដែលគ្មានលំនៅដ្ឋានជាប់លាប់។

106 Chhorn Raksmey, “Call to Extend NSSF to Elderly Turned Down by PM”, Kiripost, June 3, 2025, online: https://kiripost.com/stories/call-to-extend-nssf-to-elderly-turned-down-by-pm.

107 “Lunar New Year giveaway of cash and food leaves 4 dead in Cambodian capital as crowd surges”, Associated Press, January 23, 2025, online: https://apnews.com/article/cambodia-crowd-crush-killed-sok-kong-facdf0652f008fa1695283aae9f49078.

១០.២ ការរើសអើងនៅកន្លែងធ្វើការ

ប្រទេសកម្ពុជា មិនទាន់បានអនុម័តច្បាប់ប្រឆាំងការរើសអើងគ្រប់ជ្រុងជ្រោយនៅឡើយទេ ទោះបីជាមានអនុសាសន៍ពីគណៈកម្មាធិការស៊ី-ដ ឱ្យអនុម័តច្បាប់នេះក្តី[108] ដែលបញ្ហានេះប្រៀបបាននឹងការបង្កើតបរិយាកាសអំណោយផលដល់ទម្លាប់ជួលកម្លាំងពលកម្ម ដោយមានការរើសអើងការបញ្ឈប់ពីការងារដោយអយុត្តិធម៌ និងការបៀតបៀននៅកន្លែងធ្វើការ។

ស្ត្រី ជាពិសេសស្ត្រីមានពិការភាព និងសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា (LGBTIQ+) បានរាយការណ៍ពីការរំលោភបំពានលើរាងកាយ និងពាក្យសម្តីនៅតាមបណ្តារោងចក្រកាត់ដេរ និងវិស័យកម្សាន្ត ក្នុងកម្រិតផ្សេងៗគ្នា។ កម្មករមានផ្ទៃពោះ និងកម្មករមានពិការភាព ក៏បានជួបប្រទះនឹងទម្លាប់ជួលកម្លាំងពលកម្មដោយមានការរើសអើង និងការបញ្ឈប់ពីការងារតាមអំពើចិត្តផងដែរ ដែលបណ្តាលមកពីការប្រើប្រាស់ខុសជាបន្តបន្ទាប់ នូវកិច្ចសន្យាការងារមានថេរវេលាកំណត់។ អាកប្បកិរិយាសង្គមដែលមានការរើសអើងចំពោះយេនឌ័រ និងភាពចម្រុះក៏នៅតែកើតមានច្រើនផងដែរ ដោយក្នុងនោះ សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា (LGBTIQ+) ជាច្រើននាក់នៅតែបន្តជួបប្រទះនឹងការរើសអើងនៅក្នុងទីផ្សារការងារផ្លូវការដដែល ក្នុងឆ្នាំ២០២៥។

ការទទួលបានធនធានហិរញ្ញវត្ថុ និងសេវាធនាគារកិច្ចប្រកបដោយបរិយាបន្ន ក៏នៅតែមានការរិតត្បិតផងដែរ ដែលជាការបង្កើតឧសគ្គបន្ថែមទៀតដល់សហគមន៍ LGBTIQ+ ដែលមានបំណងចាប់ផ្តើម ឬចង់ពង្រីកអាជីវកម្មរបស់ខ្លួន។ ជាលទ្ធផលមានមនុស្សមួយចំនួនរាយការណ៍ថា ត្រូវបានរុញច្រានឱ្យធ្លាក់ចូលទៅក្នុងទម្រង់ការងារក្រៅប្រព័ន្ធគ្មានសុវត្ថិភាព ឬមិនស្ថិតស្ថេរ ដែលក្នុងនោះ ការកេងប្រវ័ញ្ចគឺជារឿងធម្មតាទៅហើយ ហើយកិច្ចគាំពារផ្នែកច្បាប់ និងសង្គមមានតិចតួចប៉ុណ្ណោះ។

108 CEDAW Committee, above n 1, para. 9(a).

១០.៣ សិទ្ធិការងាររបស់អ្នកប្រករបរផ្លូវភេទ និងអ្នកធ្វើការនៅគ្រឹះស្ថានសេវាកម្សាន្ត

អ្នកប្រករបរផ្លូវភេទ និងអ្នកធ្វើការនៅគ្រឹះស្ថានសេវាកម្សាន្តបានរាយការណ៍ថា មានភាពអសន្តិសុខផ្នែកមុខរបរជាបន្តបន្ទាប់ពេញមួយឆ្នាំ រួមទាំងការបាត់បង់ការងារ ចំណាយក្នុងការរស់នៅ និងបំណុលកើនឡើង កន្លែងស្នាក់នៅមិនជាប់លាប់ និងសម្ពាធឱ្យធ្វើចំណាកស្រុក។ ការបិទអាជីវកម្មក្នុងវិស័យទេសចរណ៍ បានបន្តធ្វើឱ្យប៉ះពាល់ដល់ជីវភាពរស់នៅ។ ដូចបណ្តាឆ្នាំមុនៗដែរ កម្សោយនៃការអនុវត្តស្តង់ដារការងារ និងលក្ខខណ្ឌការងារបែបកេងប្រវ័ញ្ច គឺមានលក្ខណៈជាប្រព័ន្ធ និងបានក្លាយជារឿងធម្មតាទៅហើយនៅក្នុងវិស័យកម្សាន្ត ដែលធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពរបស់កម្មករ ក្នុងការផ្លាស់ទៅកន្លែងការងារ ដែលផ្តល់លក្ខខណ្ឌការងារល្អជាងនេះ។

អង្គការបណ្តាញការងារស្ត្រីរួបរួមគ្នា (WNU) បានចុះទៅមើលទីតាំងផ្តល់សេវាកម្សាន្តចំនួន ៨០កន្លែង ក្នុងខែមេសា និងខែឧសភា ឆ្នាំ២០២៥ នៅទូទាំងរាជធានីភ្នំពេញ ខេត្តកណ្តាល សៀមរាប និងបន្ទាយមានជ័យ។ ទីតាំងទាំងនោះបានជួលកម្មករប្រមាណ ១.៨៨២នាក់ និងមានខាវ៉ាអូខេចំនួន ២៦ទីតាំង ភោជនីយដ្ឋានចំនួន ៣០កន្លែង ហាងខាវ៉ាអូខេមានភោជនីយដ្ឋានរួមគ្នាចំនួន១៦ ផាប់ចំនួន៤ ក្លឹបចំនួន២ និងបៀហ្គាឌិនចំនួន២។ អង្គការបណ្តាញការងារស្ត្រីរួបរួមគ្នា (WNU) បានរកឃើញថា កម្មករជាច្រើនគ្មានកិច្ចសន្យាការងារ អត្ថប្រយោជន៍ និងការការពារសិទ្ធិការងារនោះឡើយ។ ប្រាក់ឈ្នួលប្រចាំខែភាគច្រើន គឺចន្លោះពី ៤ ដុល្លារអាមេរិក ដល់ ១០០ដុល្លារអាមេរិក ក្នុងមួយខែ ដោយក្នុងនោះការងារបន្ថែមម៉ោងគ្មានប្រាក់ឈ្នួល គឺជារឿងទូទៅទៅហើយ ហើយកម្មករពឹងផ្អែកយ៉ាងខ្លាំងទៅលើលុយទឹកតែពីអតិថិជន។

អង្គការទ្រទ្រង់ស្ត្រីខ្មែរ (COWS) ក៏បានធ្វើការស្រាវជ្រាវខ្នាតតូចមួយនៅ ឆ្នាំ២០២៥ ស្តីពីបទពិសោធន៍របស់ស្ត្រី និងក្មេងស្រីដែលធ្វើការនៅក្នុងខាវ៉ាអូខេ និងភោជនីយដ្ឋាន។[109] ក្នុងចំណោមមនុស្ស ១៦៥នាក់ ដែលត្រូវបានស្ទង់មតិ អង្គការទ្រទ្រង់ស្ត្រីខ្មែរ (COWS) បានកំណត់រកឃើញក្មេងស្រីជ្រាំបួននាក់អាយុក្រោម ១៨ឆ្នាំ ដែលធ្វើការនៅក្នុងទីតាំងផ្តល់សេវាកម្សាន្ត។ ស្ត្រីជាច្រើនបានរាយការណ៍អំពីការបៀតបៀន និងបំបាក់មុខ ជាពិសេសពីសំណាក់អតិថិជន។ ទាំងស្ត្រី និងបុរស បានរាយការណ៍ថា ការទទួលបានព័ត៌មានសុក្រឹតអំពីសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ គឺនៅមានកម្រិត ហើយជារឿយៗពឹងផ្អែកខ្លាំងលើប្រព័ន្ធផ្សព្វផ្សាយសង្គមដើម្បីទទួលបានព័ត៌មាន។ មនុស្សមួយចំនួនបានបង្ហាញពីការយល់ដឹងនៅមានកម្រិត ឬការប្រើប្រាស់តិចតួចនូវស្រោមអនាម័យ ឬការពន្យាកំណើតដោយលើកឡើងថា ភាពខ្មាសអៀន ការព្រួយបារម្ភចំពោះអាកប្បកិរិយារបស់អ្នកផ្តល់សេវា និងការរក្សាការសម្ងាត់ គឺជាឧបសគ្គដែលរារាំងដល់ការចូលទៅប្រើសេវាថែទាំសុខភាព។

109 Information provided by COWS.

១១.

ការថែទាំសុខភាព

១១.១ សុខភាពផ្លូវភេទ និងបន្តពូជ និងសិទ្ធិផ្សេងៗ

0%
នាយកមន្ទីរពេទ្យខេត្តជាស្ត្រី

៨%
នាយកមន្ទីរពេទ្យជាតិជាស្ត្រី

២៣%
គ្រូពេទ្យទូទៅជាស្ត្រី

២២%
វេជ្ជបណ្ឌិតឯកទេសជាស្ត្រី

២៦%
ប្រធានមណ្ឌល សុខភាពជាស្ត្រី

ប្រទេសកម្ពុជា ត្រូវសម្រេចឱ្យបាននូវវឌ្ឍនភាព ឆ្ពោះទៅរកការធានាថាស្ត្រី ក្មេងស្រី និងអ្នកមិនកំណត់អត្តសញ្ញាណភេទស្រី ឬប្រុសទាំងអស់នៅកម្ពុជា អាចទទួលបានសេវា និងព័ត៌មានសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ ដូចដែលគណៈកម្មាធិការ ស៊ី-ដ បានផ្តល់អនុសាសន៍។[110] គម្លាតនៅតែបន្តកើតមានដដែល ទាក់ទងនឹងការអប់រំ វត្តមាននៃសេវាកម្ម និងការយល់ដឹងរបស់មហាជន ជាពិសេសក្នុងចំណោមក្រុមមនុស្សដែលគេផាត់ចោលមួយចំនួន។ ក្នុងវិស័យសុខាភិបាល ស្ត្រីនៅតែមានតំណាងតិចតួចដដែលគិតត្រឹម ឆ្នាំ២០២៤ ដែលក្នុងនោះគ្រូពេទ្យទូទៅជាស្ត្រីមានចំនួនត្រឹមតែ ២៣% វេជ្ជបណ្ឌិតឯកទេសជាស្ត្រីមាន ២២% គិលានុបដ្ឋាកដែលមានសញ្ញាប័ត្របរិញ្ញាបត្រគឺមានស្ត្រីចំនួន ៤១% នាយកមន្ទីរពេទ្យជាតិជាស្ត្រីមានចំនួន ៨% នាយកមន្ទីរពេទ្យខេត្តជាស្ត្រីមាន ០% ហើយប្រធានមណ្ឌលសុខភាពជាស្ត្រីមានចំនួន ២៦%។[111]

ការធានាឱ្យបានថា កុមារ និងយុវជន មានលទ្ធភាពទទួលបានការអប់រំផ្លូវភេទគ្រប់ជ្រុងជ្រោយ (CSE) នៅតែជាការងារដែលត្រូវខិតខំប្រឹងប្រែងបន្តទៀតក្នុង ឆ្នាំ២០២៥។ តាមរយៈការងាររបស់ខ្លួននៅក្នុងខេត្តសៀមរាប និងខេត្តកំពត អង្គការវ៉ាក់ (RHAC) បានរកឃើញថាការផ្តល់ការអប់រំផ្លូវភេទគ្រប់ជ្រុងជ្រោយ (CSE) ប្រកបដោយស្តង់ដារគឺនៅតែមានកម្រិតនៅឡើយ។ គ្រូបង្រៀនច្រើនតែស្ទាក់ស្ទើរក្នុងការបង្រៀនខ្លឹមសារសំខាន់ៗមួយចំនួន នៃកម្មវិធីសិក្សាដោយសារ តែច្បាប់ទម្លាប់វប្បធម៌បច្ចុប្បន្ន និងការអាម៉ាស ដែលធ្វើឱ្យប៉ះពាល់ដល់លទ្ធភាពរបស់យុវជន ក្នុងការទទួលបានព័ត៌មានសុក្រឹត និងពេញលេញ។

ប្រទេសកម្ពុជាបានបន្តការងារខិតខំប្រឹងប្រែង ដើម្បីកាត់បន្ថយទម្លាប់រំលូតកូនគ្មានសុវត្ថិភាពស្របតាមច្បាប់ស្តីពីការរំលូតកូន ឆ្នាំ១៩៩៧។ ទោះជាយ៉ាងណា ការដឹងថាការរំលូតកូនជារឿងស្របច្បាប់ និងទំនុកចិត្តក្នុងការទទួលបានសេវាទាំនេះ នៅតែមានកម្រិតផងដែរ។ ការស្រាវជ្រាវដោយអង្គការវ៉ាក់ (RHAC) និងអង្គការក្លាហាន បានកំណត់រកឃើញឧបសគ្គជាបន្តបន្ទាប់ដែលរាវាំងដល់សេវារំលូតកូនមានសុវត្ថិភាព។ នៅក្នុងការវាយតម្លៃរហ័សមួយដែលធ្វើឡើងដោយអង្គការ វ៉ាក់ (RHAC) នៅខេត្តសៀមរាប រកឃើញថា ក្នុងចំណោមស្ត្រីចំនួន ១៧១នាក់ដែលត្រូវបានសម្ភាសន៍ មានតែ ៤៧%ប៉ុណ្ណោះ ដឹងថាការរំលូតកូន គឺជារឿងស្របច្បាប់នៅក្នុងប្រទេសកម្ពុជា។[112] ការពុំសូវមើលឃើញពីសេវារំលូតកូននៅតាមគ្រឹះស្ថានសាធារណៈ នៅតែជាឧបសគ្គ ជាពិសេសសម្រាប់ស្ត្រីចំណាកស្រុក និងស្ត្រីដែលមានកម្រិតវប្បធម៌ទា។ ក្នុងចំណោមអ្នកចូលរួមការស្ទង់មតិ មានជិតពាក់កណ្តាលបានរាយការណ៍ថា ពិបាកក្នុងអារម្មណ៍ក្នុងការពិភាក្សាអំពីការរំលូតកូន ដោយសារការប្រមាថមាក់ងាយក្នុងសង្គម និងការរំពឹងចង់ឱ្យមានការចូលរួមពីដៃគូក្នុងការសម្រេចចិត្ត ដែលទាំងនេះជាការរិតត្បិតលើស្ថ័យភាពរាងកាយរបស់ស្ត្រី។

110 CEDAW Committee, above n 1, para. 39(a)-(b).

111 Ministry of Women's Affairs, Ministry of Health, and National Institute of Statistics, "Policy Brief: Promote women roles in leadership and governance in the health sector", June 2024, online: https://www.nis.gov.kh/nis/Policy_Brief/G5_D2P_Policy_Brief_Eng%2005_10_2024.pdf.

112 RHAC (2025) "Rapid Assessment for Increase Access to Safe Abortion Services Project, Implemented by RHAC in Kralanh OD, Siem Reap Province".

ការស្រាវជ្រាវរបស់អង្គការ ក្លាហាន ដែលផ្អែកលើការសម្ភាសមនុស្ស ១៥នាក់ និងការស្ទង់មតិតាមអនឡាញជាមួយអ្នកចូលរួមចំនួន ១២២នាក់ បានរកឃើញស្រដៀងគ្នានេះដែរថា លទ្ធភាពទទួលបានសេវារំលូតកូនមានសុវត្ថិភាព តម្លៃសមរម្យ និងប្រកបដោយគុណភាព នៅតែមានកម្រិតមិនស្មើគ្នាដដែល។[113] តាមការរាយការណ៍ សេវានេះមិនសូវអាចរកបានទេនៅតាមទីជនបទ ហើយអ្នកផ្តល់សេវាមួយចំនួន តាមការរាយការណ៍ គឺទាមទារឱ្យមានការចុះហត្ថលេខាពីស្វាមី ដែលបង្កើតជាឧបសគ្គបំពានមួយដែលរារាំងដល់ការទទួលបានការថែទាំសុខភាព។ ការសិក្សានេះបានរកឃើញបន្ថែមទៀតថា ភាពមានកម្រិតនៃការយល់ដឹងរបស់មហាជនអំពីភាពស្របច្បាប់នៃការរំលូតកូន គួបផ្សំនឹងច្បាប់ទម្លាប់សង្គម ដែលភ្ជាប់ការរំលូតកូនទៅនឹងភាពអាម៉ាស់ និងទុរយសដែលភាគច្រើនគឺជាប់ទាក់ទងនឹងជំនឿសាសនា អ្នកតា រឫធម៌ឱ្យតម្លៃលើព្រហ្មចារី និងច្បាប់ទម្លាប់ប្រពៃណីផ្សេងទៀតនោះ បានបន្តធ្វើឱ្យប៉ះពាល់ដល់លទ្ធភាពរបស់ស្ត្រី និងក្មេងស្រីក្នុងការទទួលបានសេវាទាំងនោះ។ ស្ត្រីមួយចំនួនត្រូវបានគេរាយការណ៍ថា បានធ្វើដំណើរឆ្ងាយពីសហគមន៍របស់ខ្លួន ដើម្បីការពារឯកជនភាពរបស់ខ្លួន។

ទស្សនៈយល់ឃើញ និងការអត់ឱនចំពោះការរំលូតកូន គឺមានកម្រិតខុសគ្នាទៅតាមទីតាំង អាយុ យេនឌ័រ និងហេតុផលដែលយល់ឃើញនៅពីក្រោយការស្វែងរកការរំលូតកូន។ បញ្ហាហានិភ័យសុខភាពចំពោះស្ត្រីត្រូវបានទទួលយកយ៉ាងទូលំទូលាយថា ជាហេតុផលសម្រាប់ការរំលូតកូន ជាងហេតុផលផ្សេងៗទៀត ដូចជាការមិនចង់មានកូនក្នុងពេលជាក់លាក់ណាមួយ។ អ្នកឆ្លើយតបជាងពាក់កណ្តាលជឿថាការរំលូតកូនគ្មានសុវត្ថិភាពនៅតែមានច្រើន ជាពិសេសក្នុងចំណោមស្ត្រីវ័យក្មេង និងស្ត្រីមិនទាន់រៀបការ។ អង្គការ ក្លាហាន បានផ្តល់អនុសាសន៍ឱ្យធ្វើប្រក្រតីកម្មការរំលូតកូនជាសិទ្ធិបន្តពូជ តាមរយៈការបង្កើនការអប់រំសាធារណៈ ការបង្កើនលទ្ធភាពទទួលបានព័ត៌មាន និងការបង្កើនវត្តមានសេវារំលូតកូនដែលមានគុណភាព និងសុវត្ថិភាព។

ប្រទេសកម្ពុជាបានខិតខំប្រឹងប្រែងខ្លះៗផងដែរ ដើម្បីផ្សព្វផ្សាយសារជាសាធារណៈស្តីពីសេវារំលូតកូនដោយសុវត្ថិភាព។ កាលពីខែមិថុនា ឆ្នាំ២០២៥ រដ្ឋមន្ត្រីក្រសួងព័ត៌មាន លោកនេត្រ ភក្ត្រា បានសង្កត់ធ្ងន់លើតួនាទីរបស់ប្រព័ន្ធផ្សព្វផ្សាយក្នុងការចែករំលែកព័ត៌មានយ៉ាងទូលំទូលាយ ស្តីពីការរំលូតកូនដោយសុវត្ថិភាព និងការរៀបចំផែនការគ្រួសារ ដែលការលើកឡើងនេះធ្វើឡើងក្នុងសិក្ខាសាលាមួយដែលមានគោលបំណង ណែនាំភាគីពាក់ព័ន្ធឱ្យចែករំលែកព័ត៌មានជាមួយយុវជនអំពីការអនុវត្តការរំលូតកូនដោយសុវត្ថិភាព និងទប់ស្កាត់ការប្រមាថមាក់ងាយពីសង្គម និងការរើសអើងក្នុងសង្គមក្នុងសហគមន៍។[114]

ជាចុងក្រោយ ប្រទេសកម្ពុជាសម្រេចបានវឌ្ឍនភាពមួយចំនួនឆ្ពោះទៅរកការអនុវត្តតាមអនុសាសន៍របស់គណៈកម្មាធិការ ស៊ី-ដ ដែលណែនាំឱ្យមានការធានាបាននូវលទ្ធភាពទទួលបានសេវាប្រឹក្សាយោបល់ ការធ្វើតេស្ត និងការព្យាបាលសម្រាប់មេរោគអេដស៍ដោយស្ម័គ្រចិត្ត និងដោយសម្ងាត់។[115] តាមរយៈគម្រោងទប់ស្កាត់មេរោគអេដស៍/ជំងឺអេដស៍ ដែលអនុវត្តនៅក្នុងខេត្តភាគខាងជើងចំនួន ១៣ខេត្ត អង្គការ រ៉ាក់ (RHAC) បានកត់ត្រាអ្នកប្រើប្រាស់ PrEP (ថ្នាំបង្ការមេរោគអេដស៍) ចំនួន ៨.៨១៦នាក់ បានធ្វើតេស្តមេរោគអេដស៍ចំនួន ៥១.០៣៥នាក់ និងរកឃើញករណីអ្នកផ្ទុកមេរោគអេដស៍ថ្មីចំនួន ៥០៣ករណី គិតត្រឹមខែសីហា ឆ្នាំ២០២៥។

113 Klahaan (2025) "My Body, My Choice: A Short Study of Societal Perceptions on Abortion and Women's Reproductive Rights in Cambodia", online: https://56dd158a-1ed4-4131-9020-9d0718381f08.filesusr.com/ugd/091c7d_b53c5e3f17fc459283e22a9c4ea1c5cf.pdf.

114 "The media's crucial role in safe abortion education stressed", Khmer Times, June 5, 2025, online: https://www.khmertimeskh.com/501695457/the-medias-crucial-role-in-safe-abortion-education-stressed/.

115 CEDAW Committee, above n 1, para. 39(a).

១១.២ ការថែទាំសុខភាពផ្លូវចិត្ត

អង្គការលើកកម្ពស់គុណភាពជីវិត (WELL) បានស្រាវជ្រាវអំពីលទ្ធភាពក្នុងការទទួលបានការគាំទ្រសុខុមាលភាពផ្លូវចិត្ត និងអារម្មណ៍ដោយឥតគិតថ្លៃនៅក្នុងទីក្រុងភ្នំពេញ សម្រាប់ស្ត្រីដែលបានជួបប្រទះអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដោយផ្តោតសំខាន់លើកម្មកររោងចក្រ អ្នកធ្វើការតាមផ្ទះ និងអ្នកលក់ដូរតាមចិញ្ចឹមផ្លូវ។[116] ការសិក្សានេះបានផ្អែកលើការសម្ភាសន៍ជាមួយស្ត្រីចំនួន ២០នាក់ ដែលធ្លាប់បានជួបប្រទះអំពើហិង្សា ការស្ទង់មតិអនឡាញជាមួយមហាជនចំនួន ១០៤នាក់ ការពិភាក្សាជាក្រុមជាមួយស្ត្រីចំនួនប្រាំបីនាក់ និងការសម្ភាសន៍ជាមួយមេដឹកនាំអង្គការសង្គមស៊ីវិលចំនួនប្រាំនាក់។

ការស្រាវជ្រាវនេះបានរកឃើញថា វត្តមាននៃសេវាគាំទ្រសុខភាពផ្លូវចិត្ត និងចិត្តសង្គមដោយឥតគិតថ្លៃបានកើនឡើងក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ដែលសេវាទាំងនោះផ្តល់ដោយតួអង្គរដ្ឋាភិបាលផង និងសង្គមស៊ីវិលផង។ សេវាដែលបានផ្តល់ រួមមានការប្រឹក្សាជាលក្ខណៈបុគ្គល ការព្យាបាលជាក្រុម ក្រុមមិត្តជួយមិត្ត ទូរស័ព្ទទាន់ហេតុការណ៍ (ដូចជាទូរស័ព្ទទាន់ហេតុការណ៍លេខ ១២៨០ ជាដើម) និងកម្មវិធីទូរស័ព្ទ (រួមមានកម្មវិធី សុវត្ថិភាពយើង ឬGBV Safe App)។ ទោះជាយ៉ាងណា វត្តមាននៃសេវានៅតែប្រមូលផ្តុំនៅកណ្តាលក្រុង ហើយជារឿយៗពឹងផ្អែកលើការផ្តល់មូលនិធិជំនួយរយៈពេលខ្លី ឬមិនជាប់លាប់សម្រាប់កម្មវិធីសង្គមស៊ីវិល។

ការយល់ដឹង និងការទទួលយកសេវានៅតែមានកម្រិតទាបនៅឡើយក្នុងចំណោមមហាជន និងក្នុងចំណោមស្ត្រីដែលធ្លាប់ជួបប្រទះអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ អ្នកចូលរួមតិចតួចណាស់ដែលបានដឹង អំពីលេខទូរស័ព្ទទាន់ហេតុការណ៍ ឬកម្មវិធីទូរស័ព្ទដែលមានបច្ចុប្បន្ន ហើយអ្នកដែលបានប្រើប្រាស់មានរិតតែតិចទៅទៀត។ ផ្ទុយទៅវិញ ស្ត្រីភាគច្រើនពឹងផ្អែកលើយុទ្ធសាស្ត្រដោះស្រាយខ្លួនឯង បន្ទាប់មកគឺប្រភពក្រៅផ្លូវការសម្រាប់ជំនួយគាំទ្រផ្លូវចិត្តដូចជាមិត្តភក្តិ មេដឹកនាំសហជីព ឬសមាគម និងការបង្រៀនអប់រំផ្លូវចិត្តតាមអនឡាញ។ ឧបសគ្គដែលរារាំងដល់ការទទួលបានសេវាផ្លូវការរួមមាន វប្បធម៌ មាក់ងាយ៣ក់ព័ន្ធនឹងការស្វែងរកការជួយ ការភ័យខ្លាចចំពោះការវិនិច្ឆ័យ ការព្រួយបារម្ភអំពីការសម្ងាត់ ការភ័យខ្លាចការសងសឹកពីជនល្មើស ឧបសគ្គផ្នែកហិរញ្ញវត្ថុ ដូចជាការបាត់បង់ប្រាក់ចំណូលដោយសារការសុំច្បាប់ពីការងារ និងឧបសគ្គជាក់ស្តែងទាក់ទងនឹងចម្ងាយ និងការដឹកជញ្ជូន។

ស្ត្រីដែលបានចូលប្រើសេវាប្រឹក្សាយោបល់មានវិជ្ជាជីវៈ ឬសិក្ខាសាលាដែលផ្តោតលើបួសផ្លូវចិត្ត បានរាយការណ៍ពីការពេញចិត្តខ្លាំង ជាពិសេសការផ្តល់តម្លៃដល់ជំនួយគាំទ្រផ្នែកអារម្មណ៍ និងអ្នកផ្តល់សេវាដែលមិនចេះតែវិនិច្ឆ័យ។ ក្រុមមិត្តជួយមិត្ត ក៏មានការទទួលយកប្រកបដោយភាពវិជ្ជមានផងដែរ។ អ្នកចូលរួមមួយចំនួនបានរាយការណ៍ពីបទពិសោធន៍អវិជ្ជមានដែលខ្លួនជួបប្រទះផងដែរ ដែលក្នុងនោះអ្នកផ្តល់សេវាខ្វះជំនាញ៣ក់ព័ន្ធ មិនបានធ្វើការតាមដានបន្ត ឬផ្តល់ដំបូន្មានមិនមានប្រយោជន៍។

ជារួម ការសិក្សាបានរកឃើញថា ស្ត្រីឱ្យតម្លៃលើសេវាដែលអ្នកផ្តល់សេវាស្តាប់ពួកគាត់និយាយដោយយកចិត្តទុកដាក់ ផ្តល់ការលើកទឹកចិត្ត និងយោគយល់ និងធានារក្សាការសម្ងាត់។ សេវាតាមសហគមន៍ ដែលដំណើរការក្រៅម៉ោងធ្វើការធម្មតា ដូចជាពេលល្ងាច ឬថ្ងៃអាទិត្យ ហើយដែលបញ្ចូលការគាំទ្រសុខុមាលភាពផ្លូវចិត្តជាមួយនឹងជំនួយជាក់ស្តែង រួមមានការបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុមសន្សំ ការថែទាំកុមារ សេវាបោកគក់ ការគាំទ្រក្នុងការដឹកជញ្ជូន ឬសកម្មភាពសង្គម ត្រូវបានឱ្យតម្លៃជាពិសេស។ វិធីសាស្ត្ររួមបញ្ចូលគ្នាបែបនេះត្រូវបានគេរកឃើញថា ជួយកាត់បន្ថយភាពអាម៉ាស់ និងបង្កើនភាពងាយស្រួលក្នុងការទទួលបានសេវា។ ការសិក្សាបានសន្និដ្ឋានថា ការខិតខំប្រឹងប្រែងពង្រឹងលទ្ធភាពទទួលបានការថែទាំសុខភាពផ្លូវចិត្ត គួរផ្តល់អាទិភាពលើការគ្របដណ្តប់ ភាពងាយស្រួលចូលទៅប្រើប្រាស់សេវា គុណភាពសេវា និងការរួមបញ្ចូលជាមួយនឹងកម្មវិធីសុខុមាលភាពសហគមន៍ផ្សេងៗ។

116 Information provided by WELL.

១២.

ស្ត្រី និងក្មេងស្រីក្នុងពន្ធនាគារ

ចំនួនប្រជាជនជាប់ពន្ធនាគារនៅកម្ពុជា បានបន្តកើនឡើងយ៉ាងឆាប់រហ័ស ទោះបីជា គណៈកម្មាធិការ ស៊ី-ដ បានផ្តល់អនុសាសន៍ឱ្យកម្ពុជាចាត់វិធានការបន្ទាន់ ដើម្បីកាត់បន្ថយចំនួនស្ត្រីក្នុងពន្ធនាគារ ដោយអនុវត្តជម្រើសជំនួសការឃុំខ្លួន។[117]

អង្គការលីកាដូ ពិនិត្យតាមដានពន្ធនាគារ និងមណ្ឌលកែប្រែចំនួន ១៩ ក្នុងចំណោមពន្ធនាគារ និងមណ្ឌលកែប្រែចំនួន ២៩កន្លែង នៅកម្ពុជា។ គិតត្រឹមខែមករា ឆ្នាំ២០២៦ ស្ត្រីសរុបចំនួន ៣.៦៣៩នាក់ និងក្មេងស្រីអនីតិជនចំនួន ១៤២នាក់ ត្រូវបានឃុំខ្លួននៅតាមទីតាំង ដែលអង្គការលីកាដូពិនិត្យតាមដាន ដែលមានមនុស្សជាប់ឃុំសរុបចំនួន ៥២.៨១៦នាក់។ តួលេខនេះ បានបង្ហាញថា ចំនួនស្ត្រី និងក្មេងស្រីដែលកំពុងជាប់ឃុំឃាំង បានកើនឡើង ២៦% ធៀបទៅនឹងឆ្នាំមុន ហើយជាការកើនឡើង ៦៧% គិតចាប់តាំងពីខែមករា ឆ្នាំ២០២៤។ ជាពិសេស ស្ត្រីចំនួន ៧១% ដែលត្រូវបានឃុំខ្លួននៅដើមឆ្នាំ២០២៦ នៅមិនទាន់ត្រូវបានចោទប្រកាន់ ឬមិនទាន់ទទួលបានសាលក្រមសម្រេចនៅឡើយទេ ដែលបង្ហាញពីការឃុំខ្លួនបណ្តោះអាសន្នច្រើនជ្រុល។

ភាពចង្អៀតណែនធ្ងន់ធ្ងរ នៅតែជាកង្វល់ធំ ដែលធ្វើឱ្យខូចដល់លក្ខខណ្ឌដែលផ្តល់ភាពថ្លៃថ្នូរ និងលទ្ធភាពទទួលបានសេវាមូលដ្ឋាន។ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ប្រចាំនៅកម្ពុជាបានលើកឡើងពី “ការព្រួយបារម្ភជាខ្លាំង” ពីអំពើពុករលួយនៅតាមពន្ធនាគារ ហើយបានរាយការណ៍ថា ភាពចង្អៀតណែនបានបណ្តាលឱ្យខ្វះកន្លែងគេង ការថែទាំសុខភាព ពេលវេលានៅខាងក្រៅបន្ទប់ឃុំឃាំង បង្គន់ សំឡីអនាម័យពេលមករដូវ និងកន្លែងបណ្តុះបណ្តាលវិជ្ជាជីវៈ។[118]

ភាពចង្អៀតណែនធ្ងន់ធ្ងរ នៅក្នុងពន្ធនាគារបណ្តាលឱ្យមានផលលំបាកដូចជា៖

117 CEDAW Committee, above n 1, para. 45(a).

118 “Role and achievements of the Office of the United Nations High Commissioner for Human Rights in assisting the Government and people of Cambodia in the promotion and protection of human rights”, A/HRC/60/87, September 12, 2025, para. 68-74, online: https://www.ohchr.org/sites/default/files/documents/hrbodies/hrcouncil/sessions-regular/session60/advance-version/a-hrc-60-87-aev.pdf.

គិតត្រឹមខែមករា ឆ្នាំ២០២៦ ពន្ធនាគារទាំង ១៩ ដែលអង្គការលីកាដូពិនិត្យតាមដាន កំពុងដំណើរការលើសពីសមត្ថភាពផ្ទូរការរបស់ខ្លួន។ ពន្ធនាគារចំនួនប្រាំពីរ ផ្ទុកមនុស្សលើសសមត្ថភាពរបស់ខ្លួន រហូតដល់ទៅ ៤០០%។ ភាពចង្អៀតណែនកាន់តែធ្ងន់ធ្ងរឡើង ដោយសារការផ្ទេរមនុស្សទ្រង់ទ្រាយធំចំនួនពីរលើក ពីពន្ធនាគារឧត្តរមានជ័យទៅពន្ធនាគារសៀមរាប ក្នុងអំឡុងពេលនៃការកើនឡើងនូវជម្លោះព្រំដែនក្នុងខែកក្កដា និងខែធ្នូ ឆ្នាំ២០២៥។ ភាពចង្អៀតណែនក៏បានបណ្តាលឱ្យមានការផ្ទេរមនុស្សជាច្រើនលើកច្រើនសារផងដែរ នៅទូទាំងប្រទេស ក្នុងឆ្នាំ២០២៥ ដែលជារឿយៗធ្វើឱ្យមនុស្សផ្លាស់ទីទៅឆ្ងាយពីក្រុមគ្រួសារ និងមេធាវីរបស់ខ្លួន។

ភាពចង្អៀតណែនបានបន្ថែមស្ថានភាពអាក្រក់ ទៅលើក្រុមងាយរងគ្រោះកាន់តែធ្ងន់ធ្ងរថែមទៀត ដែលក្រុមទាំងនោះរួមមាន ស្ត្រីមានផ្ទៃពោះ កុមារជាប់ឃុំជាមួយម្តាយ មនុស្សចាស់ និងជនមានពិការភាព។ ចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០២៥ អង្គការលីកាដូ បានចងក្រងឯកសារអំពីការឃុំខ្លួនស្ត្រីមានផ្ទៃពោះយ៉ាងហោចណាស់ចំនួន ៩៩នាក់ និងក្មេងស្រីអនីតិជនចំនួន ២៤០នាក់។ កុមារតូចៗសរុបចំនួន ១៥៩នាក់ (ក្មេងស្រី ៨៨នាក់ និងក្មេងប្រុស ៧១នាក់) ក៏កំពុងរស់នៅជាមួយម្តាយរបស់ខ្លួនក្នុងពន្ធនាគារផងដែរ។ ស្ត្រីទាំងនេះ បានរាយការណ៍ពីកង្វះកន្លែងឯកជនសម្រាប់បំបៅដោះកូន និងងូតទឹកឱ្យកូន។ នៅក្នុងខែមិថុនា ឆ្នាំ២០២៥ អង្គការលីកាដូ បានចុះផ្សាយអត្ថបទមួយ បង្ហាញពីសក្តីកម្មអនាមិករបស់ស្ត្រីជាម្តាយចំនួនពីរនាក់ ដែលក្នុងនោះមានស្ត្រីម្នាក់រៀបរាប់អំពីការសម្រាលកូន ដោយដាក់ខ្ទោះជាប់នឹងគ្រែមន្ទីរពេទ្យ។[119]

បន្ទាប់មក អនុក្រឹត្យមួយត្រូវបានចុះហត្ថលេខាភ្លាយជាច្បាប់ ដើម្បីអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់ "ជនជាប់ឃុំជាស្ត្រីមានផ្ទៃពោះ និងកូនអាយុក្រោមពីរឆ្នាំ" របស់មូលនិធិជាតិជំនួយសង្គម (NSAF)។ ទោះជាយ៉ាងណា ការអនុវត្តជាប្រព័ន្ធនូវផម្រើសជំនួសឱ្យការឃុំខ្លួន និងការកាត់បន្ថយឱ្យបានច្រើននូវការប្រើប្រាស់វិធីឃុំខ្លួនបណ្តោះអាសន្ន គឺជារឿងដែលចាំបាច់ជាបន្ទាន់ ដើម្បីដោះស្រាយវិបត្តិមនុស្សធម៌ ដែលស្ត្រី និងក្មេងស្រីដែលជាប់ឃុំក្នុងពន្ធនាគារនៅកម្ពុជា កំពុងតែប្រឈមមុខ។

ពន្ធនាគារចំនួនប្រាំពីរ ដែលអង្គការលីកាដូ ពិនិត្យតាមដាន កំពុងផ្ទុកមនុស្សលើសសមត្ថភាពរបស់ខ្លួន រហូតដល់ទៅ ៤០០%

119 LICADHO, "No Place to Play: Childhoods Spent Behind Bars", June 1, 2025, online: https://www.licadho-cambodia.org/articles/20250601/199/index.html.

អនុសាសន៍

ចំណាត់ការទូលំទូលាយ និងជាបន្តបន្ទាប់ គឺជារឿងចាំបាច់ដើម្បីធានាបាននូវការលើកកម្ពស់ ការការពារ និងការអនុវត្តសិទ្ធិរបស់ស្ត្រី ក្មេងស្រី និងអ្នកមិនកំណត់អត្តសញ្ញាណភេទស្រី ឬប្រុស បានពេញលេញស្របតាមអនុសញ្ញា ស៊ី-ដ និងសេចក្តីសង្កេតសន្ធិដ្ឋានរបស់គណៈកម្មាធិការ ស៊ី-ដ។ ទោះជាយ៉ាងណា សកម្មភាពអាទិភាពដូចខាងក្រោមនេះជាអនុសាសន៍ដល់រដ្ឋាភិបាលកម្ពុជា៖

១. បែងចែកធនធាន៖

បែងចែកធនធានមនុស្ស បច្ចេកទេស និងហិរញ្ញវត្ថុឱ្យបានគ្រប់គ្រាន់ ជាក់លាក់ និងសម្រាប់រយៈពេលវែងដោយប្រើថវិកាជាតិដើម្បីអនុវត្តប្រកបដោយប្រសិទ្ធភាពនូវផែនការសកម្មភាព គោលនយោបាយ និងការប្តេជ្ញាចិត្តរបស់កម្ពុជាចំពោះសមភាពយេនឌ័រនៅកម្ពុជា។

២. កិច្ចគាំពារ និងការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ៖

២.១ ពិនិត្យឡើងវិញជាបន្ទាន់ និងគ្រប់ជ្រុងជ្រោយទៅលើក្របខ័ណ្ឌច្បាប់

- ជាពិសេសច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ
- ដើម្បីកំណត់ឱ្យបានច្បាស់ និងដាក់ទោសព្រហ្មទណ្ឌចំពោះគ្រប់សកម្មភាពនៃអំពើហិង្សាក្នុងគ្រួសារ។

២.២ ពង្រឹងកម្មវិធីទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងធានាបាននូវការទទួលបានសេវាទូលំទូលាយ រួមទាំងតុលាការមានប្រសិទ្ធភាព ដីកាការពារ និងសេចក្តីសម្រេចរដ្ឋបាល ការតំណាងផ្នែកច្បាប់ មណ្ឌលសុវត្ថិភាព ការថែទាំសុខភាពរាងកាយ និងផ្លូវចិត្ត ជំនួយហិរញ្ញវត្ថុ និងការបណ្តុះបណ្តាល និងឱកាសក្នុងប្រកបរបរចិញ្ចឹមជីវិត។

២.៣ បញ្ឈប់ការចាត់ទុកមុខរបរប្រកបរបរផ្លូវភេទជាបទល្មើសព្រហ្មទណ្ឌ និងលុបចោលច្បាប់គោលនយោបាយ និងសកម្មភាព និងការរើសអើងទាំងអស់ដែលប៉ះពាល់ដល់អ្នកប្រកបរបរផ្លូវភេទ។ ធានាថាច្បាប់ជាតិបែងចែករវាងការងារប្រកបរបរផ្លូវភេទ និងការជួញដូរមនុស្ស ហើយថាគំនិតផ្ទុចផ្តើមប្រឆាំងការជួញដូរមិនប៉ះពាល់ដល់សិទ្ធិរបស់អ្នកប្រកបរបរផ្លូវភេទឡើយ។

៣. ស្ត្រីអ្នកការពារសិទ្ធិមនុស្ស និងលំហសង្គមស៊ីវិល៖

បញ្ចប់រាល់ទម្រង់នៃការបៀតបៀន អំពើហិង្សា និងការគំរាមកំហែងទៅលើស្ត្រីជាគូប្រជែងនយោបាយ ជាអ្នកសារព័ត៌មាន ជាសកម្មជនដីធ្លី ការងារ និងបរិស្ថាន ស្ត្រីជាអ្នកការពារសិទ្ធិមនុស្សផ្សេងទៀត និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ។ ដោះលែងពួកគាត់ចេញពីពន្ធនាគារជាបន្ទាន់ ទម្លាក់រាល់បទចោទប្រកាន់ទាំងអស់ទៅលើពួកគាត់ និងផ្តល់អាជ្ញាប័ណ្ណប្រព័ន្ធផ្សព្វផ្សាយ ដែលត្រូវបានដកហូតនោះឡើងវិញ ។

៤. ការចូលរួមរបស់ស្ត្រីក្នុងឆាកនយោបាយ៖

ធានាថាស្ត្រីមានតំណាងស្មើគ្នាក្នុងឆាកនយោបាយ និងការតាក់តែងច្បាប់នៅថ្នាក់ជាតិ ខេត្ត/ក្រុង ស្រុក/ខណ្ឌ និងឃុំ/សង្កាត់ តាមរយៈវិធានការពិសេសបណ្តោះអាសន្ន។ វិធានការទាំងនេះអាចរួមមានចំណាត់ការវិជ្ជមានចំគោលដៅ ប្រព័ន្ធកំណត់កូតា និងវិសោធនកម្មច្បាប់បោះឆ្នោត ដើម្បីទាមទារឱ្យមានបញ្ជីគណបក្ស ដែលមានតុល្យភាពយេនឌ័រ រួមទាំងការកំណត់ឱ្យមានការឆ្លាស់គ្នារវាងបេក្ខជនស្ត្រី និងបុរស និងស្ត្រីនៅក្នុងតំណែងលំដាប់ទីមួយយ៉ាងហោចណាស់ ៥០% នៃបញ្ជីគណបក្សនីមួយៗ។

៥. វិបត្តិក្នុងការធ្លើយតបនឹងយេនឌ័រ៖

កំណត់ និងដោះស្រាយជាប្រព័ន្ធនូវតម្រូវការរបស់ស្ត្រី ក្មេងស្រី និងអ្នកមិនកំណត់អត្តសញ្ញាណភេទស្រី ឬប្រុស នៅក្នុងពេលមានវិបត្តិ និងការជម្លៀសចេញពីទីលំនៅ រាប់ទាំងវិបត្តិដែលកើតចេញពីសង្គ្រាម ការចំណាកស្រុក ការប្រែប្រួលអាកាសធាតុ និងវិបត្តិសេដ្ឋកិច្ចផងដែរ។ ធានាឱ្យបាននូវលទ្ធភាពទទួលបានជំនួយសង្គ្រោះបន្ទាន់ចំគោលដៅ សេវាគាំទ្រដែលចាំបាច់ ឱកាសការងារពាក់ព័ន្ធ និងឱកាសប្រកបមុខរបរចិញ្ចឹមជីវិត យន្តការការពារ អំពើហិង្សាទាក់ទងនឹងយេនឌ័រមានប្រសិទ្ធភាព និងការបន្ទូរបន្ថយបំណុលដែលមានភាពស្ថិតស្ថេរ។

ការវិវឌ្ឍនៃការអនុវត្តនូវសេចក្តីសង្កេតសន្និដ្ឋានចុងក្រោយអនុសញ្ញា ស៊ី-ដ ឆ្នាំ២០១៩ (CoBs)

លេខរៀងកថាខណ្ឌនៃ CoBs: ៦

ប្រធានបទ	SDGs	
សេចក្តីសង្ខេប	ទទួលស្គាល់ស្ត្រីជាកំលាំងចលករនៃការអភិវឌ្ឍន៍ប្រកបដោយស្ថេរភាព	
ការវិវឌ្ឍ ឆ្នាំ២០២៥	បានអនុវត្តរួចហើយ	

កម្រិត
២០២០
២០២១
២០២២
២០២៣/២០២៤
២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ៩ក

ប្រធានបទ	ក្របខណ្ឌច្បាប់	
សេចក្តីសង្ខេប	និយមន័យនៃការរើសអើងនៅក្នុងច្បាប់	
ការវិវឌ្ឍ ឆ្នាំ២០២៥	មិនទាន់បានអនុវត្តនៅឡើយ	

កម្រិត
២០២០
២០២១
២០២២
២០២៣/២០២៤
២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ៩ខ

ប្រធានបទ	ក្របខណ្ឌច្បាប់	
សេចក្តីសង្ខេប	ការសិក្សាវាយតម្លៃពីច្បាប់ដែលមានឥទ្ធពលលើយេនឌ័រជាលក្ខណៈប្រព័ន្ធ	
ការវិវឌ្ឍ ឆ្នាំ២០២៥	មិនទាន់បានអនុវត្តនៅឡើយ	

កម្រិត
២០២០
២០២១
២០២២
២០២៣/២០២៤
២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ១១ក

ប្រធានបទ	ការទទួលបានយុត្តិធម៌	
សេចក្តីសង្ខេប	ជំនួយផ្នែកច្បាប់ដោយមានការផ្តល់ថវិកាជំនួយពីរដ្ឋក្នុងរយៈពេលវែង សាលាឧទ្ធរណ៍តាមតំបន់	
ការវិវឌ្ឍ ឆ្នាំ២០២៥	ជំនួយផ្នែកច្បាប់មួយចំនួនអាចរកបាន។ ទោះជាយ៉ាងណាក៏ដោយ នៅមិនទាន់គ្រប់គ្រាន់ ដំណើរការមិនបានយូរអង្វែង ឬការចូលប្រើប្រាស់មិនស្មើភាពគ្នា។ មិនមានតុលាការ ឧទ្ធរណ៍ថ្មីណាមួយ ត្រូវបានបង្កើតឡើងចាប់តាំងពី ឆ្នាំ២០២០ មក។	

កម្រិត
២០២០
២០២១
២០២២
២០២៣/២០២៤
២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ១១ខ

ប្រធានបទ	ការទទួលបានយុត្តិធម៌	
សេចក្តីសង្ខេប	បញ្ចប់ការទទួលរងស្លាកស្នាមមិនល្អ ក្នុងការរាយការណ៍ពីការលោភបំពានសិទ្ធិ	
ការវិវឌ្ឍ ឆ្នាំ២០២៥	កិច្ចខិតខំប្រឹងប្រែងផ្សព្វផ្សាយដល់សាធារណជនមួយចំនួនត្រូវបានអនុវត្ត ប៉ុន្តែការរើសអើងនៅតែមាននៅគ្រប់កម្រិតនៃសង្គម និងស្ថាប័នទាំងអស់ រួមទាំងការអនុវត្តច្បាប់ និងប្រព័ន្ធតុលាការផងដែរ។ មិនមានការគាំទ្រសម្រាប់ការរាយការណ៍អំពីអំពើហិង្សា ដែលប្រព្រឹត្តឡើងដោយរដ្ឋនោះទេ។	

កម្រិត
២០២០
២០២១
២០២២
២០២៣/២០២៤
២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ១១គ

ប្រធានបទ	ការទទួលបានយុត្តិធម៌	
សេចក្តីសង្ខេប	ផ្សព្វផ្សាយពត៌មានអំពីដំណោះស្រាយ	
ការវិវឌ្ឍ ឆ្នាំ២០២៥	ព័ត៌មានសាធារណៈមួយចំនួនត្រូវបានផ្សព្វផ្សាយ ប៉ុន្តែការទទួលបានដំណោះស្រាយតាមផ្លូវតុលាការនៅតែមិនគ្រប់គ្រាន់។	

កម្រិត
២០២០
២០២១
២០២២
២០២៣/២០២៤
២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ១១ឃ

ប្រធានបទ	ការទទួលបានយុត្តិធម៌	
សេចក្តីសង្ខេប	ប្រព័ន្ធយុត្តិធម៌ដែលគិតគូពីយេនឌ័រ មានស្ត្រីកាន់តែច្រើនទទួលបានវគ្គបណ្តុះបណ្តាលអំពីអនុសញ្ញា ស៊ីដ	
ការវិវឌ្ឍ ឆ្នាំ២០២៥	ជំហានមួយចំនួនត្រូវបានអនុវត្ត ដូចជាការបណ្តុះបណ្តាលជាដើម។ ទោះជាយ៉ាងណាក៏ដោយ ប្រព័ន្ធតុលាការមិនទាន់ឆ្លើយតបគ្រប់គ្រាន់ចំពោះយេនឌ័រ ផ្តោតលើអ្នករស់រាន យល់ដឹងពីរបួសផ្លូវចិត្ត ឬមិនសមស្របសម្រាប់កុមារនៅឡើយទេ។ ស្ត្រីនៅតែមានតំណាងតិចតួចក្នុងចំណោមបុគ្គលិកតុលាការ។	

កម្រិត
២០២០
២០២១
២០២២
២០២៣/២០២៤
២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ១១ង

ប្រធានបទ	ការទទួលបានយុត្តិធម៌	
សេចក្តីសង្ខេប	ការស៊ើបអង្កេត និងការដាក់ទោសលើករណីនៃអំពើហិង្សាក្នុងគ្រួសារ និងការរំលោភសេពសន្ថវៈ ត្រូវមានលក្ខណៈមិនលំអៀង ឯករាជ្យ និងតាមផ្លូវតុលាការ	
ការវិវឌ្ឍ ឆ្នាំ២០២៥	ប្រព័ន្ធតុលាការមានភាពលំអៀង ឬមិនឯករាជ្យទេ។ ប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់ទី ១៤១ ក្នុងចំណោមប្រទេសចំនួន ១៤៣ នៅទូទាំងពិភពលោកនៅក្នុងសន្ទស្សន៍នីតិរដ្ឋ ឆ្នាំ២០២៥ នៃគម្រោងយុត្តិធម៌ពិភពលោក។[1] ករណីអំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាផ្លូវភេទមិនត្រូវបានស៊ើបអង្កេត ឬចោទប្រកាន់ជាប់លាប់នោះទេ។	

កម្រិត
២០២០
២០២១
២០២២
២០២៣/២០២៤
២០២៥

1 World Justice Project, “2025 Rule of Law Index”, online: https://worldjusticeproject.org/rule-of-law-index/country/2025/Cambodia/.

លេខរៀងកថាខណ្ឌនៃ CoBs: ១១ច

ប្រធានបទ	ការទទួលបានយុត្តិធម៌	
សេចក្តីសង្ខេប	ឱ្យមន្ត្រីដែលជាប់ពាក់ព័ន្ធនឹងអំពើពុករលួយទទួលខុសត្រូវលើទង្វើរបស់ខ្លួន	
ការវិវឌ្ឍ ឆ្នាំ២០២៥	មន្ត្រីរាជការមិនត្រូវបានទាមទារឱ្យទទួលខុសត្រូវចំពោះអំពើពុករលួយនោះទេ។ ប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់ទី ១៦៣ ក្នុងចំណោម ១៨២ប្រទេស នៅក្នុងសន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយឆ្នាំ ២០២៥ របស់អង្គការតម្លាភាពអន្តរជាតិ។[2]	

កម្រិត
២០២០
២០២១
២០២២
២០២៣/២០២៤
២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ១៣ក

ប្រធានបទ	វិភាទ
សេចក្តីសង្ខេប	ភាពត្រឹមត្រូវចំពោះជនរងគ្រោះនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ ក្នុងសម័យខ្មែរក្រហម
ការវិវឌ្ឍ ឆ្នាំ២០២៥	ការផ្តល់សំណង និងការជួសជុលការខូចខាត មិនទាន់មានលក្ខណៈទូលំទូលាយនៅឡើយទេ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានឈានចូលដល់ដំណាក់កាលកិច្ចការសេសសល់ ដែលផ្តោតលើកេរដំណែលចាប់តាំងពីការប្រកាសសាលដីកាចុងក្រោយបង្អស់របស់ខ្លួន ក្នុងឆ្នាំ២០២២។ អ្នករស់រានមានជីវិតពីរបបនោះ នៅតែបន្តត្រូវការលទ្ធភាពទទួលសេវាគាំទ្រនានា ជាពិសេសនៅក្នុងវ័យជរា។[3]

កម្រិត
២០២០
២០២១
២០២២
២០២៣/២០២៤
២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ១៣ខ

ប្រធានបទ	វិភាទ
សេចក្តីសង្ខេប	ផែនការសកម្មភាពជាតិ ស្តីពីសេចក្តីសម្រេចចិត្តលេខ ១៣២៥ របស់ក្រុមប្រឹក្សាសន្តិសុខ
ការវិវឌ្ឍ ឆ្នាំ២០២៥	ប្រទេសកម្ពុជាបានបង្ហាញការប្តេជ្ញាចិត្ត និងបានអនុវត្តជំហានបឋមមួយចំនួនឆ្ពោះទៅរកការអភិវឌ្ឍផែនការសកម្មភាពជាតិ។ ទោះជាយ៉ាងណាក็ដោយ ផែនការសកម្មភាពជាតិនេះ នៅមិនទាន់មានការអភិវឌ្ឍនោះទេ។

កម្រិត
២០២០
២០២១
២០២២
២០២៣/២០២៤
២០២៥

2 Transparency International ‘Corruption Perceptions Index’ 2025 https://www.transparency.org/en/cpi/2025/index/khm

3 Women Peace Makers (2025) “Voice of Legacy: Amplifying Minority Survivors’ Perspectives in Cambodia’s Transitional Justice and Future Atrocity Prevention Effort”, online: https://wpmcambodia.org/project/voice-of-legacy-amplifying-minority-survivors-perspectives-in-cambodias-transitional-justice-and-future-atrocity-prevention-effort/.

លេខរៀងកថាខណ្ឌនៃ CoBs: ១៣គ

ប្រធានបទ	រ៉ាទ	
សេចក្តីសង្ខេប	ស្ត្រីត្រូវចូលរួមក្នុងការកសាងសន្តិភាពនៅគ្រប់ដំណាក់កាលទាំងអស់	
ការវិវឌ្ឍ ឆ្នាំ២០២៥	ប្រទេសកម្ពុជាបានបង្ហាញនូវតួនាទីដឹកនាំក្នុងការលើកកម្ពស់របៀបវារៈស្តីពី ស្ត្រី សន្តិសុខ និងសន្តិភាព (WPS) នៅក្នុងតំបន់អាស៊ានក៏ដូចជាការចូលរួមរបស់ស្ត្រីក្នុងប្រតិបត្តិការរក្សាសន្តិភាពផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ស្ត្រីនៅមិនទាន់មានការចូលរួមនៅគ្រប់ដំណាក់កាលទាំងអស់នៃការកសាងសន្តិភាពនោះទេ ហើយចំនួនតំណាងរបស់ស្ត្រីនៅក្នុងតួនាទីដឹកនាំ នៅតែមានកម្រិតទាបខ្លាំងនៅឡើយ។	

កម្រិត	
២០២០	
២០២១	
២០២២	
២០២៣/២០២៤	
២០២៥	

លេខរៀងកថាខណ្ឌនៃ CoBs: ១៥ក

ប្រធានបទ	យន្តការដឹកនាំថ្នាក់ជាតិ	
សេចក្តីសង្ខេប	ស្វ័យភាពនិងធនធានសម្រាប់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី (CNCW)	
ការវិវឌ្ឍ ឆ្នាំ២០២៥	មិនទាន់បានអនុវត្តនៅឡើយ។	

កម្រិត	
២០២០	
២០២១	
២០២២	
២០២៣/២០២៤	
២០២៥	

លេខរៀងកថាខណ្ឌនៃ CoBs: ១៥ខ

ប្រធានបទ	យន្តការដឹកនាំថ្នាក់ជាតិ	
សេចក្តីសង្ខេប	ថវិកាជាតិសម្រាប់ការអនុវត្តពេញលេញនូវគោលនយោបាយយេនឌ័រ	
ការវិវឌ្ឍ ឆ្នាំ២០២៥	ធនធាន និងមូលនិធិនៅមានកម្រិត មិនមានប្រសិទ្ធិភាព និងមិនមានការបែងចែកច្បាស់លាស់។	

កម្រិត	
២០២០	
២០២១	
២០២២	
២០២៣/២០២៤	
២០២៥	

លេខរៀងកថាខណ្ឌនៃ CoBs: ១៥គ

ប្រធានបទ	យន្តការដឹកនាំថ្នាក់ជាតិ	
សេចក្តីសង្ខេប	ការចូលរួមរបស់អង្គការសង្គមស៊ីវិល ក្នុងការរៀបចំគោលនយោបាយជាតិ ស្តីពីសមភាពយេនឌ័រ។	
ការវិវឌ្ឍ ឆ្នាំ២០២៥	គោលនយោបាយជាតិស្តីពី សមភាពយេនឌ័រមិនទាន់ត្រូវបានបង្កើតឡើងនៅឡើយ។ ការពិគ្រោះយោបល់ចុងក្រោយបំផុតដែលមានការចូលរួមជាមួយសង្គមស៊ីវិល គឺនៅឆ្នាំ ២០២១/២០២២។	

កម្រិត	
២០២០	
២០២១	
២០២២	
២០២៣/២០២៤	
២០២៥	

លេខរៀងកថាខណ្ឌនៃ CoBs: ១៥យ

ប្រធានបទ	យន្តការដឹកនាំថ្នាក់ជាតិ	
សេចក្តីសង្ខេប	ការត្រួតពិនិត្យ និងការវាយតម្លៃ (M&E) ប្រកបដោយប្រសិទ្ធភាព លើគោលនយោបាយនានា សកម្មភាពយេនឌ័រនៅថ្នាក់ក្រសួង	
ការវិវឌ្ឍ ឆ្នាំ២០២៥	ក្របខ័ណ្ឌគ្រប់ជ្រុងជ្រោយមិនទាន់មាននៅឡើយទេ។ ផែនការយុទ្ធសាស្ត្រជាតិ និងផែនការសកម្មភាពមានលក្ខណៈបែកខ្ញែក។	

កម្រិត
២០២០
២០២១
២០២២
២០២៣/២០២៤
២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ១៧

ប្រធានបទ	ស្ថាប័នសិទ្ធិមនុស្ស	
សេចក្តីសង្ខេប	បង្កើតឱ្យមានស្ថាប័នសិទ្ធិមនុស្សស្របតាមគោលការណ៍ ទីក្រុងប៉ារីសនីមួយៗ (per Paris Principles)	
ការវិវឌ្ឍ ឆ្នាំ២០២៥	រដ្ឋាភិបាលកំពុងស្នើឱ្យមាន ស្ថាប័នជាតិសិទ្ធិមនុស្ស (NHRI) ក្នុងឆ្នាំកន្លងមក ប៉ុន្តែមិនមានយន្តការ ដើម្បីធ្វើឱ្យវាស្របតាមគោលការណ៍ទីក្រុងប៉ារីសឡើយ។ បរិយាកាសសិទ្ធិមនុស្ស និងនយោបាយនាពេលបច្ចុប្បន្ន អាចនឹងរារាំងស្ថាប័ននានា ក្នុងការដំណើរការប្រកបដោយឯករាជ្យភាព និងប្រសិទ្ធិភាព។	

កម្រិត
២០២០
២០២១
២០២២
២០២៣/២០២៤
២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ១៩

ប្រធានបទ	សង្គមស៊ីវិល	
សេចក្តីសង្ខេប	ធានាឱ្យមានទូរសេរីភាពនៃការបញ្ចេញមតិ ការប្រមូលផ្តុំ និងការចូលរួមសមាគម	
ការវិវឌ្ឍ ឆ្នាំ២០២៥	កម្ពុជាបន្តរំលោភសិទ្ធិស្ត្រី អ្នកការពារសិទ្ធិមនុស្ស សហជីព សកម្មជនដីធ្លី និងបរិស្ថាន និងអ្នកនយោបាយបក្សប្រឆាំង។	

កម្រិត
២០២០
២០២១
២០២២
២០២៣/២០២៤
២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ២១ក

ប្រធានបទ	វិធានការពិសេសបណ្តោះអាសន្ន	
សេចក្តីសង្ខេប	ការបែងចែកដីធ្លីឡើងវិញ សម្រាប់ភាពជាម្ចាស់កម្មសិទ្ធិរបស់ស្ត្រីដោយស្មើភាពគ្នា	
ការវិវឌ្ឍ ឆ្នាំ២០២៥	វិធានការពិសេសបណ្តោះអាសន្ន មិនទាន់ត្រូវបានអនុម័តនៅឡើយទេ។ របាយការណ៍ឆ្នាំ ២០២៥ បានបង្ហាញថា សមាមាត្រនៃស្ត្រី និងបុរសកម្ពុជាដែលមាន កម្មសិទ្ធិ ឬសិទ្ធិមានសុវត្ថិភាពលើដីកសិកម្មរបស់ពួកគេ គឺមានកម្រិតប្រហាក់ប្រហែលគ្នា។[4] ទោះជាយ៉ាងណាក៏ដោយ សុវត្ថិភាពនៃការកាន់កាប់ដីធ្លីនៅក្នុងប្រទេសកម្ពុជា នៅតែមានភាពទន់ខ្សោយ និងមិនមានសមធម៌ ហើយស្ត្រីនៅតែបន្តជួបប្រទះនូវការ រំលោភយកដីធ្លី និងការបណ្តេញចេញដោយបង្ខំ។	

កម្រិត
២០២០
២០២១
២០២២
២០២៣/២០២៤
២០២៥

4 National Institute of Statistics, above n 66.

លេខរៀងកថាខណ្ឌនៃ CoBs: ២១ខ

ប្រធានបទ	វិធានការពិសេសបណ្តោះអាសន្ន	កម្រិត
សេចក្តីសង្ខេប	ការផ្តល់ទីសុវត្ថិភាពសម្រាប់ស្ត្រី	២០២០ ២០២១ ២០២២ ២០២៣/២០២៤ ២០២៥
ការវិវឌ្ឍ ឆ្នាំ២០២៥	វិធានការពិសេសបណ្តោះអាសន្នមិនត្រូវបានអនុម័តទេ។ ការរំលោភយកដីធ្លី ការបណ្តេញចេញដោយបង្ខំ និងការតាំងទីលំនៅថ្មីនៅទីតាំងមិនសមរម្យ នៅតែបន្តធ្វើឱ្យខូចដល់លទ្ធភាពទទួលបានសុវត្ថិភាពកាន់តាប់ និងលំនៅដ្ឋានសមរម្យ។	

លេខរៀងកថាខណ្ឌនៃ CoBs: ២១គ

ប្រធានបទ	វិធានការពិសេសបណ្តោះអាសន្ន	កម្រិត
សេចក្តីសង្ខេប	កែលម្អឱកាសសេដ្ឋកិច្ចដោយមានការកំណត់កូតា	២០២០ ២០២១ ២០២២ ២០២៣/២០២៤ ២០២៥
ការវិវឌ្ឍ ឆ្នាំ២០២៥	មិនទាន់បានអនុវត្តនៅឡើយ។	

លេខរៀងកថាខណ្ឌនៃ CoBs: ២៣ក

ប្រធានបទ	ផ្តត់គំនិត	កម្រិត
សេចក្តីសង្ខេប	យុទ្ធសាស្ត្រមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដើម្បីលុបបំបាត់ឥរិយាបថ នៃការប្រកាន់ភាពជាបុរស	២០២០ ២០២១ ២០២២ ២០២៣/២០២៤ ២០២៥
ការវិវឌ្ឍ ឆ្នាំ២០២៥	មិនទាន់បានអនុវត្តនៅឡើយ។	

លេខរៀងកថាខណ្ឌនៃ CoBs: ២៣ខ

ប្រធានបទ	ផ្តត់គំនិត	កម្រិត
សេចក្តីសង្ខេប	វិធីសាស្ត្រផ្សេងៗក្នុងការអប់រំយេនឌ័រដោយមិនមានច្បាប់ស្រី	២០២០ ២០២១ ២០២២ ២០២៣/២០២៤ ២០២៥
ការវិវឌ្ឍ ឆ្នាំ២០២៥	មិនមានកិច្ចប្រឹងប្រែងថ្មីទេ។ ច្បាប់ស្រីនៅតែបន្តបង្រៀនតាមរូបភាពផ្សេងៗ ក្នុងសាលារៀន។	

លេខរៀងកថាខណ្ឌនៃ CoBs: ២៣គ

ប្រធានបទ	ផ្តត់គំនិត	
សេចក្តីសង្ខេប	ជំរុញឱ្យមានឥរិយាបថដែលមានលក្ខណៈវិជ្ជមានចំពោះសមភាពយេនឌ័រ ក្នុងចំណោមយុវវ័យ	
ការវិវឌ្ឍ ឆ្នាំ២០២៥	ប្រព័ន្ធផ្សព្វផ្សាយសង្គម និងយុទ្ធនាការសាធារណៈមួយចំនួន ត្រូវបានរៀបចំឡើង ដើម្បីលើកកម្ពស់សមភាពក្នុងបរិបទមួយចំនួន។	

	២០២០
	២០២១
	២០២២
	២០២៣/២០២៤
	២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ២៥ក

ប្រធានបទ	អំពើហិង្សាទាក់ទងនឹងយេនឌ័រ	
សេចក្តីសង្ខេប	ធ្វើការវាយតម្លៃពីផលប៉ះពាល់នៃវិធានការ និងដោះស្រាយឬសគល់នៃបញ្ហា	
ការវិវឌ្ឍ ឆ្នាំ២០២៥	មិនមានការវាយតម្លៃជាប្រព័ន្ធណាមួយដែលគេស្គាល់អំពីផលប៉ះពាល់នៃវិធានការនោះទេ។ គំនិតផ្តួចផ្តើមមួយចំនួនក្នុងការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ ដើម្បីផ្លាស់ប្តូរអាកប្បកិរិយាដែលបង្ករគ្រោះថ្នាក់ និងដោះស្រាយមូលហេតុឬសគល់ត្រូវបានអនុម័ត ប៉ុន្តែយុទ្ធសាស្ត្រដ៏ទូលំទូលាយជាមួយនឹងការអនុវត្តប្រកបដោយចីរភាពនៅតែមានកម្រិត។	

	២០២០
	២០២១
	២០២២
	២០២៣/២០២៤
	២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ២៥ខ

ប្រធានបទ	អំពើហិង្សាទាក់ទងនឹងយេនឌ័រ	
សេចក្តីសង្ខេប	ធ្វើការពិនិត្យឡើងវិញឱ្យបានគ្រប់ជ្រុងជ្រោយ នូវច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ ធ្វើវិសោធនកម្មដើម្បីដាក់ទោសទណ្ឌលើរាល់អំពើហិង្សាក្នុងគ្រួសារ សម្របសម្រួលឱ្យមានដីកាការពារដំណោះស្រាយប្រកបដោយប្រសិទ្ធភាព	
ការវិវឌ្ឍ ឆ្នាំ២០២៥	ក្រសួងកិច្ចការនារីបានបង្កើតផែនទីបង្ហាញផ្លូវ ដើម្បីពិនិត្យឡើងវិញនូវច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ។ ទោះជាយ៉ាងណាក៏ដោយ វាមិនទាន់ត្រូវបានផ្សព្វផ្សាយជាសាធារណៈនៅឡើយទេ ហើយដំណើរការនេះហាក់ដូចជាជាប់គាំងដោយគ្មានកាលកំណត់។	

	២០២០
	២០២១
	២០២២
	២០២៣/២០២៤
	២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ២៥គ

ប្រធានបទ	អំពើហិង្សាទាក់ទងនឹងយេនឌ័រ	
សេចក្តីសង្ខេប	កែលម្អសេវាសំខាន់នានា	
ការវិវឌ្ឍ ឆ្នាំ២០២៥	ការទទួលបានសេវាកម្ម ដែលមានគុណភាព និងទូលំទូលាយនៅតែមានកម្រិត និងមិនគ្រប់គ្រាន់។	

	២០២០
	២០២១
	២០២២
	២០២៣/២០២៤
	២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ២៥យ

ប្រធានបទ	អំពើហិង្សាទាក់ទងនឹងយេនឌ័រ	កម្រិត
សេចក្តីសង្ខេប	ធ្វើការប្រមូលទិន្នន័យដោយប្រព័ន្ធគ្រប់គ្រង អំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ	២០២០ ២០២១ ២០២២
ការវិវឌ្ឍ ឆ្នាំ២០២៥	ទិន្នន័យដែលបែងចែកមិនត្រូវបានប្រមូល ឬបោះពុម្ពផ្សាយទៀងទាត់ជាប្រព័ន្ធនោះទេ។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលបានបង្ហាញពីឆន្ទៈក្នុងការធ្វើវាឱ្យកើតឡើង។	២០២៣/២០២៤ ២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ២៧ក

ប្រធានបទ	ការជួញដូរមនុស្ស	កម្រិត
សេចក្តីសង្ខេប	ធ្វើការដោះស្រាយបញ្ហាជាឫសគល់នៃកង្វះខាតនូវឱកាសសេដ្ឋកិច្ច	២០២០ ២០២១ ២០២២
ការវិវឌ្ឍ ឆ្នាំ២០២៥	មិនត្រូវបានអនុវត្តទេ។ ការផ្លាស់ទីលំនៅក្នុងប្រទេស និងការវិលត្រឡប់មកវិញយ៉ាងច្រើនរបស់ជនអន្តោប្រវេសន៍កម្ពុជាពីប្រទេសថៃ ជាមួយនឹងឱកាសចិញ្ចឹមជីវិតមានកម្រិតនៅក្នុងប្រទេសកម្ពុជា ទំនងជាបានបង្កើនហានិភ័យនៃការជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយមិនមានសុវត្ថិភាព។	២០២៣/២០២៤ ២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ២៧ខ

ប្រធានបទ	ការជួញដូរមនុស្ស	កម្រិត
សេចក្តីសង្ខេប	ធ្វើការកែលម្អការកំណត់អត្តសញ្ញាណ និងការណែនាំឱ្យទៅរកស្ថាប័នដែលផ្តល់ជំនួយសម្រាប់ជនរងគ្រោះ	២០២០ ២០២១ ២០២២
ការវិវឌ្ឍ ឆ្នាំ២០២៥	រដ្ឋាភិបាលបានបដិសេធជាប្រព័ន្ធក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះ ដែលត្រូវបានជួញដូរចូលទៅក្នុងឧស្សាហកម្មបោកប្រាស់។ មិនមានយន្តការកំណត់អត្តសញ្ញាណដែលមានប្រសិទ្ធភាព ឬការបញ្ជូនទៅកាន់សេវាសមស្របនោះទេ។	២០២៣/២០២៤ ២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ២៧គ

ប្រធានបទ	ការជួញដូរមនុស្ស	កម្រិត
សេចក្តីសង្ខេប	ការដាក់បញ្ចូលជនរងគ្រោះឱ្យរួមរស់នៅក្នុងសង្គមឡើងវិញ	២០២០ ២០២១ ២០២២
ការវិវឌ្ឍ ឆ្នាំ២០២៥	ការទទួលបានសេវាផ្សេងៗ និងការស្តារនីតិសម្បទា នៅតែមានកម្រិត មិនគ្រប់គ្រាន់ និងមិនអាចទទួលបាន ជាពិសេសសម្រាប់អ្នកដែលត្រូវគេកេងប្រវ័ញ្ចក្នុងឧស្សាហកម្មបោកប្រាស់។	២០២៣/២០២៤ ២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ២៧យ

ប្រធានបទ	ការជួញដូរមនុស្ស	កម្រិត
សេចក្តីសង្ខេប	ការពារស្ត្រីពីការខាតបង់ ការការពារសាក្សី	២០២០ ២០២១ ២០២២
ការវិវឌ្ឍ ឆ្នាំ២០២៥	មិនមានការការពារណាមួយអាចរកបាន សម្រាប់អ្នកដែលត្រូវបានគេជួញដូរចូលទៅក្នុងឧស្សាហកម្មបោកប្រាស់នោះទេ ដែលជារឿយៗ ត្រូវបានផ្តន្ទាទោសចាជាជនអន្តោប្រវេសន៍ មិនទៀងទាត់ និងត្រូវជាប់ឃុំឃាំងអន្តោប្រវេសន៍។	២០២៣/២០២៤ ២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ២៧ង

ប្រធានបទ	ការជួញដូរមនុស្ស	កម្រិត
សេចក្តីសង្ខេប	ការដាក់ទោសទណ្ឌលើអ្នកប្រព្រឹត្តអំពើជួញដូរមនុស្ស	២០២០ ២០២១ ២០២២
ការវិវឌ្ឍ ឆ្នាំ២០២៥	ភាពស្មុគស្មាញក្នុងឧស្សាហកម្មបោកប្រាស់ នាំឱ្យជនល្មើសទទួលបាននិទណ្ឌភាព។ រដ្ឋាភិបាលមិនបានរាយការណ៍ពីការចោទប្រកាន់ពីបទជួញដូរកម្លាំងពលកម្មណាមួយឡើយ ចាប់តាំងពីឆ្នាំ ២០២២ មក។[5]	២០២៣/២០២៤ ២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ២៧ច

ប្រធានបទ	ការជួញដូរមនុស្ស	កម្រិត
សេចក្តីសង្ខេប	ការបញ្ឈប់ការប្រើប្រាស់ច្បាប់ប្រឆាំងការជួញដូរមនុស្សខុសគោលដៅ ទៅលើបុគ្គលដែលមិនមែនជាជនល្មើសជួញដូរមនុស្ស	២០២០ ២០២១ ២០២២
ការវិវឌ្ឍ ឆ្នាំ២០២៥	ច្បាប់ និងគំនិតផ្តួចផ្តើមប្រឆាំងការជួញដូរមនុស្ស បានបន្តកំណត់គោលដៅមិនត្រឹមត្រូវ ទៅលើអ្នកប្រកបរបរផ្លូវភេទ។	២០២៣/២០២៤ ២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ២៩ក

ប្រធានបទ	អំពើពេស្យាចារ	កម្រិត
សេចក្តីសង្ខេប	ធ្វើការពិនិត្យឡើងវិញនូវច្បាប់ដើម្បីមិនធ្វើឱ្យការប្រកបរបរផ្លូវភេទត្រូវជាប់ទោសទណ្ឌ	២០២០ ២០២១ ២០២២
ការវិវឌ្ឍ ឆ្នាំ២០២៥	ពុំទាន់បានអនុវត្តនៅឡើយ	២០២៣/២០២៤ ២០២៥

5 U.S. Department of State, above n 97.

លេខរៀងកថាខណ្ឌនៃ CoBs: ២៩ខ

ប្រធានបទ	អំពើពេស្យាចារ	កម្រិត
សេចក្តីសង្ខេប	ដាក់ទោសអ្នកកេងប្រវ័ញ្ចលើអំពើនេះ	២០២០ ២០២១ ២០២២ ២០២៣/២០២៤ ២០២៥
ការវិវឌ្ឍ ឆ្នាំ២០២៥	កិច្ចខិតខំប្រឹងប្រែងមួយចំនួន គឺដូចនឹងឆ្នាំមុនៗ។ ទោះជាយ៉ាងណាក៏ដោយ អ្នកប្រកបរបរផ្លូវភេទ នៅតែបន្តប្រឈមមុខនឹងការចាប់ខ្លួន និងឃុំខ្លួនច្រើនជាងអ្នកកេងប្រវ័ញ្ច។	

លេខរៀងកថាខណ្ឌនៃ CoBs: ២៩គ

ប្រធានបទ	អំពើពេស្យាចារ	កម្រិត
សេចក្តីសង្ខេប	ដោះស្រាយបញ្ហាជាឫសគល់ ដូចជាភាពក្រីក្រ តម្រូវការ វិសមភាព	២០២០ ២០២១ ២០២២ ២០២៣/២០២៤ ២០២៥
ការវិវឌ្ឍ ឆ្នាំ២០២៥	មានកិច្ចប្រឹងប្រែងមួយចំនួនដូចនឹងឆ្នាំមុនដែរ	

លេខរៀងកថាខណ្ឌនៃ CoBs: ២៩ឃ

ប្រធានបទ	អំពើពេស្យាចារ	កម្រិត
សេចក្តីសង្ខេប	ផ្តល់នីតិសម្បទា	២០២០ ២០២១ ២០២២ ២០២៣/២០២៤ ២០២៥
ការវិវឌ្ឍ ឆ្នាំ២០២៥	កម្មវិធីស្តារនីតិសម្បទា និងសមាហរណកម្មមួយចំនួនត្រូវបានអនុវត្ត។ ការទទួលបានសិទ្ធិការងារ អត្ថប្រយោជន៍ការងារ និងការការពារសង្គមរបស់ស្ត្រីប្រកបរបរផ្លូវភេទ នៅតែអវត្តមាន ឬមិនគ្រប់គ្រាន់។	

លេខរៀងកថាខណ្ឌនៃ CoBs: ៣១ក

ប្រធានបទ	ជីវិតសាធារណៈ	កម្រិត
សេចក្តីសង្ខេប	អនុម័តវិធានការពិសេសបណ្តោះអាសន្ន ដូចជាការផ្តល់កូតា	២០២០ ២០២១ ២០២២ ២០២៣/២០២៤ ២០២៥
ការវិវឌ្ឍ ឆ្នាំ២០២៥	ពុំបានអនុវត្តនៅឡើយ	

លេខរៀងកថាខណ្ឌនៃ CoBs: ៣១ខ

ប្រធានបទ	ជីវិតសាធារណៈ	កម្រិត
សេចក្តីសង្ខេប	បង្កើតបរិយាកាសដែលជួយដល់ស្ត្រី	២០២០ ២០២១ ២០២២
ការវិវឌ្ឍ ឆ្នាំ២០២៥	ប្រទេសកម្ពុជានៅតែបន្តរំលោភសិទ្ធិរបស់ស្ត្រីអ្នកនយោបាយគណបក្សប្រឆាំង។ ស្ត្រី និងក្រុមអ្នកងាយរងគ្រោះផ្សេងទៀត នៅតែមានតំណាងតិចតួចនៅគ្រប់កម្រិតនៃអភិបាលកិច្ច។	២០២៣/២០២៤ ២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ៣៣ក

ប្រធានបទ	សញ្ជាតិ	កម្រិត
សេចក្តីសង្ខេប	ការទទួលបានសញ្ជាតិ ការអប់រំ ការងារ ការថែទាំសុខភាព ផ្តល់ជម្រកដល់ស្ត្រីដែលមានសញ្ជាតិជាជនជាតិវៀតណាម និងមានដើមកំណើតខ្មែរ	២០២០ ២០២១ ២០២២
ការវិវឌ្ឍ ឆ្នាំ២០២៥	ការទទួលបានសញ្ជាតិ និងសេវាសម្រាប់ស្ត្រីជនជាតិភាគតិចនៅតែមិនគ្រប់គ្រាន់។ ប្រទេសកម្ពុជា បានធ្វើវិសោធនកម្មក្រមខ័ណ្ឌច្បាប់នៅឆ្នាំ ២០២៥ ដើម្បីអនុញ្ញាតឱ្យសញ្ជាតិកម្ពុជាត្រូវបានដកហូតតាមអំពើចិត្តដោយគ្មានការការពារគ្រប់គ្រាន់ ប្រឆាំងនឹងភាពមិនមានរដ្ឋ។	២០២៣/២០២៤ ២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ៣៣ខ

ប្រធានបទ	សញ្ជាតិ	កម្រិត
សេចក្តីសង្ខេប	សម្រួលដល់ការធ្វើឯកសារកំណត់អត្តសញ្ញាណ និងសំបុត្រកំណើតដោយគ្មានការដកហូតឯកសារ	២០២០ ២០២១ ២០២២
ការវិវឌ្ឍ ឆ្នាំ២០២៥	មិនទាន់ត្រូវបានកំណត់នៅឡើយទេ ថាតើច្បាប់ការចុះបញ្ជីអត្រានុកូលដ្ឋាន ស្របតាមច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម (ច្បាប់ CRVSID) ឆ្នាំ២០២៣ នឹងធ្វើឱ្យប្រសើរឡើងនូវការចូលប្រើប្រាស់ឯកសារ និងការចុះឈ្មោះក្នុងការអនុវត្តជាក់ស្តែង ជាពិសេសសម្រាប់ស្ត្រី និងក្មេងស្រីដើមកំណើតវៀតណាម។	២០២៣/២០២៤ ២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ៣៣គ

ប្រធានបទ	សញ្ជាតិ	កម្រិត
សេចក្តីសង្ខេប	ផ្តល់សច្ចាប័នលើអនុសញ្ញាចំនួនពីរ ស្តីពីភាពមិនមែនជាពលរដ្ឋនៃប្រទេសណាមួយ (Statelessness)	២០២០ ២០២១ ២០២២
ការវិវឌ្ឍ ឆ្នាំ២០២៥	ពុំទាន់បានអនុវត្តនៅឡើយ	២០២៣/២០២៤ ២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ៣៥ក

ប្រធានបទ	ការអប់រំ	
សេចក្តីសង្ខេប	បង្កើនការទទួលបានការអប់រំនៅកម្រិតអនុវិទ្យាល័យ លុបបំបាត់កត្តារារាំងសម្រាប់ក្មេងស្រី	
ការវិវឌ្ឍ ឆ្នាំ២០២៥	កិច្ចខិតខំប្រឹងប្រែងមួយចំនួនកំពុងបន្ត។ ការអប់រំរបស់សិស្សានុសិស្សរាប់រយរាប់ពាន់នាក់ រងការរំខានដោយសារតែជម្លោះព្រំដែនកម្ពុជា-ថៃ។	

កម្រិត	
២០២០	
២០២១	
២០២២	
២០២៣/២០២៤	
២០២៥	

លេខរៀងកថាខណ្ឌនៃ CoBs: ៣៥ខ

ប្រធានបទ	ការអប់រំ	
សេចក្តីសង្ខេប	ជំរុញលើកទឹកចិត្តដល់កុមារី ឱ្យចូលក្នុងវិធីសាស្ត្រអប់រំ STEAM (មុខវិជ្ជា វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្ប: និងគណិតវិទ្យា)	
ការវិវឌ្ឍ ឆ្នាំ២០២៥	ជំហានមួយចំនួនត្រូវបានអនុវត្តដើម្បីលើកទឹកចិត្តដល់ការចូលរួម។	

កម្រិត	
២០២០	
២០២១	
២០២២	
២០២៣/២០២៤	
២០២៥	

លេខរៀងកថាខណ្ឌនៃ CoBs: ៣៥គ

ប្រធានបទ	ការអប់រំ	
សេចក្តីសង្ខេប	ផ្តល់វគ្គបណ្តុះបណ្តាល អំពីយ៉េនឌ័រដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយដល់គ្រូបង្រៀន	
ការវិវឌ្ឍ ឆ្នាំ២០២៥	ខណៈពេលដែលការបណ្តុះបណ្តាលមួយចំនួនត្រូវបានអនុវត្ត វាមិនគ្រប់គ្រាន់ដើម្បីលុបបំបាត់ការរើសអើងយេនឌ័រ ឬទស្សនៈអវិជ្ជមានដែលចាក់ឫសយ៉ាងជ្រៅនោះទេ។	

កម្រិត	
២០២០	
២០២១	
២០២២	
២០២៣/២០២៤	
២០២៥	

លេខរៀងកថាខណ្ឌនៃ CoBs: ៣៧ក

ប្រធានបទ	ការងារ	
សេចក្តីសង្ខេប	បុគ្គលិកកម្មករស្ថិតក្នុងកិច្ចសន្យាមានថេរវេលាកំណត់ ទទួលបានសេរីភាពបង្កើតសហជីព និងអត្ថប្រយោជន៍នៃការឈប់លំហែមាតុភាព	
ការវិវឌ្ឍ ឆ្នាំ២០២៥	កិច្ចសន្យាមានកាលកំណត់នៅតែជារឿងធម្មតា ដែនកំណត់មិនត្រូវបានអនុវត្តទេ ហើយត្រូវបានប្រើប្រាស់ខុសជាប្រព័ន្ធ និងបានធ្វើឱ្យប៉ះពាល់ដល់ការទទួលបានច្បាប់ឈប់សម្រាកលំហែមាតុភាព និងសិទ្ធិសេរីភាពសមាគម និងការជួបជុំ។	

កម្រិត	
២០២០	
២០២១	
២០២២	
២០២៣/២០២៤	
២០២៥	

លេខរៀងកថាខណ្ឌនៃ CoBs: ៣៧ខ

ប្រធានបទ	ការងារ	កម្រិត
សេចក្តីសង្ខេប	ការពារសិទ្ធិអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ រួមបញ្ចូលអ្នកធ្វើការងារតាមផ្ទះ ទៅក្នុងច្បាប់ស្តីពីការងារ	២០២០ ២០២១ ២០២២
ការវិវឌ្ឍ ឆ្នាំ២០២៥	កម្មករធ្វើការតាមផ្ទះ និងកម្មករសេដ្ឋកិច្ចក្រៅប្រព័ន្ធផ្សេងទៀតមិនត្រូវបានការពារ ពេញលេញក្រោមច្បាប់ការងារទេ។ ការទទួលបានការការពារសង្គមមិនស្មើគ្នា ក្នុងចំណោមកម្មករសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ ស្ត្រីក្នុងវិស័យសេវាកម្មាន្តច្រើនតែធ្វើការ ដោយគ្មានកិច្ចសន្យា និងអត្ថប្រយោជន៍ការងារ។	២០២៣/២០២៤ ២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ៣៧គ

ប្រធានបទ	ការងារ	កម្រិត
សេចក្តីសង្ខេប	ជំរុញលើកទឹកចិត្តឱ្យមានការចែករំលែកតួនាទីជាឪពុកម្តាយ ដោយមានការឈប់លំហែបិតុភាព	២០២០ ២០២១ ២០២២
ការវិវឌ្ឍ ឆ្នាំ២០២៥	ស្ត្រីនៅតែបន្តបំពេញភារកិច្ចភាគច្រើននៃការងារផ្ទះ និងគ្រួសារ លទ្ធភាពទទួលបានបរិក្ខាថែទាំកុមារនៅមានកម្រិត។ ច្បាប់កម្ពុជា នៅតែមិនទាន់ចែងអំពីសិទ្ធិជាក់លាក់ណាមួយ ដែលលើកឡើងពីច្បាប់បិតុភាព សម្រាប់ការឈប់សម្រាកពីការងារដោយមានប្រាក់ឈ្នួល នៅឡើយ។	២០២៣/២០២៤ ២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ៣៧ឃ

ប្រធានបទ	ការងារ	កម្រិត
សេចក្តីសង្ខេប	ការតាក់តែងច្បាប់ដោយមានលក្ខណៈគ្រប់ជ្រុងជ្រោយ ស្តីពីការបៀតបៀនផ្លូវភេទ ដោយមានដំណោះស្រាយ	២០២០ ២០២១ ២០២២
ការវិវឌ្ឍ ឆ្នាំ២០២៥	ពុំទាន់បានអនុវត្តនៅឡើយ	២០២៣/២០២៤ ២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ៣៧ង

ប្រធានបទ	ការងារ	កម្រិត
សេចក្តីសង្ខេប	ធានាឱ្យមានប្រាក់ឈ្នួលស្មើគ្នាសម្រាប់ការងារមានតម្លៃស្មើគ្នា យោងតាមអនុសញ្ញាលេខ ១០០ នៃអង្គការអន្តរជាតិខាងផ្នែកការងារ (ILO C100)	២០២០ ២០២១ ២០២២
ការវិវឌ្ឍ ឆ្នាំ២០២៥	គោលការណ៍នៃប្រាក់ឈ្នួលស្មើគ្នាសម្រាប់ការងារ ដែលមានតម្លៃស្មើគ្នាមិនត្រូវបានចែងគ្រប់គ្រាន់នៅក្នុងច្បាប់ទេ។ ច្បាប់ដែលមានស្រាប់ ស្តីពីប្រាក់ឈ្នួលស្មើគ្នាសម្រាប់ការងារ ដែលមានតម្លៃស្មើគ្នាមិនត្រូវបានអនុវត្តជាប់លាប់ទេ។ ប្រាក់ឈ្នួលអប្បបរមាអនុវត្តតែនៅ ក្នុងវិស័យសម្លៀកបំពាក់ ស្បែកជើង និងទំនិញធ្វើដំណើរប៉ុណ្ណោះ។	២០២៣/២០២៤ ២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ៣៧ច

ប្រធានបទ	ការងារ	កម្រិត
សេចក្តីសង្ខេប	ការពារកម្មករចំណាកស្រុកទៅក្រៅប្រទេស	២០២០ ២០២១ ២០២២ ២០២៣/២០២៤ ២០២៥
ការវិវឌ្ឍ ឆ្នាំ២០២៥	លោកហ៊ុន សែន ប្រធានព្រឹទ្ធសភា បានអំពាវនាវឱ្យប្រជាជនកម្ពុជានៅប្រទេសថៃ វិលត្រឡប់មកផ្ទះវិញនៅក្នុងខែមិថុនា ឆ្នាំ២០២៥ រួមជាមួយនឹងការធានារបស់រដ្ឋាភិបាល លើការងារ និងការគាំទ្រផ្នែកសង្គម។ ការគាំទ្រសម្រាប់ពលករចំណាកស្រុក ដែលបានវិលត្រឡប់មកវិញមានកម្រិត ដែលបង្កើនភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច និងសម្ពាធឱ្យមានការធ្វើចំណាកស្រុកឡើងវិញ តាមរយៈបណ្តាញមិនមានសុវត្ថិភាព។	

លេខរៀងកថាខណ្ឌនៃ CoBs: ៣៧ឆ

ប្រធានបទ	ការងារ	កម្រិត
សេចក្តីសង្ខេប	ផ្តល់សច្ចាប័នលើអនុសញ្ញានៃអង្គការអន្តរជាតិខាងផ្នែក ការងារ លេខ ១៨៣ លេខ ១៨៩ លេខ ១៩០	២០២០ ២០២១ ២០២២ ២០២៣/២០២៤ ២០២៥
ការវិវឌ្ឍ ឆ្នាំ២០២៥	ពុំទាន់បានអនុវត្តនៅឡើយ	

លេខរៀងកថាខណ្ឌនៃ CoBs: ៣៩ក

ប្រធានបទ	សុខភាព	កម្រិត
សេចក្តីសង្ខេប	ការទទួលបានជាសកលនូវសេវាថែទាំសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ	២០២០ ២០២១ ២០២២ ២០២៣/២០២៤ ២០២៥
ការវិវឌ្ឍ ឆ្នាំ២០២៥	កិច្ចខិតខំប្រឹងប្រែងកំពុងបន្ត ដើម្បីធានាឱ្យមានសិទ្ធិទទួលបានស្មើគ្នាចំពោះ ការថែទាំសុខភាពផ្លូវភេទ និងបន្តពូជ រួមទាំងសេវាទាក់ទងនឹងមេរោគអេដស៍ និងសេវា រំលូតកូនដោយសុវត្ថិភាព បើទោះបីជាការទទួលបានមិនស្មើគ្នាក៏ដោយ។	

លេខរៀងកថាខណ្ឌនៃ CoBs: ៣៩ខ

ប្រធានបទ	សុខភាព	កម្រិត
សេចក្តីសង្ខេប	ការប្រយុទ្ធប្រឆាំងនឹងការទទួលរងស្លាកស្នាមមិនល្អ នៃការយកកូនចេញ និងការប្រើប្រាស់វិធីពន្យារកំណើត	២០២០ ២០២១ ២០២២ ២០២៣/២០២៤ ២០២៥
ការវិវឌ្ឍ ឆ្នាំ២០២៥	ការរើសអើងប្រឆាំងនឹងស្ត្រី និងក្មេងស្រីដែលប្រើប្រាស់សេវារំលូតកូន ដោយសុវត្ថិភាពនៅតែមានសារៈសំខាន់។ វិធានការដើម្បីប្រយុទ្ធប្រឆាំងនឹងការ រើសអើង រួមទាំង CSE នៅតែមិនស៊ីសង្វាក់គ្នា។	

លេខរៀងកថាខណ្ឌនៃ CoBs: ៣៩គ

ប្រធានបទ	សុខភាព	កម្រិត
សេចក្តីសង្ខេប	ដោះស្រាយតម្រូវការអាហារូបត្ថម្ភរបស់ស្ត្រី នៅក្នុងយុទ្ធសាស្ត្រនានា	២០២០ ២០២១ ២០២២
ការវិវឌ្ឍ ឆ្នាំ២០២៥	ប្រទេសកម្ពុជាបានបន្តដោះស្រាយតម្រូវការអាហារូបត្ថម្ភរបស់ស្ត្រីនៅក្នុងយុទ្ធសាស្ត្រផ្សេងៗ។ នៅឆ្នាំ២០២៥ ក្រសួងសុខាភិបាលបានដាក់ឱ្យដំណើរការ “ផែនទីបង្ហាញផ្លូវ រហ័សសម្រាប់ការកែលម្អអាហារូបត្ថម្ភ ២០២៣ - ២០៣០”។	២០២៣/២០២៤ ២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ៣៩យ

ប្រធានបទ	សុខភាព	កម្រិត
សេចក្តីសង្ខេប	ការទប់ស្កាត់មហារីកស្បូន	២០២០ ២០២១ ២០២២
ការវិវឌ្ឍ ឆ្នាំ២០២៥	ប្រទេសកម្ពុជាបានបន្តកិច្ចខិតខំប្រឹងប្រែងក្នុងការបង្ការ និងដោះស្រាយបញ្ហាមហារីកមាត់ស្បូនតាមរយៈវ៉ាក់សាំង HPV និងការពិនិត្យរកមេរោគ។ ទោះជាយ៉ាងណាក៏ដោយ ការចូលប្រើប្រាស់នៅតែមិនស្មើគ្នា។	២០២៣/២០២៤ ២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ៤១

ប្រធានបទ	ស្ត្រីជនបទ	កម្រិត
សេចក្តីសង្ខេប	ធ្វើនិយតកម្មលើគ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ និងកែលម្អការទទួលបានប្រាក់កម្ចីដែលមានអត្រាការប្រាក់ទាប ជួយគាំទ្រដល់អាជីពខ្នាតធំដែលមានស្ត្រីជាម្ចាស់	២០២០ ២០២១ ២០២២
ការវិវឌ្ឍ ឆ្នាំ២០២៥	វិស័យមីក្រូហិរញ្ញវត្ថុមិនត្រូវបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពទេ ហើយពឹងផ្អែកលើការអនុវត្តដែលមានលក្ខណៈកៀបសង្កត់ និងកេងប្រវ័ញ្ច។ រដ្ឋាភិបាលកម្ពុជា និងវិនិយោគិនអន្តរជាតិមិនបានបន្ធូរបន្ថយ ឬផ្តល់សំណងសមរម្យណាមួយឡើយ។	២០២៣/២០២៤ ២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ៤៣ក

ប្រធានបទ	ការប្រែប្រួលអាកាសធាតុ	កម្រិត
សេចក្តីសង្ខេប	បញ្ចូលស្ត្រីក្នុងការបង្កើតគោលនយោបាយ	២០២០ ២០២១ ២០២២
ការវិវឌ្ឍ ឆ្នាំ២០២៥	ការរួមបញ្ចូលសំឡេងរបស់ស្ត្រី និងក្មេងស្រីក្នុងការបង្កើតគោលនយោបាយនៅមានកម្រិត។ សកម្មជនបរិស្ថានស្ត្រី ដែលបានសម្តែងមតិពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ បានប្រឈមមុខនឹងការយាយី និងការដាប់ពន្ធនាគារ។	២០២៣/២០២៤ ២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ៤៣ខ

ប្រធានបទ	ការប្រែប្រួលអាកាសធាតុ	
សេចក្តីសង្ខេប	បញ្ចូលទស្សនៈវិស័យយេនឌ័រដែលមានលក្ខណៈច្បាស់លាស់ទៅក្នុងគោលនយោបាយ	
ការវិវឌ្ឍ ឆ្នាំ២០២៥	ទស្សនៈយេនឌ័រត្រូវបានដាក់បញ្ចូលនៅក្នុងគោលនយោបាយមួយចំនួន។ ទោះជាយ៉ាងណាក៏ដោយ គោលនយោបាយមួយចំនួនខ្វះសកម្មភាព ធនធាន និងការណែនាំលម្អិតដែលចាំបាច់មួយចំនួនក្នុងការអនុវត្តទស្សនៈយេនឌ័រ ជាពិសេសនៅថ្នាក់ក្រោមជាតិ។	

កម្រិត
២០២០
២០២១
២០២២
២០២៣/២០២៤
២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ៤៥ក

ប្រធានបទ	ស្ត្រីស្ថិតក្នុងការឃុំខ្លួន	
សេចក្តីសង្ខេប	ប្រើវិធីសាស្ត្រផ្សេងទៀតជំនួសដោយការឃុំខ្លួន	
ការវិវឌ្ឍ ឆ្នាំ២០២៥	ចំនួនប្រជាជនក្នុងពន្ធនាគារបានបន្តកើនឡើងក្នុងអត្រាមិនធ្លាប់មានពីមុនមក។ ចំនួនស្ត្រី និងក្មេងស្រីដែលត្រូវបានឃុំខ្លួននៅក្នុងពន្ធនាគារ ដែលត្រូវបានឃ្លាំមើលដោយអង្គការលីកាដូបានកើនឡើង 26% ក្នុងឆ្នាំ2025 និង 67% ចាប់តាំងពីខែមករា ឆ្នាំ2024។ ជម្រើសផ្សេងទៀតជំនួសឱ្យការការឃុំខ្លួន មិនត្រូវបានពិចារណា ឬអនុវត្តឱ្យបានគ្រប់គ្រាន់ទេ។	

កម្រិត
២០២០
២០២១
២០២២
២០២៣/២០២៤
២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ៤៥ខ

ប្រធានបទ	ស្ត្រីស្ថិតក្នុងការឃុំខ្លួន	
សេចក្តីសង្ខេប	ដោះស្រាយបញ្ហាជាឫសគល់ និងផលប៉ះពាល់លើកុមារពីការកាត់ឱ្យជាប់ពន្ធនាគារ	
ការវិវឌ្ឍ ឆ្នាំ២០២៥	ពុំទាន់បានអនុវត្តនៅឡើយ	

កម្រិត
២០២០
២០២១
២០២២
២០២៣/២០២៤
២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ៤៥គ

ប្រធានបទ	ស្ត្រីស្ថិតក្នុងការឃុំខ្លួន	
សេចក្តីសង្ខេប	កាត់បន្ថយចំនួនមនុស្សលើសចំណុះ សេវា តាមវិធានទីក្រុងបាំងកក និងវិធានណេសាន់ ម៉ានដេឡា	
ការវិវឌ្ឍ ឆ្នាំ២០២៥	ពន្ធនាគារនៅតែចង្អៀតណែនខ្លាំង ដោយស្ទើរតែគ្រប់កន្លែងទាំងអស់ផ្ទុកមនុស្សលើសពីចំនួនដែលបានកំណត់។ លក្ខខណ្ឌរស់នៅ និងការទទួលបានសេវានៅតែមិនគ្រប់គ្រាន់។	

កម្រិត
២០២០
២០២១
២០២២
២០២៣/២០២៤
២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ៤៧ក

ប្រធានបទ	ស្ត្រីពរពោះជំនួស	
សេចក្តីសង្ខេប	លុបចោលសេចក្តីសម្រេចក្នុងខែធ្នូ ឆ្នាំ២០១៦ ដើម្បីអនុញ្ញាតឱ្យស្ត្រីពរពោះជំនួសមានសិទ្ធិចិញ្ចឹមក្មេងក្នុងនាមជាកូនបង្កើតរបស់ខ្លួន	
ការវិវឌ្ឍ ឆ្នាំ២០២៥	ពុំទាន់បានអនុវត្តនៅឡើយ	

កម្រិត
២០២០
២០២១
២០២២
២០២៣/២០២៤
២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ៤៧ខ

ប្រធានបទ	ស្ត្រីពរពោះជំនួស	
សេចក្តីសង្ខេប	ដោះស្រាយបញ្ហាជាឫសគល់ ដោយកែលម្អឱកាសនៃការរកប្រាក់ចំណូល	
ការវិវឌ្ឍ ឆ្នាំ២០២៥	ពុំទាន់បានអនុវត្តនៅឡើយ	

កម្រិត
២០២០
២០២១
២០២២
២០២៣/២០២៤
២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ៤៧គ

ប្រធានបទ	ស្ត្រីពរពោះជំនួស	
សេចក្តីសង្ខេប	ធានាថា ច្បាប់ និងគោលនយោបាយនឹងជួយដោះស្រាយអតុល្យភាពអំណាចនៃស្ត្រីពរពោះជំនួស	
ការវិវឌ្ឍ ឆ្នាំ២០២៥	ពុំទាន់បានអនុវត្តនៅឡើយ	

កម្រិត
២០២០
២០២១
២០២២
២០២៣/២០២៤
២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ៤៧ឃ

ប្រធានបទ	ស្ត្រីពរពោះជំនួស	
សេចក្តីសង្ខេប	ច្បាប់មិនគួរដាក់ទោសទណ្ឌលើស្ត្រីពរពោះជំនួស	
ការវិវឌ្ឍ ឆ្នាំ២០២៥	សេចក្តីព្រាងច្បាប់នេះ នៅមិនទាន់បានបញ្ចប់នៅឡើយទេ។ សេចក្តីព្រាងច្បាប់មុនៗនៅតែបន្តដាក់ទោសទណ្ឌស្ត្រីដែលធ្វើជាអ្នកពពោះជំនួស។	

កម្រិត
២០២០
២០២១
២០២២
២០២៣/២០២៤
២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ៤៩ក

ប្រធានបទ	អាពាហ៍ពិពាហ៍	
សេចក្តីសង្ខេប	វិធានការនានា ផ្តោលើការបន្ថយអត្រានៃការរៀបអាពាហ៍ពិពាហ៍កុមារ	
ការវិវឌ្ឍ ឆ្នាំ២០២៥	វិធានការគោលដៅមួយចំនួនត្រូវបានអនុវត្ត។ កម្ពុជាបានបង្ហាញពីការបង្កើតផែនការ សកម្មភាពជាតិស្តីពីការទប់ស្កាត់ការរៀបការវ័យក្មេង និងការមានផ្ទៃពោះក្នុងវ័យជំទង់ នៅកម្ពុជា (២០២៥-២០៣០)។	

កម្រិត
២០២០
២០២១
២០២២
២០២៣/២០២៤
២០២៥

លេខរៀងកថាខណ្ឌនៃ CoBs: ៤៩ខ

ប្រធានបទ	អាពាហ៍ពិពាហ៍	
សេចក្តីសង្ខេប	លុបចោលមាត្រា ៩៥០ នៃក្រមរដ្ឋប្បវេណី	
ការវិវឌ្ឍ ឆ្នាំ២០២៥	ពុំទាន់បានអនុវត្តនៅឡើយ	

កម្រិត
២០២០
២០២១
២០២២
២០២៣/២០២៤
២០២៥

គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់ នៃការរើសអើងប្រឆាំងនឹងនារីភេទ (NGO-CEDAW) ជាសម្ព័ន្ធអង្គការឈានមុខគេ ដែលធ្វើការតាមដាន និងលើកកម្ពស់ឱ្យមានការអនុវត្តអនុញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើនារីភេទ (ស៊ី-ដ)។ អង្គការនេះ បានបង្កើតឡើងនៅក្នុង ឆ្នាំ១៩៩៥ ដោយសកម្មជនស្ត្រីកម្ពុជាមួយក្រុម នៅក្រោយការវិលត្រឡប់មកវិញរបស់ពួកគាត់ ពីការចូលរួមសន្និសីទពិភពលោកស្តីពីស្ត្រីនៅទីក្រុងប៉েកាំង។ NGO-CEDAW បានពង្រីកសមាជិកភាពរបស់ខ្លួនពី ៩អង្គការ ដែលជាអ្នកបង្កើត NGO-CEDAW នេះឡើង រហូតមកដល់ ៣២អង្គការ ក្នុងស្រុកជាសមាជិក។ NGO-CEDAW ធ្វើការជាមួយបណ្តាញដៃគូជាង ៣០បន្ថែមទៀត ដើម្បីផ្តល់សម្លេងគាំទ្រដល់ក្រុមស្ត្រី និងសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា (LGBTIQ+) ដែលងាយរងគ្រោះ។

ការងាររបស់ NGO-CEDAW រួមមាន៖
ការស្រាវជ្រាវ ការស្វែងរកមតិគាំទ្រ ការលើកកម្ពស់ការយល់ដឹង កសាងសមត្ថភាព និងការផ្លាស់ប្តូរព័ត៌មានក្នុងចំណោមសមាជិករបស់ខ្លួន។ សកម្មភាពសំខាន់ៗរបស់ NGO-CEDAW រួមមានការកសាងសមត្ថភាព ការរៀបចំវេទិកាជជែកដេញដោលថ្នាក់សាកលវិទ្យាល័យប្រចាំឆ្នាំ កម្មវិធីតាំងពិព័រណ៍ការបង្កើតស្នាដៃសិល្ប: ការតស៊ូមតិដោយផ្ទាល់នៅអង្គការសហប្រជាជាតិ ផ្តល់វគ្គបណ្តុះបណ្តាលដល់អង្គការជាសមាជិក និងក្រុមគោលដៅជាយុវជន។

អាសយដ្ឋាន ការិយាល័យ NGO-CEDAW:
ផ្ទះលេខ ១៦ ផ្លូវ ៩៩ សង្កាត់ បឹងត្របែក
ខណ្ឌចំការមន រាជធានីភ្នំពេញ

www.ngocedaw.org

ngocedaw.pnh@gmail.com

@TheCambodianNgoCommitteeOnCedaw